## គម្រោងគាំទ្រសេវាអប់រំកុមារតំបន់ដាច់ស្រយាល

**Educational Support to Children in Underserved Population (ESCUP)**

Educational Quality Improvement Program
Classrooms • Schools • Communities

# ភាសាខ្មែរបន្ថែម

**Supplementary Khmer Language**

## ថ្នាក់ទី ១



## សម្រាប់គ្រូ

**កំពង់ចាម ខែ មករា ឆ្នាំ ២០០៧**

កែសម្រួលពីឯកសាររបស់អង្គការឃែរកម្ពុជាក្នុងគម្រោងអភិវឌ្ឍន៍ការអប់រំកុមារតំបន់ខ្ពង់រាប **CARE/HCEP**

# អារម្ភកថា

សៀវភៅសិក្សា **“ភាសាខ្មែរបន្ថែម”** សំរាប់គ្រូ ថ្នាក់ទី១ ត្រូវបានរៀបរៀងឡើងតំរូវទៅតាមការសិក្សារបស់កុមារជនជាតិដែលមិនចេះភាសាខ្មែរឬចេះតិចតួចក្នុងសាលារៀនបឋមសិក្សារដ្ឋនៃតំបន់ដាច់ស្រយាល ។ សៀវភៅនេះជាសមិទ្ធផលនៃសហប្រតិបត្តិការរវាងអង្គការអប់រំពិភពលោកក្នុងគំរោងអេស្កាប់ និងអង្គការឃែរកម្ពុជា ដែលផ្តល់ ឯកសារ ។

ភាសាខ្មែរ ជាមុខវិជ្ជាដ៏សំខាន់មួយសំរាប់កុមារកម្ពុជារាល់រូបជាពិសេសកុមារជនជាតិនៅក្នុងប្រទេសដើម្បីឈានទៅចាប់យកឬស្វែងយល់មុខវិជ្ជាផ្សេងៗទៀតសំរាប់ជីវិតរស់នៅ ។ កុមារទាំងអស់មានសិទ្ធិទទួលបានការអប់រំកំរិតមូលដ្ឋានប្រកបដោយគុណភាព ដែលជំរុញអោយមានការគោរពចំពោះគ្រួសារ អត្តសញ្ញាណវប្បធម៌ និងភាសា ដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈ កោសល្យ និងសមត្ថភាពខាងខួរក្បាលនិងរាងកាយរបស់ពួកគេអោយបានពេញលេញ ។

ការជំរុញអោយមានបរិស្ថានកុមារមេត្រី និងការសិក្សាពេញលេញតំរូវអោយមាននូវគោលវិធីមួយ ដែលគោរពចំពោះវប្បធម៌ និងភាសាចំរុះនៅក្នុងថ្នាក់រៀន និងផ្តល់នូវអន្តរាគមន៍ទាំងឡាយដើម្បីដោះស្រាយតំរូវការជាក់ស្តែងរបស់កុមារជនជាតិភាគតិច ។

ការតាក់តែងសៀវភៅសិក្សា ភាសាខ្មែរបន្ថែម សំរាប់ថ្នាក់ទី១ បានប្រើប្រាស់សកម្មភាពជាច្រើនដើម្បីអោយសិស្សងាយយល់ និងងាយអនុវត្តតាម ។ សៀវភៅសំរាប់គ្រូនេះជាឯកសារជំនួយដល់លោកគ្រូ អ្នកគ្រូក្នុងការបង្រៀន ។

ក្រុមអ្នករៀបរៀង សង្ឃឹមថា សៀវភៅនេះនឹងផ្តល់អត្ថប្រយោជន៏យ៉ាងច្រើនដល់សិស្សក្នុងការសិក្សា ភាសាខ្មែរ ។ ក្រុមអ្នករៀបរៀងរង់ចាំទទួលការទិទៀនស្ថាបនាពីគ្រប់មជ្ឈដ្ឋាន ដើម្បីកែលំអអោយកាន់តែមាន ប្រសិទ្ធភាពខ្ពស់ ។

*ក្រុមបណ្តុះបណ្តាលគ្រូក្នុងគំរោងអេស្កាប់*

# បញ្ជីអត្ថបទ

*អារម្ភកថា*

*បញ្ជីអត្ថបទ*

*កម្មវិធីសិក្សាភាសាខ្មែរបន្ថែម*

*មេរៀនទី១: តោះចូរចាប់ផ្តើមរៀនភាសាខ្មែរ*.....១

- **ឈុតសកម្មភាពទី១:** ចំរៀង/កំណាព្យ/មេសូត្រ និងការជជែកអំពីរូបភាព.....២
  - ។មេសូត្រ.....២
  - ។ការជជែកអំពីរូបភាព "សាលារៀនរបស់ខ្ញុំ" .....៣
- **ឈុតសកម្មភាពទី២:** បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព.....៤
  - ។ បទបញ្ជាក្នុងថ្នាក់រៀន.....៤
  - ។ការជជែកអំពីរូបភាពនិងរឿងនិទាន "សាលារៀនរបស់ខ្ញុំ".....៥
- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព.....៦
  - ។ការស្វាគមន៍គ្នា.....៦
  - ។ការជជែកអំពីរូបភាពនិងរឿងនិទាន "សាលារៀនរបស់ខ្ញុំ".....៧
- **ឈុតសកម្មភាពទី៤:** ចំនួន និងការជជែកអំពីរូបភាព.....៧
  - ។ចំនួន.....៨
  - ។ការជជែកអំពីរូបភាពនិងរឿងនិទាន "សាលារៀនរបស់ខ្ញុំ".....៩

*មេរៀនទី២: តោះចូរបន្តរៀនភាសាខ្មែរ*.....១០

- **ឈុតសកម្មភាពទី១:** ចំរៀងនិងការជជែកអំពីរូបភាព.....១១
  - ។ចំនួន "វិញ្ញាណទាំងប្រាំ " .....១១
  - ។ការជជែកអំពីរូបភាព "សត្វទន្សាយនិងផ្លែចេក".....១២
- **ឈុតសកម្មភាពទី២:** បទបញ្ជាក្នុងថ្នាក់រៀននិងការជជែកអំពីរូបភាព.....១៣
  - ។បទបញ្ជាក្នុងថ្នាក់រៀន.....១៣
  - ។ការជជែកអំពីរូបភាពនិងរឿងនិទាន "សត្វទន្សាយនិងផ្លែចេក".....១៤
- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នានិងការជជែកអំពីរូបភាព.....១៤
  - ។ការស្វាគមន៍គ្នា.....១៥
  - ។ការជជែកអំពីរូបភាពនិងរឿងនិទាន "សត្វទន្សាយនិងផ្លែចេក".....១៦

- **ឈុតសកម្មភាពទី៤:** ការរៀនលេខ ការប្រកបចំនួន និងការជជែកអំពីរូបភាព........................១៦

  ៊ី ។ការរៀនលេខ និងការប្រកបចំនួន ......................................................................១៧

  ៊ី ។ការជជែកអំពីរូបភាពនិងរឿងនិទាន "សត្វទន្សាយនិងផ្លែចេក".......................................១៩

*មេរៀនទី៣: បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ*..................................................... .......................២១

- **ឈុតសកម្មភាពទី១:** ចំរៀង និងការជជែកអំពីរូបភាព......................................................២២

  ៊ី ។ចំរៀង" ជំរាបសួរគ្រូ " ...............................................................................................២២

  ៊ី ។ការជជែកអំពីរូបភាព "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ"......................... .............................២២

- **ឈុតសកម្មភាពទី២:** បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព...................................២៣

  ៊ី ។ បទបញ្ជាក្នុងថ្នាក់រៀន............................................................................................២៤

  ៊ី ។ការជជែកអំពីរូបភាព "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ"........................................................២៥

- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព...........................................២៥

  ៊ី ។ការស្វាគមន៍គ្នា.......................................................................................................២៥

  ៊ី ។ការជជែកអំពីរូបភាពនិងរឿងនិទាន "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ"......................................២៦

- **ឈុតសកម្មភាពទី៤:** ការរៀនលេខ ការប្រកបចំនួន និងការជជែកអំពីរូបភាព........................២៧

  ៊ី ។ការរៀនលេខ និងការប្រកបចំនួន ......................................................................២៧

  ៊ី ។ការជជែកអំពីរូបភាពនិងរឿងនិទាន "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ"......................................២៩

*មេរៀនទី៤: ការរៀនអំពីសត្វ*.......................................................................................៣១

- **ឈុតសកម្មភាពទី១:** ចំរៀង និងការជជែកអំពីរូបភាព......................................................៣២

  ៊ី ។ចំរៀង" សត្វទីទុយ " ..........................................................................................៣២

  ៊ី ។ការជជែកអំពីរូបភាព "មិត្តសំលាញ់សត្វរបស់ខ្ញុំ "........................................................៣៣

- ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព..................................៣៥

  ៊ី ។ បទបញ្ជាក្នុងថ្នាក់រៀន............................................................................................៣៥

  ៊ី ។ការជជែកអំពីរូបភាព " មិត្តសំលាញ់សត្វរបស់ខ្ញុំ "........................................................៣៦

- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព...........................................៣៨

  ៊ី ។ការស្វាគមន៍គ្នា.......................................................................................................៣៨

  ៊ី ។ការជជែកអំពីរូបភាពនិងរឿងនិទាន "មិត្តសំលាញ់សត្វរបស់ខ្ញុំ "......................................៣៩

- **ឈុតសកម្មភាពទី៤:** ការរៀនលេខ ការប្រកបចំនួន និងការជជែកអំពីរូបភាព........................៤៣

ៗការរៀនលេខ និងការប្រកបចំនួន ...............................................................................................៤០

ៗការជជែកអំពីរូបភាព " មិត្តសំលាញ់សត្វរបស់ខ្ញុំ " .....................................................................៤២

*មេរៀនទី៥: តើនរណាស្លៀកខោជើងខ្លីនៅថ្ងៃនេះ?*.........................................................................៤៤

- **ឈុតសកម្មភាពទី១:** ចំរៀង តារាងរូបភាព និង រឿងនិទាន..............................................**៤៥**

ៗចំរៀង" សត្វសេក " .............................................................................................................៤៥

ៗតារាងរូបភាព និងរឿងនិទាន "សំលៀកបំពាក់របស់ខ្ញុំ"..................................................................៤៦

- **ឈុតសកម្មភាពទី២:** បទបញ្ជាក្នុងថ្នាក់រៀន តារាងរូបភាព និងរឿងនិទាន ...........................៤៧

ៗ បទបញ្ជាក្នុងថ្នាក់រៀន.................................................................................................................៤៧

ៗតារាងរូបភាព និងរឿងនិទាន " សំលៀកបំពាក់របស់ខ្ញុំ "...............................................................៤៨

- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នា តារាងរូបភាព និងរឿងនិទាន.......................................៤៩

ៗការស្វាគមន៍គ្នា.........................................................................................................................៤៩

ៗតារាងរូបភាព និងរឿងនិទាន "សំលៀកបំពាក់របស់ខ្ញុំ "..................................................................៥០

- **ឈុតសកម្មភាពទី៤:** ការរៀនលេខ ការប្រកបចំនួន តារាងរូបភាព និងរឿងនិទាន...................៥០

ៗការរៀនលេខ និងការប្រកបចំនួន ...............................................................................................៥១

ៗតារាងរូបភាព និងរឿងនិទាន " សំលៀកបំពាក់របស់ខ្ញុំ"..................................................................៥២

*មេរៀនទី៦: មិត្តសំលាញ់របស់ខ្ញុំ*..........................................................................................................៥៤

- **ឈុតសកម្មភាពទី១:** ចំរៀង ការជជែកអំពីរូបភាព និង រឿងនិទាន....................................**៥៥**

ៗចំរៀង" សារិកាកែវ " ........................................................................................................៥៥

ៗការជជែកអំពីរូបភាព និងរឿងនិទាន "មិត្តសំលាញ់របស់ខ្ញុំ"..........................................................៥៦

- **ឈុតសកម្មភាពទី២:** បទបញ្ជាក្នុងថ្នាក់រៀន ការជជែកអំពីរូបភាព និងរឿងនិទាន .................៥៧

ៗ បទបញ្ជាក្នុងថ្នាក់រៀន.................................................................................................................៥៧

ៗការជជែកអំពីរូបភាព និងរឿងនិទាន " មិត្តសំលាញ់របស់ខ្ញុំ "..........................................................៥៨

- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នា ការជជែកអំពីរូបភាព និងរឿងនិទាន............................៥៩

ៗការស្វាគមន៍គ្នា.........................................................................................................................៥៩

ៗការជជែកអំពីរូបភាព និងរឿងនិទាន "មិត្តសំលាញ់របស់ខ្ញុំ "...........................................................៦០

- **ឈុតសកម្មភាពទី៤:** ការរៀនលេខ ការប្រកបចំនួន ការជជែកអំពីរូបភាព និងរឿងនិទាន..........៦១

ៗការរៀនលេខ និងការប្រកបលេខ...................................................................................................៦១

ៗការជជែកអំពីរូបភាព និងរឿងនិទាន " មិត្តសំលាញ់របស់ខ្ញុំ"...................................... .....៦៣

*មេរៀនទី៧: រាងកាយរបស់យើង* ....................................................................................................៦៤

- **ឈុតសកម្មភាពទី១:** ចំរៀង ការជជែកអំពីរូបភាព និង រឿងនិទាន......................................៦៥

ៜ ។ចំរៀង" សារិកាកែវ " ..................................................................................................៦៥

ៜ ។ការជជែកអំពីរូបភាព និងរឿងនិទាន "រាងកាយរបស់យើង"..........................................៦៦

- **ឈុតសកម្មភាពទី២:** បទបញ្ហាក្នុងថ្នាក់រៀន ការជជែកអំពីរូបភាព និងរឿងនិទាន ..................៦៨

ៜ ។ បទបញ្ហាក្នុងថ្នាក់រៀន.........................................................................................៦៨

ៜ ។ការជជែកអំពីរូបភាព និងរឿងនិទាន " រាងកាយរបស់យើង "........................................៦៩

- **ឈុតសកម្មភាពទី៣:** ការស្វាគមន៍គ្នា ការជជែកអំពីរូបភាព និងរឿងនិទាន............................៧០

ៜ ។ការស្វាគមន៍គ្នា....................................................................................................៧០

ៜ ។ការជជែកអំពីរូបភាព និងរឿងនិទាន "រាងកាយរបស់យើង "..........................................៧១

- **ឈុតសកម្មភាពទី៤:** ការរៀនលេខ ការប្រកបចំនួន ការជជែកអំពីរូបភាព និងរឿងនិទាន..........៧២

ៜ ។ការរៀនលេខ និងការប្រកបលេខ...............................................................................៧២

ៜ ។ការជជែកអំពីរូបភាព និងរឿងនិទាន " រាងកាយរបស់យើង"..........................................៧៤

***មេរៀនទី៨: តើប្អូនៗកំពុងធ្វើអ្វី?......................................................................................៧៥***

- **ឈុតសកម្មភាពទី១:** ការនិយាយអំពីប្រធានបទជាភាសាកំណើតរបស់កុមារ..........................៧៦
- **ឈុតសកម្មភាពទី២:** ការនិយាយអំពីរូបភាពជាភាសាកំណើតរបស់កុមារ...............................៧៦
- **ឈុតសកម្មភាពទី៣:** ការនិយាយអំពីរូបភាពជាភាសាខ្មែរ ( ផ្ទាល់មាត់)............... ................៧៧
- **ឈុតសកម្មភាពទី៤:** ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ.................................៧៨
- **ឈុតសកម្មភាពទី៥:**ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ និងការទស្សន៍ទាយពាក្យ.៧៨
- **ឈុតសកម្មភាពទី៦:**ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ និងការសម្តែងតួអំពីរឿង និទាន.......................................................................... ..................................៧៩
- **ឈុតសកម្មភាពទី៧:** ការប្រើភាសាខ្មែរធ្លាប់ស្គាល់ជាទម្រង់នៃការសន្ទនា................................៨០

# កម្មវិធីសិក្សាភាសាខ្មែរបន្ថែម (SKL)

## ឆ្នាំសិក្សា២០០៦-២០០៧

## ថ្នាក់ទី១

| ខែ | សប្តាហ៍ | មេរៀន/ប្រធានបទ | កំណត់សម្គាល់ |
|---|---|---|---|
| តុលា | ១ | **មេរៀនទី១: តោះចូរចាប់ផ្តើមរៀនភាសាខ្មែរ**<br>ឈុតសកម្មភាពទី១: ចំរៀង/កំណាព្យ/មេសូត្រ និងការជជែកអំពីរូបភាព | |
| | ២ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព | |
| | ៣ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព | |
| | ៤ | ឈុតសកម្មភាពទី៤: ចំនួន និងការជជែកអំពីរូបភាព | |
| វិច្ឆិកា | ១ | **មេរៀនទី២: តោះចូរបន្តរៀនភាសាខ្មែរ**<br>ឈុតសកម្មភាពទី១: ចំរៀង និងការជជែកអំពីរូបភាព | |
| | ២ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព | សិក្ខាសាលា១ថ្ងៃ |
| | ៣ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព | |
| | ៤ | ឈុតសកម្មភាពទី៤: ការរៀនលេខ ការប្រកបចំនួន និងការជជែកអំពីរូបភាព | |
| ធ្នូ | ១ | **មេរៀនទី៣: បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ**<br>ឈុតសកម្មភាពទី១: ចំរៀង និងការជជែកអំពីរូបភាព | |
| | ២ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព | |
| | ៣ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព | |
| | ៤ | ឈុតសកម្មភាពទី៤: ការរៀនលេខ ការប្រកបចំនួន និងការជជែកអំពីរូបភាព | សិក្ខាសាលា១ថ្ងៃ |
| មករា | ១ | **មេរៀនទី៤: ការរៀនអំពីសត្វ**<br>ឈុតសកម្មភាពទី១: ចំរៀង និងការជជែកអំពីរូបភាព | |
| | ២ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព | |
| | ៣ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា និងការជជែកអំពីរូបភាព | |
| | ៤ | ឈុតសកម្មភាពទី៤: ការរៀនលេខ ការប្រកបចំនួន និងការជជែកអំពីរូបភាព | |
| កុម្ភៈ | ១ | **មេរៀនទី៥: តើនរណាស្លៀកខោជើងខ្លីនៅថ្ងៃនេះ?**<br>ឈុតសកម្មភាពទី១: ចំរៀង តារាងរូបភាព និងរឿងនិទាន | |
| | ២ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន តារាងរូបភាព និងរឿងនិទាន | សិក្ខាសាលា១ថ្ងៃ |
| | ៣ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា តារាងរូបភាព និងរឿងនិទាន | |
| | ៤ | ឈុតសកម្មភាពទី៤: ការរៀនលេខ ការប្រកបលេខ តារាងរូបភាព<br>និងរឿងនិទាន | |

| | | | |
|---|---|---|---|
| **មីនា** | ១ | **មេរៀនទី៦: មិត្តសំលាញ់របស់ខ្ញុំ**<br>ឈុតសកម្មភាពទី១: ចំរៀង ការជជែកអំពីរូបភាព និងរឿងនិទាន | |
| | ២ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន ការជជែកអំពីរូបភាព និងរឿងនិទាន | |
| | ៣ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា ការជជែកអំពីរូបភាព និងរឿងនិទាន | |
| | ៤ | ឈុតសកម្មភាពទី៤: ការរៀនលេខ ការប្រកបចំនួន ការជជែកអំពីរូបភាព និងរឿងនិទាន | សិក្ខាសាលា១ថ្ងៃ |
| **មេសា** | ១ | **មេរៀនទី៧: រាងកាយរបស់យើង**<br>ឈុតសកម្មភាពទី១: ចំរៀង ការជជែកអំពីរូបភាព និងរឿងនិទាន | |
| | ៤ | ឈុតសកម្មភាពទី២: បទបញ្ជាក្នុងថ្នាក់រៀន ការជជែកអំពីរូបភាព និងរឿងនិទាន | |
| **ឧសភា** | ១ | ឈុតសកម្មភាពទី៣: ការស្វាគមន៍គ្នា ការជជែកអំពីរូបភាព និងរឿងនិទាន | |
| | ២ | ឈុតសកម្មភាពទី៤: ការរៀនលេខ ការប្រកបចំនួន ការជជែកអំពីរូបភាព និងរឿងនិទាន | |
| | ៣ | **មេរៀនទី៨: តើប្អូនៗកំពុងធ្វើអ្វី?**<br>ឈុតសកម្មភាពទី១: ការនិយាយអំពីប្រធានបទជាភាសាកំណើតរបស់កុមារ | |
| | ៤ | ឈុតសកម្មភាពទី២: ការនិយាយអំពីរូបភាពជាភាសាកំណើតរបស់កុមារ | សិក្ខាសាលា១ថ្ងៃ |
| **មិថុនា** | ១ | ឈុតសកម្មភាពទី៣: ការនិយាយអំពីរូបភាពជាភាសាខ្មែរ (ផ្ទាល់មាត់) | |
| | ២ | ឈុតសកម្មភាពទី៤: ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ | |
| | ៣ | ឈុតសកម្មភាពទី៥: ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ និងការទស្សន៍ទាយពាក្យ | |
| | ៤ | ឈុតសកម្មភាពទី៦: ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ និងការសម្តែងតួអំពីរឿងនិទាន | |
| កក្កដា | ១ | ឈុតសកម្មភាពទី៧: ការប្រើភាសាខ្មែរធ្លាប់ស្គាល់ជាទម្រង់នៃការសន្ទនា | |
| | ២ | រំលឹកសកម្មភាពមួយចំនួននៅក្នុងមេរៀនទី១ ទី២ និងទី៣ | សិក្ខាសាលា១ថ្ងៃ |
| | ៣ | រំលឹកសកម្មភាពមួយចំនួននៅក្នុងមេរៀនទី៤ ទី៥ និងទី៦ | |
| | ៤ | រំលឹកសកម្មភាពមួយចំនួននៅក្នុងមេរៀនទី៧ និងទី៨ | |

# មេរៀនទី១ តោះចូរចាប់ផ្តើមរៀនភាសាខ្មែរ



## គោលបំណងមេរៀន

**សិស្សនៅថ្នាក់ទី១នឹងរៀនៈ**

- ចំរៀង/កំណាព្យ/មេសូត្រជាភាសាខ្មែរ
- ភាសាបទបញ្ជាក្នុងថ្នាក់រៀន
- ភាសាស្វាគមន៍ និងការណែនាំឱ្យស្គាល់គ្នា
- ចំនួនពី ១-១០
- សម្លេងព្យញ្ជនៈ "អ" ខ្លះ

## ធនធានសម្រាប់បង្រៀន

**សម្ភារមានៈ**

- រូបភាព និងការសន្ទនា- *គ្រូ និងសិស្ស*
- ប័ណ្ណរូបភាពសម្រាប់រៀនអំពីចំនួន
- រូបភាពសាលារៀន

ចូរបែងចែកពេលវេលាដើម្បីធ្វើសកម្មភាពខ្លីៗពីឃុតសកម្មភាពទាំង៤ខាងក្រោម ។

ចូរព្យាយាមធ្វើសកម្មភាពខុសៗគ្នា៤ឬ៥នៅក្នុងមេរៀនរយៈពេលមួយម៉ោងរបស់លោកគ្រូ/អ្នកគ្រូ

## ឈុតសកម្មភាពទី១ ចំរៀង/កំណាព្យ/មេសូត្រ និងការជជែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

**I. មេសូត្រ:** (បទកាកគតិឬបទពាក្យបួន)

*នៅក្នុងទីធ្លា ជ្រូកមាន់ក្ងានទា ខ្លះស៊ីខ្លះចឹក*
*ដណ្តើមចំណី ខ្លះឆីខ្លះផឹក ស៊ីឆ្អែតឈប់នឹក*
*នាំគ្នាដើរចេញ ។*

១. ចូរជ្រើសរើសចំរៀង/កំណាព្យ/មេសូត្រមួយបទសម្រាប់បង្រៀន ហើយនិយាយឬច្រៀងទៅកាន់សិស្ស ។ សិស្សស្តាប់ និងនិយាយតាមលោកគ្រូ/អ្នកគ្រូ បន្ទាប់មកច្រៀងចំរៀងនោះម្តងទៀត ។

២. ចូរនិយាយបន្ទាត់នីមួយៗរបស់ចំរៀង/កំណាព្យ/មេសូត្រទៅកាន់សិស្ស ។ សិស្សស្តាប់ និងនិយាយបន្ទាត់នីមួយៗឡើងវិញ ។

៣. ចូរសួរសំណួរដល់សិស្សអំពីចំរៀង/កំណាព្យ/មេសូត្រ ។ **"តើចំរៀង/កំណាព្យ/មេសូត្រនេះនិយាយអំពីអ្វី?" "តើវារៀបរាប់អំពីទុក្ខព្រួយឬសេចក្តីសប្បាយ?"** ។ល ។

៤. ចូរឱ្យសិស្សគូររូបភាពអំពីចំរៀង/កំណាព្យ/មេសូត្រនោះ បន្ទាប់មកហៅពួកគេឱ្យនិយាយអំពីរូបគំនូររបស់ពួកគេទៅកាន់សិស្សនៅក្នុងថ្នាក់រៀន ។

៥. ចូរចែកថ្នាក់ជាពីរក្រុម ។ ក្រុមទី១ច្រៀង/និយាយចំរៀង/កំណាព្យ/មេសូត្រពាក់កណ្តាលដំបូង ។ ក្រុមទីពីរ ច្រៀង/និយាយចំរៀង/កំណាព្យពាក់កណ្តាលចុងក្រោយ ។ បន្ទាប់មកក្រុមទាំងមូលច្រៀងម្តងទៀតទាំង អស់គ្នា ។

៦. ចូរសរសេរពាក្យចំរៀង/កំណាព្យលើផ្ទាំងក្រដាសធំ ហើយដាក់ទៅលើជញ្ជាំង បន្ទាប់មកអានឱ្យសិស្សស្តាប់ ។ ចូរប្រើរំពាត់ចង្អុលពាក្យនានា ។ សិស្សមើល និងស្តាប់ បន្ទាប់មកនិយាយតាមលោកគ្រូ/ អ្នកគ្រូ ។

៧. ចូរហាត់អនុវត្តជារៀងរាល់ថ្ងៃ ។

## II. ការជជែកអំពីរូបភាព: "សាលារៀនរបស់ខ្ញុំ "

**បញ្ជីពាក្យជាភាសាខ្មែរ**

| | | |
|---|---|---|
| សាលារៀន | ដើមឈើ | នៅពីមុខ |
| ដងទង់ជាតិ | សួនច្បារ | នៅខាងក្រោយ |
| របងសាលារៀន | សួនបន្លែ | នៅជាប់នឹង |
| បង្គន់ | អណ្តូងទឹក | នៅក្បែរ |
| ខ្លោងទ្វារ | ធុងសម្រាម | នៅខាងក្រោម |
| ទ្វាររបង | បង្អួច | |
| អាគារ | ទ្វារ | |



១. ចូរសួរសំណួរជាភាសាកំណើតរបស់សិស្សអំពីរូបភាព

| សំណួរ | ឧទាហរណ៍ចម្លើយ |
|---|---|
| តើនេះជារូបភាពអ្វី? | សាលារៀន? ផ្ទះ? |
| តើសាលារៀននេះមានប៉ុន្មានអាគារ? | ១? ២? |
| តើមានដើមឈើប៉ុន្មានដើម? | ២? ៣? |
| តើបង្គន់នៅឯណា? | ក្រោយសាលារៀន? ក្បែរសួនបន្លែ? |
| តើមានដងទង់ជាតិឬទេ? ហើយវាស្ថិតនៅឯណា? | មាន នៅពីមុខថ្នាក់? |
| តើមានអណ្តូងទឹកឬទេ? | មាន? |
| តើធុងសម្រាមស្ថិតនៅឯណា? | នៅក្រោមដើមឈើ? |
| តើសាលារៀននេះមានរបងឬទេ? | មាន? |
| តើសួនច្បារស្ថិតនៅកន្លែងណាខ្លះ? | ក្រោមដងទង់ជាតិ ក្បែររបងសាលារៀន |

២. ចូរប្រាប់សិស្សអំពីរូបភាពជាភាសាកំណើតរបស់សិស្ស

**នេះជាសាលាបឋមសិក្សា។**

**នេះជាអណ្តូងទឹក។ វាស្ថិតនៅក្បែរសួនបន្លែ។**

**នេះជាបង្គន់។ វាស្ថិតនៅក្រោយសាលារៀន។**

**នេះជាដងទង់ជាតិ។ វាស្ថិតនៅមុខថ្នាក់រៀន។**

**នេះជាសួនបន្លែ។**

**នេះជាសួនច្បារ។ វាស្ថិតនៅជាប់របងសាលារៀន។**

៣. ចូប្រាប់សិស្សអំពីរូបភាព ម្តងនេះប្រើភាសាខ្មែរម្តង។ លោកគ្រូ/អ្នកគ្រូអាចប្រើភាសាកំណើតរបស់សិស្សបាន បើសិនជា សិស្សពុំយល់។

## ឈុតសកម្មភាពទី២ បទបញ្ហាក្នុងថ្នាក់រៀន និងការចែករំលែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

## I. បទបញ្ជាក្នុងថ្នាក់រៀនៈ

ឧទាហរណ៍ៈ



<u>សូមក្រោកឈរឡើង</u>



<u>សូមអង្គុយចុះ</u>



<u>សូមប្អូនៗលើកដៃឡើង</u>

<u>សូមឈប់ជជែកគ្នា</u>

<u>សូមស្តាប់</u>



<u>សូមយកក្តារឆ្នួន និងដីសរបស់ប្អូនៗចេញមក</u>

១. ចូរណែនាំឱ្យសិស្សស្គាល់អំពីបទបញ្ជាក្នុងថ្នាក់រៀនជាភាសាកំណើតរបស់សិស្ស។ ចូរធ្វើបង្ហាញសិស្ស។ សិស្សត្រូវមើល និងស្តាប់។ សិស្សត្រូវធ្វើតាមគំរូរបស់លោកគ្រូ/អ្នកគ្រូ។

២. នៅលើកនេះ ចូរណែនាំបទបញ្ជាដូចគ្នានេះជាភាសាខ្មែរ។ ចូរធ្វើគំរូឱ្យសិស្សមើល។ ចូរសួរសិស្ស **"តើយើងនិយាយយ៉ាងដូចម្តេចជាភាសាកំណើតរបស់សិស្ស?"**។

៣. ចូរហាត់ធ្វើបទបញ្ជាថ្មីមួយជារៀងរាល់ថ្ងៃ។ ណែនាំឱ្យសិស្សស្គាល់ជាភាសាពួកគេនៅលើកដំបូង។ ធ្វើគំរូឱ្យសិស្សមើល។ បង្ហាញបទបញ្ជានេះម្តងទៀតដល់សិស្សដោយនិយាយជាភាសាខ្មែរ។ ធ្វើគំរូឱ្យសិស្សមើល។

៤. ចូរផ្តល់បទបញ្ជា២ឬ៣ ជាភាសាខ្មែរ។ សិស្សស្តាប់ និងធ្វើតាមបទបញ្ជានីមួយៗ។

៥. ចូរសម្តែងតួអំពីការផ្តល់បទបញ្ជា។ ហៅសិស្សឱ្យនិយាយបទបញ្ជាជាភាសាខ្មែរ។

៦. សិស្សត្រូវជ្រើសរើសបទបញ្ជាមួយ និងផ្តល់បទបញ្ជានោះទៅកាន់សិស្សដទៃទៀតនៅក្នុងថ្នាក់ដោយប្រើភាសាខ្មែរ។ សិស្សទាំងឡាយត្រូវធ្វើតាមឱ្យបានត្រឹមត្រូវ។

៧. ចូរចែកថ្នាក់រៀនជាក្រុមតូចៗ។ សិស្សម្នាក់ៗសម្តែងតួផ្តល់បទបញ្ជាដល់ក្រុម។ សមាជិកក្រុមត្រូវទាយ បទបញ្ជា និងនិយាយតើវាជាអ្វី។

៨. សិស្សគូររូបភាពឱ្យត្រូវគ្នានឹងបទបញ្ជានីមួយៗ។ សិស្សបង្ហាញគំនូរពួកគេទៅកាន់សិស្សក្នុងថ្នាក់។ ហើយសិស្សទាំងនោះធ្វើការទស្សន៍ទាយបទបញ្ជាឱ្យត្រូវគ្នានឹងរូបភាព។

## II. ការផ្ជែកអំពីរូបភាពនិងរឿងនិទាន "សាលារៀនរបស់ខ្ញុំ"

**សាលារៀនរបស់ខ្ញុំ**

នេះជាសាលារៀនរបស់ខ្ញុំ។ សាលារៀននេះមានពីរអាគារ។ នៅក្នុងសាលារៀនរបស់ខ្ញុំមានវត្ថុផ្សេងៗជាច្រើនទៀត។ មានដើមឈើ២ដើម។ មានអណ្តូងទឹកមួយនៅក្បែរសួនច្បារ។ មានដងទង់ជាតិនៅខាងមុខថ្នាក់រៀន និងបង្គន់នៅខាងក្រោយថ្នាក់រៀន។ មានសួនផ្កា ធុងសម្រាម ខ្លោងទ្វារ។ មានទីធ្លាស្រស់ស្អាតនិងមានរបងព័ទ្ធជុំវិញសាលារៀន។ ខ្ញុំចូលចិត្តសាលារៀនរបស់ខ្ញុំខ្លាំងណាស់។



១. ចូរបង្ហាញរូបភាពដល់សិស្សហើយសួរសំណួរជាភាសាខ្មែរអំពីរូបភាពនោះ។

| សំណួរ | ឧទាហរណ៍ចម្លើយ |
|---|---|
| តើនេះជារូបភាពអ្វី? | សាលារៀន? ផ្ទះ? |
| តើសាលារៀននេះមានប៉ុន្មានអាគារ? | ១? ២? |
| តើមានដើមឈើប៉ុន្មានដើម? | ២? ៣? |
| តើបង្គន់នៅឯណា? | ក្រោយសាលារៀន? ក្បែរសួនបន្លែ? |
| តើមានដងទង់ជាតិឬទេ? ហើយវាស្ថិតនៅឯណា? | មាន នៅពីមុខថ្នាក់? |
| តើមានអណ្តូងទឹកឬទេ? | មាន? |
| តើធុងសម្រាមស្ថិតនៅឯណា? | នៅក្រោមដើមឈើ? |
| តើសាលារៀននេះមានរបងឬទេ? | មាន? |
| តើសួនច្បារស្ថិតនៅកន្លែងណាខ្លះ? | ក្រោមដងទង់ជាតិ/ក្បែររបងសាលារៀន? |

២. ចូរបង្ហាញរូបភាពហើយសួរសិស្សជាភាសាខ្មែរ *"តើមានអ្វីផ្សេងទៀតដែលប្អូនអាចមើលឃើញ?"* *(ទ្វារ របង កូនរុក្ខជាតិ ផ្កា ខ្លោងទ្វារ...)* ។ ឱ្យសិស្សគូររូបនៅក្នុងរូបភាពដាក់លើក្តារឆ្នួន។ ឧទាហរណ៍: ដើមឈើ ដងទង់ជាតិ។ សួរសិស្សជាភាសាខ្មែរ *"តើនេះជាអ្វី?* *(នេះជាដងទង់ជាតិ)*។ សិស្សឡើងទៅខាងមុខថ្នាក់ ហើយនិយាយប្រាប់ពីគំនូររបស់គេដោយផ្តល់ប្រយោគគំរូដែលផ្តើមដោយ *"ខ្ញុំបានគូររូបដងទង់ជាតិ"*។

៤. ចូរបិទរូបភាពលើក្តារខៀន ហើយអានរឿងឱ្យសិស្សស្តាប់ជាភាសាខ្មែរ។ សិស្សគ្រាន់តែស្តាប់ និងមើលរូបភាពប៉ុណ្ណោះ។

## ឈុតសកម្មភាពទី៣ ការស្វាគមន៍ថ្នា និងការចែកអំពីរូបភាព

**ចូរជ្រើសរើសវិធានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការស្វាគមន៍ថ្នា:

ឧទាហរណ៍៖ **អរុណសួស្តី ។ តើសំឡាញ់សុខសប្បាយឬទេថ្ងៃនេះ? (ខ្ញុំសុខសប្បាយជាទេ សូមអរគុណ)**
**សាយ័ណសួស្តី ។**

១. ចូរណែនាំឱ្យស្គាល់អំពីការស្វាគមន៍គ្នាជាភាសាខ្មែរ ។ សិស្សត្រូវនិយាយឡើងវិញតាមលោកគ្រូ/ អ្នកគ្រូ ។
២. ចូរនិយាយពាក្យស្វាគមន៍ ។ សិស្សត្រូវឆ្លើយតបឱ្យបានសមរម្យ ។
៣. សិស្សសម្តែងតួជាគូ ដោយធ្វើជាគ្រូ និងសិស្ស /សិស្ស និងសិស្ស ។

## ការប្រើរូបភាព



៤. ចូរប្រើរូបភាពហើយសួរសំណួរជាភាសាកំណើតរបស់សិស្ស។ "**តើមនុស្សទាំងនេះជានរណា?**" "**តើពួកគេនៅឯណា?**" "**តើស្ត្រីម្នាក់នោះកំពុងនិយាយអ្វីខ្លះទៅកាន់សិស្ស?**" ។ ល ។
៥. ចូរប្រើរូបភាព ហើយធ្វើសកម្មភាពដូចគ្នានឹងលើកមុន ប៉ុន្តែត្រូវប្រើភាសាខ្មែរតែប៉ុណ្ណោះ ។
៦. ចូរប្រើភាសាកំណើតរបស់សិស្សដើម្បីប្រាប់សិស្សអំពីវត្ថុផ្សេងៗនៅក្នុងរូបភាព ។ "**នេះជាក្តារខៀន/ទូ/គ្រូបង្រៀន**" ។ ល ។ ចូរសួរសិស្ស "**តើនេះជាអ្វី?**" (វាជាក្តារខៀន) ។ ល ។
៧. ចូរធ្វើសកម្មភាពដូចលើកមុន ប៉ុន្តែត្រូវប្រើតែភាសាខ្មែរប៉ុណ្ណោះ ។
៨. ចូរប្រើរូបភាព ហើយអានការសន្ទនាឱ្យសិស្សស្តាប់២ឬ៣ដង ។ សិស្សស្តាប់ ។

<u>គ្រូ</u> អរុណសួស្តីមីរ៉ា ។ តើប្អូនសុខសប្បាយឬទេថ្ងៃនេះ?
<u>សិស្ស</u> សុខសប្បាយណាស់ សូមអរគុណអ្នកគ្រូ ។ តើអ្នកគ្រូសុខសប្បាយឬទេថ្ងៃនេះ?
<u>គ្រូ</u> សុខសប្បាយណាស់ សូមអរគុណប្អូន ។
តើអ្នកគ្រូអាចជួយកិច្ចការធ្វើនៅផ្ទះរបស់ប្អូនបានឬទេ?
<u>សិស្ស</u> ចាស៎ អ្នកគ្រូ ។

៩. ចូរប្រើរូបភាព និងការសន្ទនាម្តងទៀត ។ ចូរនិយាយការសន្ទនាហើយឱ្យសិស្សនិយាយតាមលោកគ្រូ/ អ្នកគ្រូ
១០. ចូរសម្តែងការសន្ទនាជាមួយសិស្សក្នុងថ្នាក់ ។ លោកគ្រូ/អ្នកគ្រូសម្តែងតួជាគ្រូ សិស្សសម្តែងតួជាសិស្ស ។
១១. ចូរបែងចែកសិស្សក្នុងថ្នាក់ជាពាក់កណ្តាល ។ សិស្សពាក់កណ្តាលសម្តែងតួធ្វើជាគ្រូ និងពាក់កណ្តាលទៀតសម្តែងតួជាសិស្ស ។

## II. ការចែករំលែកគ្នាអំពីរូបភាពនិងរឿងនិទាន៖ "សាលារៀនរបស់ខ្ញុំ "

**សាលារៀនរបស់ខ្ញុំ**

នេះជាសាលារៀនរបស់ខ្ញុំ ។ សាលារៀននេះមានពីរអាគារ ។
នៅក្នុងសាលារៀនរបស់ខ្ញុំមានវត្ថុផ្សេងៗជាច្រើនទៀត ។
មានដើមឈើ២ដើម ។ មានអណ្តូងទឹកមួយនៅក្បែរសួនច្បារ ។
មានដងទង់ជាតិនៅខាងមុខថ្នាក់រៀន និងបង្គន់នៅខាងក្រោយ



១. ចូរអានរឿងខាងលើឱ្យសិស្សស្តាប់ចំនួន២ដង។ បន្ទាប់មកចង្អុលវត្ថុផ្សេងៗក្នុងរូបភាព ហើយប្រាប់សិស្សជាភាសាខ្មែរ។ ឧទាហរណ៍ៈ "នេះជាងណ្តូងទឹក" "នេះជាដងទង់ជាតិ"។ បន្ទាប់មកចង្អុលទៅកន្លែងផ្សេងទៀតនៅក្នុងរូបភាពដោយសួរថា "តើនេះជាអ្វី?"(សួនបន្លែ)។ល។

២. ចូររំលឹកពាក្យថ្មីដើម្បីធ្វើតេស្តការចងចាំរបស់សិស្ស ដោយបង្ហាញរូបភាពដល់សិស្សមួយភ្លែត ហើយសួរសំណួរ "តើនេះជាអ្វី?" (អណ្តូងទឹក ដងទង់ជាតិ។ល។ គ្របរូបភាព ហើយឱ្យសិស្សធ្វើការជាគូ និងចងចាំអ្វីដែលមាននៅក្នុងរូបភាពឱ្យបានច្រើនតាមដែលអាចធ្វើបាន។ គ្រូសរសេរចម្លើយសិស្ស បន្ទាប់មកបើក រូបភាព ហើយពិនិត្យមើលថាតើមានចម្លើយប៉ុន្មានដែលត្រឹមត្រូវ។

៣. ចូរអានរឿងឱ្យសិស្សស្តាប់ ហើយឱ្យសិស្សទះដៃនៅពេលដែលឮគ្រូអានពាក្យ "សាលារៀន"។ បន្ទាប់មកអានរឿងម្តងទៀតដោយប្រាប់សិស្សថា "ចូររាប់ចំនួនដងនៅពេលដែលអ្នកឮពាក្យថា "សាលារៀន" នៅក្នុងរឿងនិទាន។(៥ដង)។

## ឈុតសកម្មភាពទី៤ ចំនួន និងការជជែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍ៈ សកម្មភាព៤ឬ៥ដំបូង)**

**I. ចំនួនៈ**

ប័ណ្ណរូបភាពសម្រាប់រៀនចំនួន

| | |
|---|---|
| ១<br>មួយ | សាលារៀន |
| ២<br>ពីរ | សិស្សា |
| ៣<br>បី | ដុំដីស |
| ៤<br>បួន | សិស្សី |
| ៥<br>ប្រាំ | ខ្មៅដៃ |

| | |
|---|---|
| ៦<br>ប្រាំមួយ | ក្ដារឆ្នួន |
| ៧<br>ប្រាំពីរ | សៀវភៅ |
| ៨<br>ប្រាំបី | គ្រូបង្រៀន |
| ៩<br>ប្រាំបួន | សំពៀត<br>សៀវភៅ |
| ១០<br>ដប់ | សិស្ស |

១. ចូរប្រើប័ណ្ណរូបភាពពី ១-១០។ ត្រូវបង្ហាញតែប័ណ្ណរូបភាពប៉ុណ្ណោះហើយប្រាប់សិស្សថា "នេះគឺជាសាលារៀន ១ខ្នង/សិស្សា ២ នាក់ ។ល ។

២. ចូរប្រើប័ណ្ណរូបភាពម្ដងទៀត ហើយសួរសិស្សថា **"តើប្អូនៗមើលឃើញអ្វីខ្លះ?"** (សាលារៀនមួយខ្នង)។ **តើមានសាលារៀនប៉ុន្មាន?** (១)" ។ល។ លោកគ្រូ/អ្នកគ្រូសួរសំណួររហូតគ្រប់ប័ណ្ណរូបភាពទាំងអស់ ។

៣. ចូរលើកប័ណ្ណរូបភាពខុសៗគ្នាឡើងហើយសួរសិស្សថា **"តើមាន .....ប៉ុន្មានដែលប្អូនមើលឃើញ?"** ។

៤. ចូរនិយាយទៅកាន់សិស្សថា **"ចូរប្អូនបង្ហាញខ្មៅដៃ៤ដើមដល់អ្នកគ្រូ/លោកគ្រូ"** ។ សិស្សគួរតែលើកខ្មៅដៃ ៤ដើមឡើង ។ **"ចូរបង្ហាញសំពៀតសៀវភៅ៣ ដល់អ្នកគ្រូ/លោកគ្រូ"** ។ ល ។

៥. ចូរបង្ហាញប័ណ្ណចំនួននិងចង្អុលទៅលេខខ្មែរ ។ បន្ទាប់មកចង្អុលពាក្យខ្មែរព្រមទាំងនិយាយពាក្យនោះផង ។ ចំណែកសិស្ស ត្រូវនិយាយឡើងវិញតាមលោកគ្រូ/អ្នកគ្រូ ។

៦. ចូរហ្វឹកហាត់ចំនួនទាំងអស់ពី ១ដល់១០ ។

៧. ចូរលើកប័ណ្ណចំនួនខុសៗគ្នាឡើងហើយសួរសិស្សថា **"តើនេះជាចំនួនប៉ុន្មាន?"** ។

៨. ចូរដាក់ប័ណ្ណចំនួនទាំងអស់ពី១ដល់៥លើក្ដារខៀន ដោយកុំឱ្យត្រូវតាមលំដាប់លំដោយ ។ បន្ទាប់មកឱ្យសិស្ស ឡើងរៀបលំដាប់លេខនោះឱ្យបានត្រឹមត្រូវ ។ ត្រូវធ្វើសកម្មភាពដូចគ្នានេះចំពោះចំនួនពី៦ដល់១០ ។ និងបន្ទាប់ មកទៀតធ្វើសកម្មភាពដដែលចំពោះចំនួនពី ១ដល់១០ ។

៩. ចូរដាក់ប័ណ្ណរូបភាព និងប័ណ្ណចំនួនលើក្ដារខៀន ហើយឱ្យសិស្សផ្គូរផ្គងប័ណ្ណរូបភាព និងចំនួននោះឱ្យត្រូវគ្នា ។

## II. ការថែកអំពីរូបភាពនិងរឿងនិទានៈ "សាលារៀនរបស់ខ្ញុំ "

**សាលារៀនរបស់ខ្ញុំ**

នេះជាសាលារៀនរបស់ខ្ញុំ ។ សាលារៀននេះមានពីរអាគារ ។ នៅក្នុងសាលារៀនរបស់ខ្ញុំមានវត្ថុផ្សេងៗជាច្រើនទៀត ។ មានដើមឈើ២ដើម ។ មានអណ្តូងទឹកមួយនៅក្បែរសួនច្បារ ។ មានដងទង់ជាតិនៅខាងមុខថ្នាក់រៀន និងបង្គន់នៅខាងក្រោយថ្នាក់រៀន ។ មានសួនផ្កា ធុងសម្រាម ក្លោងទ្វារ ។ មានទីធ្លាស្រស់ស្អាតនិងមានរបងព័ទ្ធជុំវិញសាលារៀន ។ ខ្ញុំចូលចិត្តសាលារៀនរបស់ខ្ញុំខ្លាំងណាស់ ។



១. ចូរអានរឿងឱ្យសិស្សស្តាប់ចំនួន២ដង ។ ក្នុងខណៈពេលអានលើកទី២ លោកគ្រូ/អ្នកគ្រូត្រូវឈប់ផ្អាកម្តងម្កាលដើម្បីឱ្យសិស្សនិយាយពាក្យបន្ទាប់ ឧទាហរណ៍: "នេះជា..........របស់ខ្ញុំ ។ នៅក្នុងសាលារៀននេះមានពីរ............ ។

២. ចូរសួរសំណួរដល់សិស្សជាភាសាខ្មែរអំពីសាលារៀនរបស់ពួកគេផ្ទាល់ ។

| សំណួរ | ឧទាហរណ៍ចម្លើយ |
|---|---|
| តើសាលារៀនរបស់ប្អូនមានអណ្តូងទឹកឬទេ?តើវាស្ថិតនៅកន្លែងណា? | មាន ក្រោយសាលារៀន? |
| តើសាលារៀនរបស់ប្អូនមានដងទង់ជាតិឬទេ?តើវាស្ថិតនៅកន្លែងណា? | មាន មុខថ្នាក់រៀន? |
| តើសាលារៀនរបស់ប្អូនមានបង្គន់ឬទេ?តើវាស្ថិតនៅកន្លែងណា? | គ្មាន? |
| ។ល។ | |

៣. ចូរចែកក្រដាស និងខ្មៅដៃឱ្យសិស្ស ហើយឱ្យពួកគេគូររូបភាពអ្វីដែលមាននៅក្នុងសាលារៀនរបស់ ពួកគេ ។ បន្ទាប់មកឱ្យសិស្សពន្យល់ពីគំនូររបស់ពួកគេទៅកាន់សិស្សនៅក្នុងថ្នាក់រៀន ឧទាហរណ៍: "ខ្ញុំបានគូររូបភាពបង្គន់នៅខាងក្រោយថ្នាក់រៀន" ។ "ខ្ញុំបានគូរដើមឈើដែលមានធុងសម្រាមនៅខាងក្រោម" ។ល ។

# មេរៀនទី២ តោះចូលរៀនភាសាខ្មែរ



| **គោលបំណងមេរៀន** | **ធនធានសម្រាប់បង្រៀន** |
|---|---|
| **សិស្សនៅថ្នាក់ទី១ នឹងរៀន:** | **សម្ភារមាន:** |
| • ចំរៀង/កំណាព្យ/មេសូត្រជាភាសាខ្មែរ | • ប័ណ្ណរូបភាពសម្រាប់រៀនលេខ និងឈ្មោះចំនួន |
| • ភាសាបទបញ្ជានៅក្នុងថ្នាក់រៀន | • រូបភាព "គ្រូ និងសិស្ស" |
| • ភាសាស្វាគមន៍ និងការណែនាំឱ្យស្គាល់គ្នា | • រូបភាព "ទន្សាយ និងផ្លែចេក" និងរឿងនិទាន |
| • ចំនួនពី ១-១០ | |
| • ការជជែកអំពីរូបភាព | |

ចូរបែងចែកពេលវេលាដើម្បីធ្វើសកម្មភាពខ្លីៗពីឈុតសកម្មភាព ទាំង៤ខាងក្រោម ។

ចូរព្យាយាមធ្វើសកម្មភាពខុសៗគ្នា៤ឬ៥នៅក្នុងមេរៀនរយៈពេលមួយម៉ោងរបស់លោកគ្រូ/អ្នកគ្រូ

## ឈុតសកម្មភាពទី១ ចំរៀងនិងការជជែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

## I. ចំរៀង **"វិញ្ញាណទាំងប្រាំ"** (លំនាំបទជិះទូកលេងតាមដងគង្គា)

*ខ្ញុំមានមាត់សម្រាប់និយាយ ពេលសប្បាយចិត្តខ្ញុំច្រៀងលេង*
*ត្រចៀកពីរស្តាប់សូរសម្លេង ភ្នែកទាំងពីរសម្រាប់មើលគេ ។*
*ដៃទាំងពីរចាប់កាន់សំនេរ ជើងទាំងទ្វេសម្រាប់ឈរឈាន*
*ដឹងក្តៅត្រជាក់ដោយកាយវិញ្ញាណ ដូចនេះត្រូវមានអនាម័យជានិច្ច ។*

១. ចូរប្រើចំរៀងនេះជាគំរូមេរៀនដោយនិយាយឬច្រៀងទៅកាន់សិស្ស ។ សិស្សស្តាប់ និងនិយាយពាក្យឡើងវិញតាមលោកគ្រូ/អ្នកគ្រូ បន្ទាប់មកច្រៀងចំរៀងនេះម្តងទៀត ។
២. ចូរនិយាយចំរៀងក្នុងបន្ទាត់នីមួយៗឱ្យសិស្សស្តាប់ ។ សិស្សស្តាប់ និងនិយាយបន្ទាត់នីមួយៗឡើងវិញ ។ ចូរឱ្យសិស្សម្នាក់ៗនិយាយឡើងវិញបន្ទាប់ពីលោកគ្រូ/អ្នកគ្រូ ។
៣. ចូរសួរសំណួរអំពីចំរៀងដល់សិស្សថា **"តើចំរៀងនេះនិយាយអំពីអ្វី?"** **"តើវានិយាយអំពីទុក្ខព្រួយឬភាពសប្បាយ?"** ។ល ។
៤. ចូរឱ្យសិស្សគូររូបភាពអំពីចំរៀង បន្ទាប់មកហៅសិស្សឱ្យនិយាយអំពីរូបគំនូរពួកគេទៅកាន់សិស្សក្នុងថ្នាក់ ។
៥. ចូរបែងចែកសិស្សចេញជាពីរក្រុម ។ ក្រុមទី១ច្រៀងចំរៀងពាក់កណ្តាលដំបូង និងក្រុមទីពីរច្រៀងចំរៀងពាក់កណ្តាលទៀត ។ បន្ទាប់មកក្រុមទាំងមូលច្រៀងម្តងទៀតទាំងអស់គ្នា ។
៦. ចូរសរសេរពាក្យចំរៀងនៅលើផ្ទាំងក្រដាសធំហើយដាក់ទៅលើជញ្ជាំង បន្ទាប់មកអានឱ្យសិស្សស្តាប់ ។ ចូរប្រើរំពាត់ចង្អុលពាក្យទាំងនោះ ។ សិស្សមើល និងស្តាប់ បន្ទាប់មកនិយាយឡើងវិញតាមលោកគ្រូ/អ្នកគ្រូ ។
៧. ចូរហ្វឹកហាត់ជារៀងរាល់ថ្ងៃ ។

## II.ការផផែកអំពីរូបភាព: "សត្វទន្សាយនិងផ្លែចេក "






១. នៅក្នុងសកម្មភាពនេះមានរូបភាពចំនួនបួន។
ចូរសួរសំណួរទៅកាន់សិស្សអំពីរូបភាពនីមួយៗជាភាសាកំណើតរបស់សិស្ស។

| **សំណួរគ្រូ** | **ឧទាហរណ៍ចម្លើយ** |
|---|---|
| តើនរណានៅក្នុងរូបភាពនេះ? | លោកយាយម្នាក់ |
| តើគាត់កំពុងតែទូលអ្វី? | ល្អី |
| តើមានអ្វីនៅក្នុងល្អី? | ផ្លែឈើ/បន្លែ/របស់សម្រាប់បរិភោគ/អង្ករ |
| តើមានអ្វីទៀតដែលគាត់ដាក់នៅក្នុងល្អី? | សត្វស្លាប់/ទន្សាយ |
| តើទន្សាយកំពុងធ្វើអ្វីនៅក្នុងល្អី? | កំពុងស៊ី/កំពុងស៊ីចេក |
| តើលោកយាយដឹងថាទន្សាយកំពុងស៊ីរបស់នៅក្នុងល្អីគាត់ឬទេ? | ទេ/ប្រហែលជាដឹង/ទេ, គាត់គិតថាទន្សាយស្លាប់ហើយ |
| តើលោកយាយឃើញអ្វីនៅពេលគាត់ទៅដល់ផ្ទះ? | កាផាគាត់ទទេ/គាត់ពុំមានចេកឡើយ/គាត់ពុំមានទន្សាយឡើយ |

២. ចូរប្រើរូបភាពហើយប្រាប់សិស្សអំពីរូបភាពនោះដោយប្រើភាសាខ្មែរ។ ឧទាហរណ៍: **"នេះគឺជាល្អី/ទន្សាយ/ចេកខ្លះ/លោកយាយ"**។ ល។ ចូរចង្អុលវត្ថុផ្សេងៗនៅក្នុងរូបភាព និងសួរសិស្សថា **"តើនេះជាអ្វី?"**។ សិស្សត្រូវព្យាយាមឆ្លើយជាភាសាខ្មែរ។

៣. ចូរបង្ហាញរូបភាពហើយសួរសិស្សថា **"តើប្អូនៗអាចមើលឃើញវត្ថុផ្សេងៗអ្វីខ្លះ?"** (ទន្សាយមួយ, លោកយាយម្នាក់, ល្អីមួយ)។ ឥឡូវនេះចូរឱ្យសិស្សគូររូបវត្ថុពីក្នុងរូបភាពដាក់លើក្តារឆ្នួនពួកគេ (ឧ: ទន្សាយ)។ បន្ទាប់មកសួរសិស្សអំពីរូបគំនូរពួកគេជាភាសាខ្មែរ " **តើនេះជាអ្វី?**" (នេះជាទន្សាយមួយ)។ សិស្សអាចឡើងមកខាងមុខថ្នាក់ដើម្បីនិយាយអំពីអ្វីដែលពួកគេបានគូរ។ លោកគ្រូ/អ្នកគ្រូផ្តល់ប្រយោគគំរូដល់សិស្ស ។ ឧទាហរណ៍: **"ខ្ញុំបានគូររូបទន្សាយ មួយ ។ ខ្ញុំបានគូររូបផ្លែចេកខ្លះនៅក្នុងល្អី"**។ ល។

## ឈុតសកម្មភាពទី២ បទបញ្ហាក្នុងថ្នាក់រៀននិងការចែករំលែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ជំហ៊ុង)**

## I. បទបញ្ជាក្នុងថ្នាក់រៀនៈ

ឧទាហរណ៏

សូមក្រោកឈរឡើង



សូមអង្គុយចុះ



សូមលើកដៃប្អូនៗឡើង



សូមឈប់ជជែកគ្នា

សូមស្តាប់

សូមយកក្តារឆ្នួន និងដីសប្អូនៗចេញមក



១. ចូរណែនាំឱ្យសិស្សស្គាល់បទបញ្ជាក្នុងថ្នាក់រៀនថ្មីជាភាសាកំណើតរបស់សិស្ស។ ចូរធ្វើបង្ហាញសិស្ស។ សិស្សត្រូវមើល និង ស្តាប់ បន្ទាប់មកត្រូវធ្វើតាមគំរូរបស់លោកគ្រូ/អ្នកគ្រូ ។

២. នៅលើកនេះ ចូរណែនាំបង្ហាញបទបញ្ជាដូចគ្នា ប៉ុន្តែជាភាសាខ្មែរ។ ចូរធ្វើគំរូឱ្យសិស្សមើលហើយសួរសិស្សថា **"តើយើងនិយាយយ៉ាងដូចម្តេច ជាភាសាកំណើតរបស់សិស្ស?"** ។

៣. ចូរហាត់ផ្តល់បទបញ្ជាថ្មីមួយរៀងរាល់ថ្ងៃជាភាសារបស់ពួកគេ ដោយធ្វើគំរូឱ្យសិស្សមើល។ បន្ទាប់មក បង្ហាញបទបញ្ជានេះម្តងទៀតដល់សិស្សដោយនិយាយជាភាសាខ្មែរដោយធ្វើគំរូឱ្យសិស្សមើលផងដែរ។

៤. ចូរផ្តល់បទបញ្ជា២ឬ៣ជាភាសាខ្មែរ ដោយសិស្សស្តាប់ និងធ្វើតាមបទបញ្ជានីមួយៗ ។

៥. ចូរសម្តែងតួផ្តល់បទបញ្ជា ដោយហៅសិស្សឱ្យនិយាយបទបញ្ជានោះជាភាសាខ្មែរ ។

៦. ឱ្យសិស្សជ្រើសរើសបទបញ្ជាមួយ ហើយផ្តល់បទបញ្ជានោះទៅកាន់សិស្សដទៃទៀតនៅក្នុងថ្នាក់ដោយប្រើភាសាខ្មែរ។ សិស្សទាំងឡាយត្រូវធ្វើតាមឱ្យបានត្រឹមត្រូវ ។

៧. ចូរចែកថ្នាក់រៀនជាក្រុមតូចៗ ហើយសិស្សម្នាក់ៗសម្តែងតួផ្តល់បទបញ្ជាដល់ក្រុមរបស់ខ្លួន។ សមាជិកក្រុមត្រូវទាយបទបញ្ជា និងនិយាយ តើវាជាអ្វី? ។

៨. ឱ្យសិស្សគូររូបភាពឱ្យត្រូវគ្នាទៅនឹងបទបញ្ជានីមួយៗ។ បន្ទាប់មកឱ្យសិស្សបង្ហាញគំនូរពួកគេទៅកាន់សិស្សក្នុងថ្នាក់។ សិស្សទាំងឡាយធ្វើការទស្សន៏ទាយបទបញ្ជាឱ្យត្រូវគ្នានឹងរូបភាព ។

## II. ការជជែកអំពីរូបភាពនិងរឿងនិទានៈ "សត្វទន្សាយនិងផ្លែចេក "









១. ចូរបិទរូបភាពលើក្ដារខៀនហើយអានរឿងនិទានអំពីរូបភាពនោះឱ្យសិស្សស្ដាប់ ។ សិស្សគ្រាន់តែស្ដាប់ និង មើលទៅរូបភាពប៉ុណ្ណោះ ។

**សត្វទន្សាយនិងផ្លែចេក**

ថ្ងៃមួយ លោកយាយម្នាក់បានទូលល្អីមួយដែលមានផ្លែចេកពេញមកពីចម្ការរបស់គាត់។ សត្វទន្សាយបានឃើញផ្លែចេកក៏នឹកចង់ស៊ី ដូចនេះវាធ្វើពុតជាស្លាប់។ លោកយាយបានឃើញទន្សាយស្លាប់នៅតាមផ្លូវ។ គាត់ត្រេកអរណាស់ ហើយក៏រើសទន្សាយឡើងដាក់ក្នុងល្អីរបស់គាត់ដោយគិតថា គាត់នឹងយកវាទៅធ្វើម្ហូប។ នៅតាមផ្លូវទៅផ្ទះ ទន្សាយបានចាប់ផ្ដើមស៊ីផ្លែចេកនៅក្នុងល្អី។ លោកយាយពុំមានការសង្ស័យអ្វីឡើយ ពីព្រោះគាត់កំពុងតែគិតអំពី ថាតើត្រូវយកទន្សាយទៅស្លអ្វី។ ទន្សាយបានស៊ីចេកលោកយាយអស់ ហើយក៏លោតចេញពីល្អីរត់ចូលទៅក្នុងព្រៃបាត់ស្រមោល។ លោកយាយមកដល់ផ្ទះក៏ដាក់ល្អីរបស់គាត់ចុះ ហើយមើលទៅល្អី ស្រាប់តែទទេស្អាត។ លោកយាយមិនជឿថាមានរឿងនេះកើតឡើងឡើយ។ គាត់នឹកឆ្ងល់ថាតើចេក របស់គាត់នៅឯណា? តើទន្សាយនៅឯណា?

២. ចូរអានរឿងនិទានដូចគ្នានេះឱ្យសិស្សស្ដាប់ដោយចង្អុលទៅកាន់វត្ថុផ្សេងៗនៅក្នុងរូបភាពហើយប្រាប់សិស្សអំពីវត្ថុនោះជាភាសាខ្មែរ។ ឧទាហរណ៍: "**នេះជាសត្វទន្សាយ**" "**នេះជាល្អី**"។ ចូរចង្អុលវត្ថុផ្សេងៗនៅក្នុងរូបភាពដោយសួរថា "**តើនេះជាអ្វី?**" (ល្អី) "**តើនេះជានរណា?**" (លោកយាយម្នាក់) ។ល។

៣. រំលឹកវាក្យស័ព្ទថ្មីៗឡើងវិញដោយធ្វើតេស្តអំពីការចងចាំរបស់សិស្ស។ លោកគ្រូ/អ្នកគ្រូត្រូវបង្ហាញរូបភាពដល់សិស្សចំនួន២នាទី ហើយសួរសំណួរមួយចំនួន "**តើនេះគឺជាអ្វី?**" (ល្អី, សត្វទន្សាយ, លោកយាយម្នាក់។ ល។) បន្ទាប់មកលោកគ្រូ/អ្នកគ្រូគ្របរូបភាព និងឱ្យសិស្សធ្វើការជាគូធ្វើការចងចាំវត្ថុនៅក្នុងរូបភាពឱ្យបានច្រើនតាមតែអាចធ្វើបាន។ លោកគ្រូ/អ្នកគ្រូសរសេរគំនិតរបស់សិស្ស បន្ទាប់មកបើករូបភាពឡើងវិញដើម្បីផ្ទៀងផ្ទាត់ចម្លើយរបស់សិស្ស។

## ឈុតសកម្មភាពទី៣ ការស្វាគមន៍គ្នានិងការចំណែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការស្វាគមន៍គ្នា:

ឧទាហរណ៍: **អរុណសួស្ដី។ តើសំឡាញ់សុខសប្បាយឬទេ ថ្ងៃនេះ?** (ខ្ញុំសុខសប្បាយជាទេ សូមអរគុណ)
**សាយ័ណ្ហសួស្ដី ។**

១. ចូរណែនាំសិស្សឱ្យស្គាល់ការស្វាគមន៍គ្នាជាភាសាខ្មែរហើយសិស្សត្រូវនិយាយឡើងវិញតាមលោកគ្រូ/អ្នកគ្រូ ។

២. ចូរនិយាយពាក្យស្វាគមន៍។ សិស្សត្រូវឆ្លើយតបឱ្យបានសមរម្យ។

៣. សិស្សសម្តែងតួជាគូ ដោយធ្វើជាគ្រូ និងសិស្ស /សិស្ស និងសិស្ស ។

**ការប្រើរូបភាព**



៤. ចូរប្រើរូបភាព និងសួរសំណួរអំពីរូបភាពនោះជាភាសាកំណើតរបស់សិស្ស ឧទាហរណ៏ៈ " **តើមនុស្សទាំងនេះជានរណា?" "តើពួកគេនៅឯណា?" " តើស្រ្តីម្នាក់នោះកំពុងនិយាយអ្វីខ្លះទៅកាន់សិស្សី?"** ។ ល ។

៥. ចូរប្រើរូបភាពហើយធ្វើសកម្មភាពដូចគ្នានឹងលើកមុន ប៉ុន្តែត្រូវប្រើភាសាខ្មែរតែប៉ុណ្ណោះ ។

៦. ចូរប្រើភាសាកំណើតរបស់សិស្សដើម្បីប្រាប់សិស្សអំពីវត្ថុផ្សេងៗនៅក្នុងរូបភាព ឧទាហរណ៏ៈ " **នេះជាក្តារខៀន/ទូ/គ្រូ បង្រៀន"** ។ ល ។ បន្ទាប់មកសួរសិស្សថា " **តើនេះជាអ្វី?"** (វាជាក្តារខៀន) ។ ល ។

៧. ចូរធ្វើសកម្មភាពដូចលើកមុន ប៉ុន្តែលើកនេះត្រូវប្រើតែភាសាខ្មែរប៉ុណ្ណោះ ។

៨. ចូរប្រើរូបភាពហើយអានការសន្ទនាឱ្យសិស្សស្តាប់២ឬ៣ដង ។ សិស្សស្តាប់ ។

<u>គ្រូ</u> អរុណសួស្តីមីរ៉ា ។ តើប្អូនសុខសប្បាយឬទេថ្ងៃនេះ?

<u>សិស្ស</u> សុខសប្បាយណាស់ សូមអរគុណអ្នកគ្រូ ។ តើអ្នកគ្រូសុខសប្បាយឬទេថ្ងៃនេះ?

<u>គ្រូ</u> សុខសប្បាយណាស់ សូមអរគុណប្អូន ។
តើអ្នកគ្រូអាចជួយកិច្ចការធ្វើនៅផ្ទះរបស់ប្អូនបានឬទេ?

<u>សិស្ស</u> ចាស៎ អ្នកគ្រូ ។

៩. ចូរប្រើរូបភាព និងការសន្ទនាម្តងទៀត ។ ចូរនិយាយការសន្ទនា ហើយឱ្យសិស្សនិយាយតាមលោកគ្រូ/ អ្នកគ្រូ ។

១០. ចូរសម្តែងតួក្នុងការសន្ទនាជាមួយសិស្សក្នុងថ្នាក់ ។ លោកគ្រូ/អ្នកគ្រូសម្តែងតួជាគ្រូ សិស្សសម្តែងតួជាសិស្ស ។

១១. ចូរបែងចែកថ្នាក់ជាពាក់កណ្តាល ។ សិស្សពាក់កណ្តាលសម្តែងតួជាគ្រូនិងពាក់កណ្តាលទៀតសម្តែងតួជាសិស្ស ។

## II. ការផផែកអំពីរូបភាពនិងរឿងនិទានៈ "សត្វទន្សាយនិងផ្លែចេក "









### សត្វទន្សាយនិងផ្លែចេក

ថ្ងៃមួយលោកយាយម្នាក់បានទូលល្អីមួយដែលមានផ្លែចេកពេញមកពីចម្ការរបស់គាត់។ សត្វទន្សាយបានឃើញផ្លែចេកក៏នឹកចង់ស៊ី ដូចនេះវាក៏ធ្វើពុតជាស្លាប់។ លោកយាយបានឃើញទន្សាយស្លាប់នៅតាមផ្លូវ។ គាត់ត្រេកអរណាស់ ហើយក៏រើសទន្សាយឡើងដាក់ក្នុងល្អីរបស់គាត់ដោយគិតថាគាត់នឹងយកវាទៅធ្វើម្ហូប។ នៅតាមផ្លូវទៅផ្ទះ ទន្សាយបានចាប់ផ្តើមស៊ីផ្លែចេកនៅក្នុងល្អី។ លោកយាយពុំមានការសង្ស័យអ្វីឡើយ ពីព្រោះគាត់កំពុងតែគិត ថាតើត្រូវយកទន្សាយទៅស្លអ្វី។ ទន្សាយបានស៊ីចេកលោកយាយអស់ហើយ ក៏លោតចេញពីល្អីរត់ចូលទៅក្នុងព្រៃបាត់ស្រមោល។ លោកយាយមកដល់ផ្ទះក៏ដាក់ល្អីរបស់គាត់ចុះ ស្រាប់តែឃើញល្អីទទេស្អាត។ លោកយាយមិនជឿថាមានរឿងនេះកើតឡើងឡើយ។ តើចេករបស់គាត់នៅឯណា? តើទន្សាយ នៅឯណា?

១. ចូរអានរឿងនិទានឱ្យសិស្សស្តាប់ហើយប្រាប់សិស្សថា **"ចូរទះដៃនៅពេលដែលប្អូនៗឮអ្នកគ្រូ/លោកគ្រូនិយាយពាក្យ "ទន្សាយ"**។ បន្ទាប់មកអានរឿងនិទានម្តងទៀតហើយប្រាប់សិស្សថា **"ចូររាប់មើល តើប្អូនៗឮពាក្យ "ទន្សាយ" ប៉ុន្មានដងនៅក្នុងរឿងនិទាន"**។

២. ចូរចែកក្រដាស និងខ្មៅដៃខ្លះដល់សិស្ស ហើយឱ្យសិស្សគូររូបភាពអំពីផ្នែកនៃរឿងនិទានដែលពួកគេចូលចិត្តជាងគេ។ បន្ទាប់មកឱ្យសិស្សបង្ហាញរូបគំនូរពួកគេដល់ថ្នាក់ទាំងមូល និងពន្យល់អំពីអ្វីដែលពួកគេបានគូរដោយនិយាយថា **"ខ្ញុំបានគូររូបលោកយាយទូលផ្លែចេក"** **"ខ្ញុំបានគូររូបទន្សាយស៊ីផ្លែចេក"**។ ចូររក្សាទុករូបគំនូរទាំងនេះសម្រាប់ប្រើបន្តទៀត។

## ឈុតសកម្មភាពទី៤ ការរៀនលេខនិងការប្រកបចំនួន និងការជជែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការរៀនលេខនិងការប្រកបចំនួន:

ប័ណ្ណរូបភាពសម្រាប់រៀនចំនួន

| | | | |
|---|---|---|---|
| ១<br>មួយ | សាលារៀន | ៦<br>ប្រាំមួយ | ក្ដារឆ្នួន |
| ២<br>ពីរ | សិស្សា | ៧<br>ប្រាំពីរ | សៀវភៅ |
| ៣<br>បី | ដុំដីសរ | ៨<br>ប្រាំបី | គ្រូបង្រៀន |
| ៤<br>បួន | សិស្សី | ៩<br>ប្រាំបួន | សំពៀត<br>សៀវភៅ |
| ៥<br>ប្រាំ | ខ្មៅដៃ | ១០<br>ដប់ | សិស្ស |

១. ចូរបង្រៀនសិស្សនូវចំនួនពី១ដល់៥ជាភាសាខ្មែរដោយប្រើសម្ភារពិត។ ចូរបង្ហាញខ្មៅដៃដល់សិស្សហើយប្រាប់សិស្សថា "**នេះគឺជាខ្មៅដៃមួយដើម** "។ បន្ទាប់មកសួរសិស្សថា " **តើមានខ្មៅដៃប៉ុន្មាន?**" (១)។ គ្រូបន្ដលើកខ្មៅដៃពីរដើមឡើងហើយប្រាប់ថា "**ទាំងនេះគឺខ្មៅដៃពីរដើម**" បន្ទាប់មកសួរថា" **តើមានខ្មៅដៃប៉ុន្មានដើម?**" (២) ។ល។ លោកគ្រូ/អ្នកគ្រូត្រូវប្រាប់ និងសួររបៀបនេះសម្រាប់គ្រប់ចំនួនទាំងអស់ពី១ដល់៥។

២. ចូរធ្វើសកម្មភាពដូចគ្នា ប៉ុន្ដែលើកនេះ ចូរណែនាំឱ្យស្គាល់ចំនួនពី៦ដល់១០ ដោយប្រើសម្ភារពិត។

៣. ចូររំលឹកចំនួនពី១ដល់១០ ជាក្រុមដោយប្រើសម្ភារពិត (ឧ: ខ្មៅដៃឬបំពង់បឺត)។ ចូរបែងចែកសិស្សទៅជាក្រុមតូចៗ ហើយឱ្យសិស្សម្នាក់នៅក្នុងក្រុមនីមួយៗបង្ហាញខ្មៅដៃឬបំពង់បឺតព្រមទាំងសួរថា " **តើមាន ខ្មៅដៃ/បំពង់បឺតប៉ុន្មាន?**" សមាជិកក្នុងក្រុមត្រូវឆ្លើយតប។ សិស្សម្នាក់ៗនៅក្នុងក្រុមត្រូវដាក់វេនគ្នាសួរ " **តើមាន ...............ប៉ុន្មាន?**"។

៤. ចូរជជែកអំពីប័ណ្ណរូបភាពពី១ដល់១០ដោយប្រើភាសាកំណើតរបស់សិស្សហើយសួរសិស្សថា "**តើប្អូនមើលឃើញអ្វីខ្លះ? តើប្អូន មើលឃើញមនុស្សប៉ុន្មាននាក់? តើពួកគេជានរណា?** " (សិស្សឆ្លើយដោយប្រើភាសារបស់ពួកគេ)។ល។

៥. ចូរប្រើប័ណ្ណរូបភាពដូចគ្នាពីលេខ១ដល់១០ ប៉ុន្ដែពេលនេះចូរនិយាយជាមួយសិស្សដោយប្រើភាសាខ្មែរ ឧទា: "**នេះជាសាលារៀន។ "ហើយឥឡូវនេះចូរប្អូនៗនិយាយវាជាភាសារបស់ប្អូនៗ?**" (សិស្សឆ្លើយជាភាសារបស់ ពួកគេ) "**មានសិស្សា២នាក់**" "**ចូរប្អូននិយាយជាភាសារបស់ប្អូន ?** " (សិស្សឆ្លើយជាភាសារបស់ពួកគេ)។

៦. ចូររំលឹកប័ណ្ណពីលេខ១ដល់១០ដោយប្រើភាសាខ្មែរ។ ចូរប្រាប់សិស្សថា " នេះជាសាលារៀន១ " បន្ទាប់មកសួរសិស្សថា " **តើវាជាអ្វី ?** " (សាលារៀនមួយ)។ លោកគ្រូ/អ្នកគ្រូបន្ដប្រាប់ថា: **មានសិស្សា២នាក់** និងសួរថា "**តើមានសិស្សាចំនួនប៉ុន្មាននាក់ ?** " (២)។

៧. ចូរលើកប័ណ្ណរូបភាពខុសៗគ្នាទៅតាមលំដាប់លំដោយហើយសួរសិស្ស "**តើមាន...........ដែលប្អូនអាចមើល ឃើញ?** ចូរចែកសិស្សជា៥ក្រុម ហើយឱ្យរូបភាព២ទៅឱ្យក្រុមនីមួយៗ។ ឱ្យក្រុមទាំងមូលប្រាប់គ្នា ទៅវិញទៅមកពីរូបភាព។ បន្ទាប់មកទៀតធ្វើការផ្លាស់ប្ដូរប័ណ្ណរូបភាពជុំវិញក្រុម ។

៨. ចូររំលឹកលេខពី១-១០ម្តងទៀត ដោយបិទរូបភាពលើក្តារខៀនកុំឱ្យត្រូវតាមលំដាប់លំដោយ ហើយឱ្យសិស្សផ្សេងៗគ្នាឡើងក្តារខៀនដើម្បីជួយគ្នាក្នុងការតំរៀបរូបភាពឱ្យត្រូវតាមលំដាប់លំដោយពី១-១០។ ប័ណ្ណទី១ជា " **សាលារៀន**" ប័ណ្ណទី២ ជា "**សិស្ស ២ នាក់** "។ ល។ ក្រុមទាំងមូលអាចជួយគ្នាបាន។

៩. ចូរប្រើសម្ភារពិតដើម្បីរំលឹកលេខនិងពាក្យថ្មីជាភាសាខ្មែរដោយប្រាប់សិស្សថា "**សូមបង្ហាញខ្មៅដៃ៤ដល់ខ្ញុំ** "។ សិស្សត្រូវលើកខ្មៅដៃ៤ ឡើង។ គ្រូបន្តប្រាប់ទៀតថា " **សូមបង្ហាញកាតាប៣ដល់ខ្ញុំ** " ។ល។

១០. ចូរណែនាំលេខជាភាសាខ្មែរដល់សិស្ស។ ចូរគ្របការប្រកបលេខសម្រាប់សកម្មភាពនេះ បន្ទាប់មកចង្អុលលេខនីមួយៗ ហើយប្រាប់សិស្សថា " **នេះគឺជាលេខ ១** "។ **និងសួរទៀតថា** "**តើនេះជាលេខប៉ុន្មាន ?**" ( លេខ ១ )។ "**នេះជាលេខ ២ ។ល។** "

១១. **មើល គ្រប សរសេរ ផ្ទៀងផ្ទាត់** លេខពី១-១០។ ចូរគ្របការប្រកបលេខសម្រាប់មេរៀននេះ។ ចូរលើកប័ណ្ណឡើងហើយសួរថា "**តើនេះជាលេខប៉ុន្មាន ?** " (លេខ២)។ ចូរគ្របប័ណ្ណ ហើយឱ្យសិស្សសរសេរលេខដាក់នៅលើក្តារឆ្នួនរបស់ពួកគេហើយឱ្យសិស្ស " លើកក្តារឆ្នួនឡើង " បន្ទាប់មកបើកប័ណ្ណឡើងវិញដើម្បីពិនិត្យមើល។

១២. ចែកសិស្សជាក្រុមចំនួន១០នាក់ និងឱ្យប័ណ្ណលេខទៅក្រុមនីមួយៗ។ ចូរគ្របការប្រកបលេខសម្រាប់សកម្មភាពនេះ។ ចូរហៅសិស្សម្នាក់នៅក្នុងក្រុមឱ្យឡើងក្តារខៀនហើយប្រាប់ថា " **ចូរដាក់ប័ណ្ណលេខឱ្យត្រូវទៅតាមលំដាប់លំដោយ ពី ១-១០**" ។ សិស្សនៅក្នុងថ្នាក់ទាំងមូលអាចជួយបាន ។

១៣. ចូរណែនាំសិស្សនូវការប្រកបពី១-១០។ ចូរលើកប័ណ្ណពី១-១០ឡើងហើយចង្អុលទៅលេខ "**តើនេះជាលេខប៉ុន្មាន?** " (លេខ ១)។ បន្ទាប់មកចង្អុលពាក្យហើយប្រាប់សិស្សថា "**នេះគឺជាលេខ ១** "។ ចូរធ្វើសកម្មភាពដូចគ្នាចំពោះប័ណ្ណដែលនៅសល់ ។

១៤. ចូររំលឹកការអានពាក្យថ្មីជាភាសាខ្មែរ។ នៅពេលនេះចូរគ្របលេខនៅលើប័ណ្ណ។ លើកប័ណ្ណនីមួយៗឡើងហើយចង្អុលតែពាក្យដោយសួរសិស្ស " **តើនេះជាលេខប៉ុន្មាន ?** " សិស្សអានពាក្យថា "**១**"។ ចូរធ្វើរបៀបនេះចំពោះលេខដែលនៅសល់ពីលេខ ២-១០។

១៥. ចូរដាក់ប័ណ្ណលេខពី១-១០លើក្តារខៀនកុំឱ្យត្រូវតាមលំដាប់លំដោយ។ ចូរគ្របលេខ ហើយឱ្យសិស្សតំរៀបប័ណ្ណឱ្យត្រូវទៅតាមលំដាប់លំដោយឡើងវិញពី១-១០។ សិស្សត្រូវអានពាក្យ និងតំរៀបប័ណ្ណទៅតាមលំដាប់លំដោយ។

១៦. ចូរណែនាំរូបភាព និងប័ណ្ណរួមគ្នាតែម្តង។ ចូរលើករូបភាព និងប័ណ្ណតាមគូដែលត្រឹមត្រូវពី១-១០ (ឧទា: រូបភាពសាលារៀនត្រូវនឹងលេខ ១ )ហើយសួរសិស្សថា " **តើនេះជាអ្វី?** "(សាលារៀន)។ "**តើមានសាលារៀនប៉ុន្មាន?**" (១)។

១៧. ចូរដាក់រូបភាព និងលេខលើក្តារខៀន ហើយឱ្យសិស្សភ្ជាប់រូបភាព និងប័ណ្ណលេខឱ្យត្រូវគ្នា។

១៨. ចូរចែកសិស្សនៅក្នុងថ្នាក់ជា២០ក្រុម ហើយឱ្យប័ណ្ណ១ទៅក្រុមនីមួយៗដោយប្រាប់ថា " **ប័ណ្ណរបស់ប្អូនៗត្រូវការស្វែងរកគូត្រឹមត្រូវរបស់វា។ ចូរស្វែងរកក្រុមដែលមានគូត្រូវគ្នា**"។ សិស្សត្រូវដើរជុំវិញថ្នាក់រៀនដើម្បីស្វែងរករូបភាពឬប័ណ្ណលេខដែលត្រូវគ្នាជាមួយនឹងរបស់ដែលខ្លួនមាន។

## II. ការផផែកអំពីរូបភាពនិងរឿងនិទានៈ "សត្វទន្សាយនិងផ្លែចេក "






១. ចូរហាត់សម្តែងតួអំពីផ្នែកខ្លះនៃរឿងនិទាន។ លោកគ្រូ/អ្នកគ្រូត្រូវធ្វើបង្ហាញសិស្សជាមុន បន្ទាប់មកសិស្សត្រូវធ្វើតាមគំរូរបស់លោកគ្រូ/អ្នកគ្រូ។

**<u>ផ្នែកនានារបស់រឿងនិទានសម្រាប់សម្តែងតួ</u>**

*លោកយាយឃើញសត្វទន្សាយស្លាប់នៅតាមផ្លូវ*

*សត្វទន្សាយធ្វើពុតជាស្លាប់*

*លោកយាយទូលកាផាគាត់ទៅផ្ទះ*

*សត្វទន្សាយស៊ីចេក*

*លោកយាយរកមិនឃើញចេករបស់គាត់ឬសត្វទន្សាយឡើយ*

២. ចូរដាក់ប្រយោគផ្ទាល់មាត់ឱ្យត្រូវជាមួយនឹងរូបភាព។ ចូរអានប្រយោគនេះឱ្យសិស្សស្តាប់ហើយឱ្យពួកគេរករូបភាពណាដែលត្រូវគ្នាជាងគេជាមួយប្រយោគនេះ។

**<u>ផ្នែកនានារបស់រឿងនិទានសម្រាប់ផ្គូរគ្នាជាមួយរូបភាពឱ្យបានត្រឹមត្រូវ</u>**


លោកយាយឃើញទន្សាយស្លាប់នៅតាមផ្លូវ


ទន្សាយធ្វើពុតជាស្លាប់

លោកយាយទូលកាផាទៅផ្ទះ

ទន្សាយស៊ីចេក




លោកយាយរកមិនឃើញចេករបស់គាត់ឬសត្វទន្សាយ

⊱⊱⊱⊱⊱⓪⊰⊰⊰⊰⊰

# មេរៀនទី៣ បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ



## គោលបំណងមេរៀន

**សិស្សនៅថ្នាក់ទី១ នឹងរៀនៈ**

- ចំរៀង/កំណាព្យ/មេសូត្រជាភាសាខ្មែរ
- ភាសាបទបញ្ជាក្នុងថ្នាក់រៀន
- ភាសាស្វាគមន៍ និងការណែនាំឱ្យស្គាល់គ្នា
- ចំនួនពី១-១០
- ការជជែកអំពីរូបភាព

## ធនធានសម្រាប់បង្រៀន

**សម្ភារមានៈ**

- ប័ណ្ណរូបភាពសម្រាប់រៀនលេខ និងឈ្មោះចំនួន
- រូបភាព "គ្រូ និងសិស្ស"
- រូបភាព "បន្ទប់រៀនថ្នាក់ទី១ខ្ញុំ" និងរឿងនិទាន

ចូរបែងចែកពេលវេលាសម្រាប់ធ្វើសកម្មភាពខ្លីៗពីឃុតសកម្មភាពទាំង៤ខាងក្រោម

ចូរព្យាយាមធ្វើសកម្មភាពខុសៗគ្នា៤ឬ៥នៅក្នុងមេរៀនរយៈពេលមួយម៉ោងរបស់លោកគ្រូ/អ្នកគ្រូ

## ឈុតសកម្មភាពទី១ ចំរៀង និងការជជែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ចំរៀង "ជំបូន្មានរបស់គ្រូ "(លំនាំបទយប់យន់)

*ក្រចកត្រូវកាត់ឱ្យខ្លី កុំលេងដីក្រែងវាឆ្លងជំងឺ*
*ភ្នែកជានឹងក្លាយជាឈឺ ពេលដឹងលឺគេឈប់ឱ្យលេងចូល ។*

១. ចូរប្រើចំរៀងខាងលើសម្រាប់គំរូសកម្មភាពនេះដោយនិយាយឬច្រៀងឱ្យសិស្សស្តាប់ សិស្សស្តាប់ហើយថាតាមលោកគ្រូ/អ្នកគ្រូ បន្ទាប់មកគ្រូច្រៀងចំរៀងម្តងទៀត ។
២. ចូរហាត់បទភ្លេងជាមួយសិស្សដោយគ្មានសម្លេង ។ ចូរច្រៀងឃ្លានីមួយៗនៃចំរៀងតិចៗនិងឱ្យសិស្សថា តាមគ្រូ ។
៣. ចូរអានចំរៀងមួយបន្ទាត់ៗទៅកាន់សិស្ស ។ ចំណែកសិស្សត្រូវស្តាប់ និងនិយាយបន្ទាត់នីមួយៗឡើងវិញ ។ បន្ទាប់មកគ្រូឱ្យសិស្សម្នាក់ៗនិយាយឡើងវិញតាមលោកគ្រូ/អ្នកគ្រូ ។
៤. ចូរសួរសំណួរទៅសិស្សអំពីចំរៀងនោះថា **"តើចំរៀងនេះនិយាយអំពីអ្វី?" តើវានិយាយអំពីទុក្ខព្រួយឬភាពសប្បាយ?"** ។ល ។
៥. ចូរឱ្យសិស្សគូររូបភាពអំពីចំរៀងនោះ ហើយហៅពួកគេឡើងមកលើក្តារខៀនដើម្បីនិយាយពីរូបភាពដែលពួកគេបានគូរឱ្យសិស្សទាំងអស់គ្នាបានស្តាប់ ។
៦. ចូរចែកសិស្សជា២ក្រុម ។ ក្រុមទី១ច្រៀងចំរៀងពាក់កណ្តាលដំបូង និងក្រុមទី២ច្រៀងផ្នែកដែលនៅសល់ ។ បន្ទាប់មកក្រុមទាំងមូលច្រៀងម្តងទៀតទាំងអស់គ្នា ។
៧. ចូរហ្វឹកហាត់ចំរៀងនេះជារៀងរាល់ថ្ងៃ ។

### II. ការជជែកអំពីរូបភាព "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ "

**បញ្ជីពាក្យជាភាសាខ្មែរ**

| | | |
|---|---|---|
| ថ្នាក់រៀន | តុ | នៅលើ |
| សិស្ស | ក្តារខៀន | នៅក្រោម |
| គ្រូ | សៀវភៅ | នៅពីមុខ |
| ដីស | ក្តារឆ្នួន | នៅជាប់ |
| | ខ្មៅដៃ | |



១. ចូរសួរសំណួរសិស្សអំពីរូបភាពជាភាសាកំណើតរបស់សិស្ស ។

| **សំណួរគ្រូ** | **ឧទាហរណ៍ចម្លើយ** |
|---|---|
| តើមនុស្សនៅក្នុងរូបភាពស្ថិតនៅឯណា ? | ថ្នាក់រៀន? សាលារៀន? ផ្ទះ? |
| តើមនុស្សនៅក្នុងរូបភាពជាអ្នកណា ? | សិស្ស? សិស្ស? គ្រូ? |
| តើសិស្សនៅថ្នាក់ទីប៉ុន្មាន? | ថ្នាក់ទី ១? ទី២? ទី៣? |
| តើសិស្សកំពុងធ្វើអ្វី ? | រៀន? សរសេរ? និយាយ? មើលក្តាខៀន? |
| តើគ្រូកំពុងធ្វើអ្វី ? | សរសេរដាក់លើក្តាខៀន? រៀន? |
| តើប្អូនអាចឃើញសិស្សប៉ុន្មាននាក់នៅក្នុងរូបភាព ? | (សិស្សអាចរាប់) សិស្ស១៥នាក់ ? ១៦នាក់? |
| តើនៅថ្នាក់ទី ១ មានសិស្សច្រើនឬតិច? | (សិស្សគួររាប់ចំនួនសិស្សនៅក្នុងថ្នាក់រៀន) |

២. ចូរប្រាប់សិស្សអំពីរូបភាពជាភាសាកំណើតរបស់សិស្ស ។

**នេះជាគ្រូនៅខាងមុខថ្នាក់រៀន ។**

**ទាំងនេះជាសិស្សនៅថ្នាក់ទី១ ។ ពួកគេកំពុងអង្គុយនៅលើតុ ។**

**នេះជាក្តារខៀន ។ ទាំងនេះជាក្តារឆ្នួន ។ ពួកគេអង្គុយនៅតុ ។**

៣. ចូរបង្ហាញរូបភាពដល់សិស្ស ហើយសួរជាភាសាកំណើតរបស់សិស្ស ។

| **សំណួរគ្រូ** | **ឧទាហរណ៍ចម្លើយ** |
|---|---|
| តើគ្រូឈរនៅកន្លែងណា ? | នៅមុខថ្នាក់រៀន |
| តើសិស្សនៅកន្លែងណា? | នៅក្នុងថ្នាក់រៀន កំពុងអង្គុយនៅតុរបស់ពួកគេ |
| តើសិស្សកំពុងមើលអ្វី? | មើលគ្រូ មើលក្តារខៀន |
| តើក្តារឆ្នួននៅឯណា ? | នៅតុ |
| តើសំពៀតសិស្សនៅឯណា? | (សិស្សគួរទាយចម្លើយ) នៅក្រោមតុ? នៅលើតុ ? |

## ឈុតសកម្មភាពទី២ បទបញ្ជាក្នុងថ្នាក់រៀន និងការចែករំលែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

## I. បទបញ្ជាក្នុងថ្នាក់រៀនៈ

<u>សូមក្រោកឈរឡើង</u>  <u>សូមអង្គុយចុះ</u> 

<u>សូមប្អូនៗលើកដៃឡើង</u>  <u>សូមឈប់ជជែកគ្នា</u>

<u>សូមស្តាប់</u>

សូមប្អូនៗយកក្តារឆ្នួននិងដីសចេញមក  សូមឡើងក្តារខៀន

សូមនិយាយតាមអ្នកគ្រូ /លោកគ្រូ

១. ចូរណែនាំឱ្យសិស្សស្គាល់បទបញ្ជាក្នុងថ្នាក់រៀនថ្មីពីរជាភាសាកំណើតរបស់សិស្ស **"សូមឡើងក្តារខៀន"** និង **"សូមនិយាយតាម អ្នកគ្រូ/លោកគ្រូ"**។ ចូរធ្វើបង្ហាញសិស្ស ចំណែកសិស្សត្រូវមើលនិងស្តាប់ បន្ទាប់មកសិស្សត្រូវធ្វើតាមគំរូ របស់លោកគ្រូ/អ្នកគ្រូ។

២. នៅលើកនេះ ចូរណែនាំបទបញ្ជាដូចគ្នានេះជាភាសាខ្មែរដោយធ្វើគំរូឱ្យសិស្សមើលផង។ បន្ទាប់មកសួរសិស្សថា **"តើយើងនិយាយយ៉ាងដូចម្តេចជាភាសាកំណើតរបស់សិស្ស?"**។

៣. ចូររំលឹកបទបញ្ជាទាំងអស់ឡើងវិញដោយហៅសិស្ស៤នាក់ឡើងមកខាងមុខថ្នាក់។ ហើយលោកគ្រូ/អ្នកគ្រូផ្តល់បទបញ្ជា (ឧទាហរណ៍: **សូមលើកដៃប្អូនៗឡើង**)។ សិស្សត្រូវស្តាប់ និងធ្វើតាមអ្វីដែលគ្រូឱ្យធ្វើ។ ឥឡូវនេះចូរផ្តល់បទបញ្ជាពីរ (ឧទាហរណ៍: **សូមលើកដៃប្អូនៗឡើង និងទៅកាន់ក្តារខៀន**)។ សិស្សត្រូវស្តាប់ និងធ្វើតាមអ្វីដែលគ្រូឱ្យធ្វើ ។

៤. ចូរចែកសិស្សជាក្រុមដែលមានគ្នាពី៤ទៅ៥នាក់ ហើយតែងតាំងសិស្សម្នាក់នៅក្នុងក្រុមឱ្យធ្វើជា "គ្រូ"។ "គ្រូ" ម្នាក់ៗត្រូវផ្តល់បទបញ្ជាផ្សេងៗទៅឱ្យក្រុម ចំណែកក្រុមត្រូវស្តាប់ និងធ្វើតាមអ្វីដែលបានប្រាប់។

៥. ចូរហាត់ធ្វើបទបញ្ជាថ្មីមួយជារៀងរាល់ថ្ងៃដោយប្រើភាសាពួកគេនៅលើកដំបូង និងធ្វើគំរូឱ្យសិស្សមើល។ ចូរបង្ហាញបទបញ្ជានេះម្តងទៀតដល់សិស្សដោយនិយាយជាភាសាខ្មែរព្រមទាំងធ្វើគំរូឱ្យសិស្សមើល។

៦. ចូរសម្តែងតួផ្តល់បទបញ្ជាដោយហៅសិស្សឱ្យនិយាយបទបញ្ជាជាភាសាខ្មែរ។

៧. ឱ្យសិស្សជ្រើសរើសបទបញ្ជាមួយ និងផ្តល់បទបញ្ជានោះទៅកាន់សិស្សដទៃទៀតនៅក្នុងថ្នាក់ដោយប្រើ ភាសាខ្មែរ។ សិស្សទាំងឡាយត្រូវធ្វើតាមឱ្យបានត្រឹមត្រូវ។

៨. ចូរចែកថ្នាក់រៀនជាក្រុមតូចៗ ហើយសិស្សម្នាក់ៗសម្តែងតួផ្តល់បទបញ្ជាដល់ក្រុម។ សមាជិកក្រុមត្រូវទាយបទបញ្ជា និងនិយាយតើវាជាអ្វី។

៩. សិស្សគូររូបភាពឱ្យត្រូវគ្នានឹងបទបញ្ជានីមួយៗ។ សិស្សបង្ហាញគំនូរពួកគេទៅកាន់ថ្នាក់។ ធ្វើការទស្សន៍ទាយបទបញ្ជាដែលត្រូវគ្នានឹងរូបភាព។

## II.ការពណ៌នាអំពីរូបភាពនិងរឿងនិទានៈ "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ "



១. ចូរប្រាប់សិស្សពីរូបភាពដោយប្រើភាសាខ្មែរ ។ គ្រូអាចប្រើភាសាកំណើតរបស់សិស្សបានប្រសិនបើសិស្សពុំយល់

**នេះជាគ្រូនៅខាងមុខថ្នាក់រៀន ។**

**ទាំងនេះជាសិស្សនៅថ្នាក់ទី១ ។ ពួកគេកំពុងអង្គុយនៅលើតុ ។**

**នេះជាក្តាខៀន ។ ទាំងនេះជាក្តាឆ្នួន ។ ពួកគេអង្គុយនៅតុ ។**

២. ចូរបង្ហាញរូបភាពដល់សិស្សហើយសួរជាភាសាខ្មែរ ។

| សំណួរគ្រូ | ចម្លើយ |
|---|---|
| តើគ្រូឈរនៅកន្លែងណា ? | នៅមុខថ្នាក់រៀន |
| តើសិស្សនៅកន្លែងណា? | នៅក្នុងថ្នាក់រៀន កំពុងអង្គុយនៅតុរបស់ពួកគេ |
| តើសិស្សកំពុងមើលអ្វី? | មើលគ្រូ មើលខ្តាខៀន |
| តើក្តាឈ្នួននៅឯណា ? | នៅតុ |
| តើសំពៀតសិស្សនៅឯណា? | (សិស្សគួទាយចម្លើយ) នៅក្រោមតុ? នៅលើតុ ? |

៣. ចូរបង្ហាញរូបភាពនិងសួរសិស្សជាភាសាខ្មែរថា **"តើមានអ្វីផ្សេងទៀតដែលប្អូនអាចមើលឃើញ ?"** (គ្រូ សិស្ស ក្តាខៀន តុ) បន្ទាប់មកឱ្យសិស្សគូររូបនៅក្នុងរូបភាពដាក់លើក្តារឆ្នួន ឧទា: គ្រូ។ ចូរសួរសិស្សអំពីគំនូរជាភាសាខ្មែរថា "តើនេះជាអ្នកណា?" (នេះជាគ្រូថ្នាក់ទី១របស់ខ្ញុំ) ។ ហៅសិស្សឡើងមកខាងមុខថ្នាក់ហើយនិយាយអំពីរូបភាពទៅតាមគំរូប្រយោគ ឧទាហរណ៍: **"ខ្ញុំបានគូររូបលោកគ្រូ/អ្នកគ្រូនៅថ្នាក់ទី ១ របស់ខ្ញុំ "** ។

## ឈុតសកម្មភាពទី៣ ការស្វាគមន៍គ្នា និងការពណ៌នាអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

## I.ការស្វាគមន៍គ្នា:

ឧទាហរណ៍: **អរុណសួស្តី ។ តើសំឡាញ់សុខសប្បាយឬទេថ្ងៃនេះ? (ខ្ញុំសុខសប្បាយជាទេ សូមអរគុណ)**
**សាយ័ណសួស្តី ។**

១. ចូរណែនាំសិស្សឱ្យស្គាល់ពាក្យស្វាគមន៍គ្នាជាភាសាខ្មែរ ហើយសិស្សត្រូវនិយាយវាឡើងវិញតាមលោកគ្រូ /អ្នកគ្រូ ។

២. ចូរនិយាយពាក្យស្វាគមន៍ ហើយសិស្សត្រូវឆ្លើយតបឱ្យបានសមរម្យ ។

៣. ឱ្យសិស្សសម្តែងតួជាគូ ដោយធ្វើជាគ្រូ និងសិស្ស /សិស្ស និងសិស្ស ។

## ការប្រើរូបភាព



៤. ចូរប្រើរូបភាពហើយសួរសំណួរជាភាសាកំណើតរបស់សិស្ស ។ ឧទាហរណ៍: **"តើមនុស្សទាំងនេះជានរណា?" "តើពួកគេនៅឯណា?" " តើស្ត្រីម្នាក់នោះកំពុងនិយាយអ្វីខ្លះទៅកាន់សិស្ស?"** ។ ល ។

៥. ចូរប្រើរូបភាពហើយធ្វើសកម្មភាពដូចគ្នានឹងលើកមុន ប៉ុន្តែត្រូវប្រើភាសាខ្មែរតែប៉ុណ្ណោះ ។

៦. ចូរប្រើភាសាកំណើតរបស់សិស្សដើម្បីប្រាប់សិស្សអំពីវត្ថុផ្សេងៗនៅក្នុងរូបភាព ។ ឧទាហរណ៍: " **នេះជាក្តារខៀន/ទូ/ គ្រូបង្រៀន**" ។ ល ។ បន្ទាប់មកសួរសិស្សថា" **តើនេះជាអ្វី?**" (វាគឺជាក្តារខៀន) ។ ល ។

៧. ចូរធ្វើសកម្មភាពដូចលើកមុនតែលើកនេះត្រូវប្រើភាសាខ្មែរប៉ុណ្ណោះ ។

៨. ចូរប្រើរូបភាពហើយអានការសន្ទនាឱ្យសិស្សស្តាប់២ឬ៣ដង ។ សិស្សស្តាប់ ។

| | |
|---|---|
| <u>គ្រូ</u> | អរុណសួស្តីមីរ៉ា ។ តើប្អូនសុខសប្បាយឬទេថ្ងៃនេះ? |
| <u>សិស្ស</u> | សុខសប្បាយណាស់ សូមអរគុណអ្នកគ្រូ ។ តើអ្នកគ្រូសុខសប្បាយឬទេថ្ងៃនេះ? |
| <u>គ្រូ</u> | សុខសប្បាយណាស់ សូមអរគុណប្អូន ។<br>តើអ្នកគ្រូអាចជួយកិច្ចការធ្វើនៅផ្ទះរបស់ប្អូនបានឬទេ? |
| <u>សិស្ស</u> | ចាស៎ អ្នកគ្រូ ។ |

៩. ចូរប្រើរូបភាព និងការសន្ទនាម្តងទៀត ដោយនិយាយការសន្ទនាហើយឱ្យសិស្សនិយាយតាមលោកគ្រូ/ អ្នកគ្រូ

១០. ចូរសម្តែងតួក្នុងការសន្ទនាជាមួយសិស្សក្នុងថ្នាក់ ដោយលោកគ្រូ/អ្នកគ្រូសម្តែងតួជាគ្រូ សិស្សសម្តែងជាសិស្ស ។

១១. ចូរបែងចែកថ្នាក់ជាពាក់កណ្តាលដោយសិស្សពាក់កណ្តាលសម្តែងតួជាគ្រូ និងពាក់កណ្តាលទៀតសម្តែងតួជា សិស្ស ។

## II. ការចែករំលែកអំពីរូបភាពនិងរឿងនិទានៈ "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ "

### បន្ទប់រៀនថ្នាក់ទី១ របស់ខ្ញុំ

នេះគឺជាបន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំនៅសាលារៀន ។នៅក្នុងថ្នាក់របស់ខ្ញុំមានវត្ថុផ្សេងៗជាច្រើន ។ មានគ្រូនៅខាងមុខថ្នាក់រៀន ។ គ្រូសរសេរនៅលើក្តារខៀននឹងដីស ។ មានសិស្សអង្គុយនៅតាមតុរបស់ពួកគេ ។ នៅលើតុពួកគេមានក្តារឆ្នួន សៀវភៅ និងខ្មៅដៃ ។ នៅក្រោយតុមានសំពៀត ។ នៅក្នុងថ្នាក់រៀនខ្ញុំអង្គុយនៅជាប់មិត្តរបស់ខ្ញុំឈ្មោះម៉េរ៉ា ។ខ្ញុំចូលចិត្តបន្ទប់រៀនថ្នាក់ទី១ របស់ខ្ញុំខ្លាំងណាស់ ។



១. ចូរបិទរូបភាពលើក្ដារខៀនហើយអានរឿងអំពីរូបភាពនោះឱ្យសិស្សស្ដាប់។ សិស្សគ្រាន់តែស្ដាប់ និងមើល រូបភាព។
២. ចូរអានរឿងដដែលឱ្យសិស្សស្ដាប់ព្រមទាំងចង្អុលវត្ថុផ្សេងៗក្នុងរូបភាព ហើយប្រាប់សិស្សជាភាសាខ្មែរ ឧទាហរណ៍៖ "នេះជាគ្រូ " "នេះជាក្ដារខៀន"។ ចូរចង្អុលទៅកន្លែងផ្សេងទៀតនៅក្នុងរូបភាពហើយសួរថា "តើនេះជាអ្វី? " (ក្ដារខៀន) "តើនេះជាអ្នកណា?" (គ្រូ)។
៣. ចូររំលឹកពាក្យថ្មីដើម្បីធ្វើតេស្ដការចងចាំរបស់សិស្ស ដោយបង្ហាញរូបភាពដល់សិស្សមួយផ្លែត។ បន្ទាប់មកសួរសំណួរថា "តើនេះជាអ្វី? " (គ្រូ តុ សិស្ស។ល។)។ បន្ទាប់មកទៀតចូរគ្របរូបភាពហើយឱ្យ សិស្សធ្វើការជាគូនិងចងចាំអ្វីដែលមាននៅក្នុងរូបភាពឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ គ្រូសរសេ ចម្លើយសិស្សរួចហើយបើករូបភាពហើយពិនិត្យមើលថាតើមានចម្លើយប៉ុន្មានដែលត្រឹមត្រូវ។
៤. ចូរអានរឿងនិទានឱ្យសិស្សស្ដាប់ និងឱ្យពួកគេ "ទះដៃនៅពេលដែលឮអ្នកគ្រូអានពាក្យ "ថ្នាក់រៀន"។ ចូរអានរឿងនិទានម្ដងទៀត ហើយប្រាប់សិស្សថា "ចូររាប់ចំនួនដងនៅពេលដែលអ្នកឮពាក្យថា "ថ្នាក់រៀន" នៅក្នុងរឿង និទាន" (៤ដង)។

## ឈុតសកម្មភាពទី៤ ការរៀនលេខនិងការប្រកបចំនួន និងការថតែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍៖ សកម្មភាព៤ឬ៥ដំបូង)**

### I.ការរៀនលេខ និងការប្រកបចំនួន៖

ប័ណ្ណរូបភាពសម្រាប់រៀនចំនួន

| | |
|---|---|
| ១<br>មួយ | សាលារៀន |
| ២<br>ពីរ | សិស្សា |
| ៣<br>បី | ដុំដីសរ |
| ៤<br>បួន | សិស្សី |
| ៥<br>ប្រាំ | ខ្មៅដៃ |

| | |
|---|---|
| ៦<br>ប្រាំមួយ | ក្ដារឆ្នួន |
| ៧<br>ប្រាំពីរ | សៀវភៅ |
| ៨<br>ប្រាំបី | គ្រូបង្រៀន |
| ៩<br>ប្រាំបួន | សំពៀត<br>សៀវភៅ |
| ១០<br>ដប់ | សិស្ស |

១. ចូរបង្រៀនសិស្សនូវចំនួនពី១ដល់៥ជាភាសាខ្មែរដោយប្រើសម្ភារពិត។ ចូរបង្ហាញខ្មៅដៃដល់សិស្សហើយប្រាប់សិស្សថា "**នេះជាខ្មៅដៃមួយដើម** "។ បន្ទាប់មកសួរសិស្ស " **តើមានខ្មៅដៃប៉ុន្មាន?**" (១)។ គ្រូបន្តលើកខ្មៅដៃពីរដើមឡើងហើយប្រាប់ថា "**ទាំងនេះជាខ្មៅដៃពីរដើម** " បន្ទាប់មកសួរថា" **តើមានខ្មៅដៃប៉ុន្មាន ដើម?**" (២) ។ល។ ចូរធ្វើបែបនេះរហូតគ្រប់ចំនួនទាំងអស់ពី១ដល់៥។

២. ចូរធ្វើសកម្មភាពដូចគ្នា ប៉ុន្តែនៅលើកនេះ ត្រូវណែនាំឱ្យស្គាល់ចំនួនពី៦ដល់១០ដោយប្រើសម្ភារពិត។

៣. ចូររំលឹកចំនួនពី១ដល់១០ជាក្រុមដោយប្រើសម្ភារពិត (ឧទាហរណ៍: ខ្មៅដៃឬបំពង់បឺត)។ ចូរបែងចែកសិស្សទៅជាក្រុមតូចៗ ហើយឱ្យសិស្សម្នាក់នៅក្នុងក្រុមនីមួយៗបង្ហាញខ្មៅដៃឬបំពង់បឺត និងសួរថា " **តើមានខ្មៅដៃ /បំពង់បឺតប៉ុន្មាន?**" សមាជិកក្នុងក្រុមត្រូវឆ្លើយតប។ សិស្សម្នាក់ៗនៅក្នុងក្រុមត្រូវដាក់ វេនគ្នាសួរ " **តើមាន ................ប៉ុន្មាន?**"។

៤. ចូរជជែកអំពីប័ណ្ណរូបភាពពី១ដល់១០ដោយប្រើភាសាកំណើតរបស់សិស្ស ហើយសួរសំណួរអំពីរូបភាពនោះថា។ "**តើប្អូនមើល ឃើញអ្វីខ្លះ? តើប្អូនមើលឃើញមនុស្សប៉ុន្មាននាក់? តើពួកគេជានរណា?** " (សិស្សឆ្លើយដោយប្រើភាសា របស់ពួកគេ)។

៥. ចូរប្រើប័ណ្ណរូបភាពដូចគ្នាពីលេខ១ដល់១០ ប៉ុន្តែនៅពេលនេះត្រូវនិយាយជាមួយសិស្សដោយប្រើភាសាខ្មែរ។ ឧទាហរណ៍: "**នេះជាសាលារៀន** " "**ហើយឥឡូវនេះចូរនិយាយជាភាសារបស់ប្អូនៗ**" (សិស្សឆ្លើយជាភាសារបស់ពួកគេ) "**មានសិស្សា២នាក់**" "**ចូរប្អូននិយាយវាជាភាសារបស់ប្អូន ?** " (សិស្សឆ្លើយជាភាសា របស់ពួកគេ)

៦. ចូររំលឹកប័ណ្ណពីលេខ១ដល់១០ដោយប្រើភាសាខ្មែរដោយប្រាប់សិស្ស " នេះជាសាលារៀន១"។ បន្ទាប់មកសួរសិស្សថា" **តើវាជាអ្វី ?** " (សាលារៀនមួយ)។ "មានសិស្សា២នាក់"។ "**តើមានសិស្សាចំនួនប៉ុន្មាននាក់ ?** " (២)។

៧. ចូរលើកប័ណ្ណរូបភាពខុសៗគ្នាទៅតាមលំដាប់លំដោយហើយសួរសិស្សថា "**តើមាន.....ដែលប្អូនអាចមើល ឃើញ?** ចូរចែកសិស្សជា៥ក្រុមហើយឱ្យរូបភាព២ទៅឱ្យក្រុមនីមួយៗ។ ចូរឱ្យក្រុមទាំងមូល ប្រាប់គ្នាទៅវិញទៅមកពីរូបភាព បន្ទាប់មកធ្វើការផ្លាស់ប្តូរប័ណ្ណរូបភាពជុំវិញក្រុម។

៨. ចូររំលឹកលេខពី១-១០ម្តងទៀត។ ចូរបិទរូបភាពលើក្តារខៀនកុំឱ្យត្រូវតាមលំដាប់លំដោយ ហើយឱ្យសិស្សផ្សេងៗគ្នាឡើងក្តារខៀនដើម្បីជួយគ្នាក្នុងការតំរៀបរូបភាពឱ្យត្រូវតាមលំដាប់លំដោយពី១-១០។ ប័ណ្ណទី១ជា "**សាលារៀន**" ប័ណ្ណទី២ជា "**សិស្ស២ នាក់** "។ ល។ ក្រុមទាំងមូលអាចជួយគ្នាបាន។

៩. ចូរប្រើសម្ភារពិតដើម្បីរំលឹកលេខនិងពាក្យថ្មីជាភាសាខ្មែរដោយប្រាប់សិស្សថា "**សូមបង្ហាញខ្មៅដៃ៤ដល់ខ្ញុំ** "។ សិស្សត្រូវលើកខ្មៅដៃ៤ ឡើង។ " **សូមបង្ហាញសំពៀតសៀវភៅ៣ដល់ខ្ញុំ** "។ ល។

១០. ចូរណែនាំលេខជាភាសាខ្មែរដល់សិស្ស។ ចូរគ្របការប្រកបលេខសម្រាប់សកម្មភាពនេះហើយចង្អុលលេខនីមួយៗដោយប្រាប់សិស្សថា "**នេះជាលេខ១**" **បន្ទាប់មកសួរថា** "**តើនេះជាលេខប៉ុន្មាន?**" (លេខ ១ )។ " **នេះជា លេខ២ ។ល។** "

១១. **មើល គ្រប សរសេរ ផ្ទៀងផ្ទាត់** លេខពី១-១០។ ចូរគ្របការប្រកបលេខសម្រាប់សកម្មភាពនេះ ហើយលើកប័ណ្ណចំនួនឡើងដោយសួរថា "**តើនេះជាលេខប៉ុន្មាន ?** " (លេខ ២)។ ចូរគ្របប័ណ្ណ។

ឱ្យសិស្សសរសេរលេខដាក់លើក្តារឆ្នួនរបស់ពួកគេ បន្ទាប់មកឱ្យសិស្សលើកក្តាឆ្នួនឡើង ហើយបើកប័ណ្ណឡើងវិញដើម្បីពិនិត្យមើល។

១២.ចូរចែកសិស្សជាក្រុមចំនួន១០នាក់ ហើយឱ្យប័ណ្ណលេខទៅក្រុមនីមួយៗ។ ចូរគ្រូបការប្រកបលេខសម្រាប់សកម្មភាពនេះ។ ចុរហៅសិស្សម្នាក់នៅក្នុងក្រុមឱ្យឡើងក្តារខៀនហើយប្រាប់ថា " **ចូរដាក់ប័ណ្ណលេខឱ្យត្រូវទៅតាមលំដាប់លំដោយ ពី ១-១០**"។ សិស្សនៅក្នុងថ្នាក់ទាំងមូលអាចជួយបាន។

១៣. ចូរណែនាំសិស្សនូវការប្រកបដោយឱ្យសិស្សលើកប័ណ្ណពី១-១០ឡើង បន្ទាប់មកចង្អុលទៅលេខហើយសួរថា "**តើនេះជាលេខប៉ុន្មាន?**" (លេខ ១)។ ចូរចង្អុលពាក្យហើយប្រាប់សិស្ស "**នេះគឺជាលេខ ១** "។ ចូរធ្វើសកម្មភាពដូចគ្នាចំពោះប័ណ្ណដែលនៅសល់។

១៤.រំលឹកការអានពាក្យថ្មីជាភាសាខ្មែរ។ នៅពេលនេះចូរគ្រូបលេខនៅលើប័ណ្ណ។ ចូរលើកប័ណ្ណនីមួយៗឡើងហើយចង្អុលតែពាក្យបានហើយនិងសួរសិស្សថា" **តើនេះជាលេខប៉ុន្មាន ?** " សិស្សអានពាក្យថា "**១**"។ ចូរធ្វើលេខដែលនៅសល់ពីលេខ ២-១០។

១៥.ចូរដាក់ប័ណ្ណលេខពី១-១០លើក្តារខៀនកុំឱ្យត្រូវតាមលំដាប់លំដោយ។ ចូរគ្រូបលេខ ហើយឱ្យសិស្សតំរៀបប័ណ្ណឱ្យត្រូវទៅតាមលំដាប់លំដោយឡើងវិញពី១-១០។ សិស្សត្រូវអានពាក្យ និងតំរៀបប័ណ្ណទៅតាមលំដាប់លំដោយ។

១៦.ចូរណែនាំរូបភាព និងប័ណ្ណរួមគ្នាតែម្តង។ ចូរលើករូបភាព និងប័ណ្ណតាមគូដែលត្រឹមត្រូវពី១-១០ (ឧទាហរណ៍ៈ រូបភាពសាលារៀនត្រូវនឹងលេខ ១ )។ សួរសិស្ស " **តើនេះជាអ្វី?** "(សាលារៀន)។ "**តើមាន សាលារៀនប៉ុន្មាន?**" (១)។

១៧.ចូរដាក់រូបភាព និងលេខលើក្តារខៀន ហើយឱ្យសិស្សភ្ជាប់រូបភាព និងប័ណ្ណលេខឱ្យត្រូវគ្នា។

១៨.ចែកសិស្សនៅក្នុងថ្នាក់ជា២០ក្រុម។ ឱ្យប័ណ្ណ១ទៅក្រុមនីមួយៗនិងប្រាប់ក្រុមនីមួយៗថា " **ប័ណ្ណរបស់ប្អូនៗត្រូវការស្វែងរកគូត្រឹមត្រូវរបស់វា។ ចូរស្វែងរកក្រុមដែលមានគូត្រូវគ្នា**"។ សិស្សត្រូវដើរជុំវិញថ្នាក់រៀនដើម្បីស្វែងរករូបភាព ឬប័ណ្ណលេខដែលត្រូវគ្នាជាមួយនឹងរបស់ដែលខ្លួនមាន។

## II.ការផ្ដែកអំពីរូបភាពនិងរឿងនិទានៈ "បន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំ "

**បន្ទប់រៀនថ្នាក់ទី១ របស់ខ្ញុំ**

នេះគឺជាបន្ទប់រៀនថ្នាក់ទី១របស់ខ្ញុំនៅសាលារៀន ។នៅក្នុងថ្នាក់របស់ខ្ញុំមានវត្ថុផ្សេងៗជាច្រើន។ មានគ្រូនៅខាងមុខថ្នាក់រៀន។ គ្រូសរសេរនៅលើក្តារខៀននឹងដីស។ មានសិស្សអង្គុយនៅតាមតុរបស់ពួកគេ។ នៅលើតុពួកគេមានក្តារឆ្នួន សៀវភៅ និងខ្មៅដៃ។ នៅក្រោយតុមានសំពៀត។ នៅក្នុងថ្នាក់រៀន ខ្ញុំអង្គុយនៅជាប់មិត្តរបស់ខ្ញុំឈ្មោះម៉េរ៉ា ។ខ្ញុំចូលចិត្តបន្ទប់រៀនថ្នាក់ទី១ របស់ខ្ញុំខ្លាំងណាស់។



១. ចូរអានរឿងឱ្យសិស្សស្តាប់ បន្ទាប់មកអានរឿងម្តងទៀតហើយឈប់ម្តងម្កាលដើម្បីឱ្យសិស្សនិយាយពាក្យ បន្ទាប់ឧ. "នេះគឺជា............ថ្នាក់ទី ១របស់ខ្ញុំនៅសាលារៀន ។ នៅក្នុង.........របស់ខ្ញុំ មានរបស់ផ្សេងៗ ជាច្រើន ។

២. ចូរសួរសំណួរដល់សិស្សជាភាសាខ្មែរអំពីថ្នាក់រៀនរបស់ពួកគេ ។

,

| **សំណួរគ្រូ** | **ឧទាហរណ៍ចម្លើយ** |
|---|---|
| តើបន្ទប់រៀនថ្នាក់ទី១របស់ប្អូនមានក្តារខៀនឬទេ? តើវាស្ថិតនៅកន្លែងណា ? | បាទ នៅពីមុខថ្នាក់រៀន ។ |
| តើបន្ទប់រៀនថ្នាក់ទី១របស់ប្អូនមានគ្រូឬទេ? តើគាត់ស្ថិតនៅកន្លែងណា ? | បាទ នៅក្បែរក្តារខៀន ។ |

៣. ចូរចែកក្រដាស និងខ្មៅដៃឱ្យសិស្ស ហើយឱ្យពួកគេគូររូបភាពអ្វីដែលមាននៅក្នុងថ្នាក់រៀនទី១របស់ ពួកគេ ។ ឱ្យសិស្សពន្យល់ពីគំនូររបស់ពួកគេទៅកាន់សិស្សនៅក្នុងថ្នាក់រៀន ។ ឧ. "ខ្ញុំបានគូររូបភាពគ្រូរបស់ខ្ញុំដែលកំពុងសរសេរនៅលើក្តារខៀន" "ខ្ញុំបានគូរមិត្តភក្តិរបស់ខ្ញុំ ណារី ។ នាងកំពុងអង្គុយនៅជិតខ្ញុំ " ។

# មេរៀនទី៤ ការរៀនអំពីសត្វ







| គោលបំណងមេរៀន | ធនធានសម្រាប់បង្រៀន |
|---|---|
| **សិស្សនៅថ្នាក់ទី១ នឹងរៀនៈ** | **សម្ភារមានៈ** |
| • ចំរៀង/កំណាព្យ/មេសូត្រជាភាសាខ្មែរ | • ប័ណ្ណរូបភាពសម្រាប់រៀនលេខ និងឈ្មោះចំនួន |
| • ភាសាបទបញ្ជានៅក្នុងថ្នាក់រៀន | • រូបភាព "គ្រូ និងសិស្ស" |
| • ភាសាជំរាបសួ និងការណែនាំឱ្យស្គាល់គ្នា | • រូបភាព "មិត្តសំលាញ់សត្វរបស់ខ្ញុំ" និងរឿងនិទាន |
| • ចំនួនពី១-១០ | |
| • ការជជែកអំពីរូបភាព | |

ចូរបែងចែងពេលវេលារបស់លោកគ្រូ/អ្នកគ្រូដើម្បីធ្វើសកម្មភាពខ្លីៗពីឈុតសកម្មភាពទាំង៥ខាងក្រោម ។
ចូរព្យាយាមធ្វើសកម្មភាពពី៤ទៅ៥ ខុសៗគ្នានៅក្នុងមេរៀនរយៈពេលមួយម៉ោង របស់លោកគ្រូ/អ្នកគ្រូ ។

## ឈុតសកម្មភាពទី១ ចំរៀង និងការផ្ដែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

**I.ចំរៀង "សត្វទីទុយ "** (លំនាំបទឆោមអើយឆោមឆើត)

**សត្វទីទុយ**



*មានសត្វទីទុយ មួយភ្នែកធំ ស្រែកយំពីលើដើមជ្រៃ*
*ព្រួសូរសំរែក សត្វមៀមព្រៃ ឃ្មាតខ្ចីវាយំឆ្លើយឆ្លង*
*ទីទុយ ទីទុយ ទីទុយ ទីទុយ ។*

១. ចូរប្រាប់សិស្សថា លោកគ្រូ/អ្នកគ្រូនឹងច្រៀងចំរៀងខ្មែរមួយបទអំពីសត្វស្លាបមួយ។ សត្វស្លាបនេះហៅថា សត្វទីទុយ ។ ចូរប្រាប់ឈ្មោះសត្វទីទុយដល់សិស្សជាភាសាកំណើតរបស់សិស្សដើម្បីជួយឱ្យសិស្សងាយយល់។ ចូរសួរសិស្សថា **"តើប្អូនៗស្គាល់សត្វនេះឬទេ?" "តើប្អូនៗអាចរកសត្វនេះនៅក្នុងភូមិបានឬទេ?"**។ ចូរប្រាប់សិស្សថាសត្វ ទីទុយចូលចិត្តចេញរកស៊ីពេលយប់ ហើយមានការលំបាកណាស់ក្នុងការរកវានៅពេលថ្ងៃ។

ចូរឈរនៅខាងមុខថ្នាក់ហើយច្រៀងចំរៀងឱ្យសិស្សស្ដាប់។ ចូរធ្វើកាយវិការនៅពេលដំណាលគ្នានឹងពេល ច្រៀង។ ត្រូវប្រាកដថាសិស្សអាចមើលឃើញច្បាស់នូវកាយវិការរបស់លោកគ្រូ/អ្នកគ្រូ។ សិស្សគ្រាន់តែមើល និងស្ដាប់តែប៉ុណ្ណោះ។

២. ចូរច្រៀងចំរៀងឱ្យសិស្សស្ដាប់ដោយធ្វើកាយវិការ។ សិស្សមើល និងស្ដាប់ បន្ទាប់មកសួរសិស្សថា " **តើនេះជាចំរៀងសប្បាយឬចំរៀងទុក្ខសោក?** "(សិស្សឆ្លើយតប)។ " **តើសត្វទីទុយធ្វើសម្លេងយ៉ាងដូចម្ដេច?**" (សិស្សឆ្លើយ)។ ចូរចែកក្រដាស និងខ្មៅដៃពណ៌ដល់សិស្ស ហើយប្រាប់ពួកគេឱ្យគូររូបសត្វទីទុយ។ ឱ្យសិស្សបិទរូបភាពពួកគេនៅលើក្ដារខៀន។

៣. ចូរច្រៀងចំរៀងដោយធ្វើកាយវិការ។ ឥឡូវនេះ ចូរច្រៀងចំរៀងមួយបន្ទាត់ៗឱ្យយឺតៗ។ សិស្សស្ដាប់ហើយ ច្រៀងតាមលោកគ្រូ/អ្នកគ្រូ។ ចូរច្រៀងចំរៀងមួយបន្ទាត់ៗម្ដងទៀត។ សិស្សស្ដាប់ និងច្រៀងជាមួយ លោកគ្រូ/អ្នកគ្រូ។

៤. ចូរធ្វើការបំពេញឃ្លាដោយផ្ទាល់មាត់។ ច្រៀងចំរៀងម្ដងទៀត។ ច្រៀងមួយបន្ទាត់ៗប៉ុន្តែយូរៗម្ដងត្រូវរំលង ពាក្យខ្លះ។ ចូរឱ្យសិស្សព្យាយាមបំពេញពាក្យដែលបាត់នោះ (ដោយផ្ទាត់មាត់តែប៉ុណ្ណោះ)។

៥. ចូរច្រៀងចំរៀងជាមួយសិស្ស បន្ទាប់មកចែកថ្នាក់ជាពីរ។ ក្រុមមួយច្រៀងចំរៀងនៅបន្ទាត់ទីមួយ និង ក្រុមមួយទៀតច្រៀងចំរៀងនៅបន្ទាត់បន្ទាប់។ ជួយសិស្សនៅពេលដែលចាំបាច់។

៦. ចូរច្រៀងចំរៀងជាមួយសិស្សដោយធ្វើកាយវិការនៅពេលដំណាលគ្នា។ ឥឡូវនេះ ចូរចាប់ផ្តើមច្រៀងចំរៀងម្តងទៀត។ ចូរច្រៀងបន្ទាត់ទីមួយដោយធ្វើកាយវិការ។ សិស្សត្រូវធ្វើតាមកាយវិការរបស់លោកគ្រូ/ អ្នកគ្រូ។ ចូរច្រៀងបន្ទាត់ទីពីរដោយធ្វើកាយវិការ និងជាបន្តបន្ទាប់រហូតដល់បញ្ចប់ចំរៀងទាំងមូល។

៧. ចូរច្រៀងចំរៀងម្តងទៀត។ នៅពេលដែលលោកគ្រូ/អ្នកគ្រូច្រៀង សូមប្រាប់សិស្សឱ្យធ្វើត្រឹមតែកាយវិការប៉ុណ្ណោះ។ ចូរពិនិត្យមើល ថាតើពួកគេចេះធ្វើកាយវិការឬទេ។

៨. ចូរបែងចែកសិស្សជាគូ។ ចូរច្រៀងចំរៀងឱ្យសិស្សស្តាប់ហើយនៅពេលដែលលោកគ្រូ/អ្នកគ្រូច្រៀង គូនីមួយៗត្រូវធ្វើកាយវិការទាំងអស់គ្នា។ ចូរច្រៀងចំរៀងម្តងទៀត។ ចូរឱ្យសិស្សព្យាយាមច្រៀងនិងធ្វើកាយវិការនៅពេលដំណាលគ្នា

៩. ចូរប្រាប់ឱ្យថ្នាក់ទាំងមូលក្រោកឈរ និងច្រៀងចំរៀងជាមួយលោកគ្រូ/អ្នកគ្រូ ដោយមានធ្វើកាយវិការ។

## II.ការចែកចាយរូបភាពនិងរឿងនិទាន "មិត្តសំលាញ់សត្វរបស់ខ្ញុំ"

    

**បញ្ជីពាក្យជាភាសាខ្មែរ**

| | | | | | |
|---|---|---|---|---|---|
| សត្វ | ក្របី | ភូមិ | វែង | ពណ៌ខ្មៅ | ពណ៌ត្នោត |
| មាន់ | គោ | អូរ | ខ្លី | ពណ៌ស | ពណ៌ផ្កាឈូក |
| ជ្រូក | ឆ្កែ | ធំ | តូច | ពណ៌បៃតង | |

១. មេរៀននេះគឺជាមេរៀន **ធ្វើ និយាយ កត់ត្រា**។ ចូរធ្វើសកម្មភាពនេះជាមួយសិស្សជាភាសាកំណើតរបស់សិស្ស។ ក្នុងមេរៀននេះអ្នកនឹងប្រើប្រាស់ផ្ទាំងក្រដាសធំសម្រាប់កត់ត្រាបញ្ជីឈ្មោះសត្វ។

**ធ្វើ**

សួរសំណួរមួយចំនួនដល់សិស្សអំពីប្រភេទសត្វដែលពួកគេបានស្គាល់រួចហើយ។

| សំណួរគ្រូ | ឧទាហរណ៍ចម្លើយ |
|---|---|
| តើប្អូនៗឃើញសត្វអ្វីខ្លះនៅក្បែរផ្ទះ? | ជ្រូក? ឆ្កែ? មាន់? |
| តើជ្រូក/ឆ្កែ/មាន់ ធ្វើសម្លេងដូចម្តេច? | សិស្សឆ្លើយដោយធ្វើជាសម្លេងសត្វទាំងនោះ |

នាំសិស្សទៅកាន់កសិដ្ឋាននៅក្បែរនោះឬក៏នាំដើរតាមភូមិ។

**និយាយ**

សួរសំណួរមួយចំនួនដល់សិស្សអំពីសត្វផ្សេងៗដែលពួកគេឃើញនៅក្នុងពេលកំពុងដើរ ។

| សំណួរគ្រូ | ឧទាហរណ៍ចម្លើយ |
|---|---|
| តើប្អូនៗមានឃើញសត្វជ្រូក/ឆ្កែ/មាន់ឬទេ? នៅឯណា? | សិស្សឆ្លើយ ។ សិស្សចង្អុល |
| តើសត្វទាំងនេះមានពណ៌អ្វីខ្លះ? ពណ៌ផ្កាឈូក? ខ្មៅ? ត្នោត? | សិស្សឆ្លើយ |
| តើសត្វទាំងនេះមានជើងប៉ុន្មាន? | ជើង២? ជើង ៤? |
| តើសត្វទាំងនេះធ្វើសម្លេងដូចម្តេចខ្លះ? | សិស្សឆ្លើយតបដោយធ្វើសម្លេងសត្វ |

**កត់ត្រា**

ត្រឡប់មកកាន់ថ្នាក់រៀនវិញ ។ ចូរបង្កើតបញ្ជីឈ្មោះសត្វជាមួយសិស្សដែលពួកគេឃើញនៅក្នុងភូមិនៅលើផ្ទាំងក្រដាសធំជាភាសាកំណើតរបស់សិស្ស ។ ចូរអានពាក្យទាំងនេះជាមួយសិស្ស ។ (**រក្សាបញ្ជីឈ្មោះសត្វសម្រាប់ប្រើប្រាស់ពេលក្រោយ**)

២. បិទបញ្ជីឈ្មោះសត្វពីសកម្មភាពទី១នៅលើក្តារខៀន ។ ចូរចង្អុលអក្សរហើយឱ្យសិស្សអានឈ្មោះសត្វជាភាសាកំណើតរបស់សិស្ស ។ សួរសិស្សនូវសំណួរ " **តើមានប៉ុន្មាន** " អំពីសត្វនៅក្នុងបញ្ជី ។

| តើមានសត្វប៉ុន្មានដែល | មានជើង២ ជើង៤?<br>មានកន្ទុយវែង/កន្ទុយខ្លី?<br>មានពណ៌ត្នោត/ពណ៌ខ្មៅ?<br>ជាសត្វធំ/សត្វតូច? |
|---|---|

៣. ចូរបិទក្រដាសផ្ទាំងធំនោះនៅលើក្តារខៀន (សកម្មភាពទី១) ។ ចែកក្រដាសខ្លះ និងខ្មៅដៃពណ៌ដល់សិស្ស ។ ឱ្យពួកគេជ្រើសរើសសត្វដែលគេចូលចិត្តពីក្នុងបញ្ជី ហើយគូររូបសត្វនោះ ។ ជួយសិស្សក្នុងការសរសេរឈ្មោះសត្វនៅពីក្រោមរូប ។ ប្រាប់សិស្សឱ្យបង្ហាញរូបភាពពួកគេដល់ថ្នាក់ទាំងមូល ហើយពណ៌នាអំពីវា ។ សួរសំណួរមួយចំនួនជាភាសាកំណើតរបស់សិស្សដល់សិស្ស " **តើប្អូនគូររូបសត្វអ្វី? តើវាមានកន្ទុយឬទេ? តើវាមានពណ៌អ្វី? តើវាធ្វើ សម្លេងដូចម្តេច?** " ។ ចូររក្សាទុករូបភាពទាំងនេះដើម្បីធ្វើជាសៀវភៅ ។

៤. ចូរបង្ហាញរូបភាពសត្វដល់សិស្សហើយប្រាប់សិស្សអំពីរូបភាពនោះជាភាសាកំណើតរបស់សិស្ស ។

**នេះជាមាន់ ។ វាមានពណ៌ខ្មៅ និងក្រហម ។ វាមានកូនជាច្រើន ។**

**នេះជាជ្រូក ។ វាធំ និងមានពណ៌ផ្កាឈូក ។ វាក៏មានកូនខ្លះដែរ ។**

**នេះជាគោ ។ គោនេះធំ ហើយមានពណ៌ត្នោត ។ គោនេះមានកន្ទុយវែងមួយ ។**

**នេះជាក្របី ។ ក្របីនេះធំ ហើយមានពណ៌ខ្មៅ ។ វាមានកូនមួយ ។**

**នេះជាឆ្កែ ។ ឆ្កែនេះពណ៌ខ្មៅ និងមានកន្ទុយវែងពណ៌ខ្មៅ ។**

៥. ចូរបង្ហាញរូបភាពដល់សិស្ស ហើយសួរសំណួរជាភាសាកំណើតរបស់សិស្សអំពីរូបភាពនោះ ។

| សំណួរគ្រូ | ឧទាហរណ៍នៃចម្លើយ |
|---|---|
| តើប្អូនៗឃើញមានសត្វប៉ុន្មាននៅក្នុងរូបភាពនេះ? | សត្វប្រាំ |
| តើប្អូនៗឃើញមានសត្វអ្វីខ្លះ? | ជ្រូក/គោ/ក្របី/មាន់/ឆ្កែ |
| តើសត្វណាខ្លះមានកន្ទុយវែង/ខ្លី? | សិស្សឆ្លើយ |
| តើសត្វចំនួនប៉ុន្មានដែលមានជើងបួន? | សិស្សឆ្លើយ |
| តើសត្វចំនួនប៉ុន្មានដែលមានពណ៌ខ្មៅ? | សិស្សឆ្លើយ |

## ឈុតសកម្មភាពទី២ បទបញ្ជាក្នុងថ្នាក់រៀន និងការជជែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ជំហាន)**

### I. បទបញ្ជាក្នុងថ្នាក់រៀន

សូមក្រោកឈរឡើង



សូមអង្គុយចុះ



សូមប្អូនៗលើកដៃឡើង



សូមឈប់ជជែកគ្នា

សូមប្អូនៗយកក្តារឆ្នួន និងដីសចេញមក

សូមឡើងក្តារខៀន



សូមស្តាប់

សូមថាតាមខ្ញុំ

១. សូមប្រើភាសាកំណើតរបស់សិស្សដើម្បីណែនាំបទបញ្ជាថ្នាក់រៀនថ្មីពីរ " សូមឡើងក្តារខៀន " និង "សូមថាតាមខ្ញុំ" ។ បង្ហាញ ការណែនាំ ។ សិស្សមើល និងស្តាប់ បន្ទាប់មកសិស្សត្រូវអនុវត្តទៅតាមគំរូ ។

២. ចូរប្រាប់បទបញ្ជានេះជាភាសាខ្មែរវិញ ហើយសួរសិស្សថា " **តើយើងអានពាក្យនេះជាភាសាកំណើតរបស់សិស្សយ៉ាងដូចម្តេច?**" ។

៣. ចូររំលឹកបទបញ្ជាទាំងអស់នោះដោយហៅសិស្ស៤នាក់ឡើងក្តារខៀន។ ចូរផ្តល់បទបញ្ជា (ឧទាហរណ៏: **សូមលើកដៃឡើង**) សិស្សត្រូវស្តាប់ និងធ្វើនូវអ្វីដែលអ្នកប្រាប់។ ឥឡូវនេះចូរផ្តល់បទបញ្ជាចំនួន២ (ឧទាះរណ៏: **សូមលើកដៃឡើង ហើយដើរទៅក្តារខៀន**)។ សិស្សត្រូវស្តាប់ និងធ្វើនូវអ្វីដែលអ្នកប្រាប់។

៤. ចូរចែកសិស្សពី៤ទៅ៥ក្រុមហើយតែងតាំងសិស្សម្នាក់នៅក្នុងក្រុមឱ្យធ្វើជាគ្រូ។ គ្រូនោះត្រូវផ្តល់បទបញ្ជាផ្សេងៗទៅឱ្យក្រុម។ ក្រុមត្រូវស្តាប់ និងធ្វើតាមអ្វីដែលបានប្រាប់។

៥. ចូរអនុវត្តនូវបទបញ្ជាថ្មីជារៀងរាល់ថ្ងៃ។ ជាដំបូងត្រូវនិយាយបទបញ្ជានោះជាភាសាសិស្ស។ ត្រូវធ្វើគំរូឱ្យសិស្សមើល។ និយាយបទបញ្ជានោះម្តងទៀតជាភាសាខ្មែរ។ ត្រូវធ្វើជាគំរូឱ្យសិស្សមើល។

៦. ចូរសម្តែងតួអំពីការផ្តល់បទបញ្ជា ដោយឱ្យសិស្សនិយាយបទបញ្ជានោះជាភាសាខ្មែរ។

៧. សិស្សជ្រើសរើសបទបញ្ជា១ ហើយផ្តល់វាទៅឱ្យសិស្សដទៃទៀតនៅក្នុងថ្នាក់ជាភាសាខ្មែរ។ សិស្សដទៃទៀតធ្វើការឆ្លើយចម្លើយដែលសមស្រប។

៨. ចូរចែងសិស្សជាក្រុមតូចៗ។ សិស្សម្នាក់ៗសម្តែងបទបញ្ជាមួយឱ្យក្រុមបានមើល។ សមាជិករបស់ក្រុមធ្វើការទស្សន៏ទាយបទបញ្ជាហើយសួរថាវាជាបទបញ្ជាអ្វី។

៩. ឱ្យសិស្សគូររូបភាព ហើយគូសភ្ជាប់ទៅនឹងបទបញ្ជានីមួយៗ បន្ទាប់មកសិស្សបកស្រាយគំនូររបស់ពួកគេទៅឱ្យសិស្សផ្សេងទៀតស្តាប់។ ចូរធ្វើការទស្សន៏ទាយបទបញ្ជាដែលភ្ជាប់ទៅនឹងរូបភាព។

## II.ការផដែកពីរូបភាពនិងរឿងនិទាន "មិត្តសំលាញ់សត្វរបស់ខ្ញុំ"

    

១. ចូរបង្ហាញរូបភាពសត្វដល់សិស្ស និងប្រាប់សិស្សអំពីរូបភាពនោះជាភាសាខ្មែរ។ ចូរប្រើភាសាកំណើតរបស់សិស្សដើម្បី ជួយសិស្សឱ្យយល់។

**នេះជាមាន់។ វាមានពណ៌ខ្មៅ និងក្រហម។ វាមានកូនជាច្រើន។**

**នេះជាជ្រូក។ វាធំ និងមានពណ៌ផ្កាឈូក។ វាក៏មានកូនខ្លះដែរ។**

**នេះជាគោ។ គោនេះធំ ហើយមានពណ៌ត្នោត។ គោនេះមានកន្ទុយវែងមួយ។**

**នេះជាក្របី។ ក្របីនេះធំ ហើយមានពណ៌ខ្មៅ។ វាមានកូនមួយ។**

**នេះជាឆ្កែ។ ឆ្កែនេះពណ៌ខ្មៅ និងមានកន្ទុយវែងពណ៌ខ្មៅ។**

២. បង្ហាញរូបភាពដល់សិស្ស។ នៅលើកនេះចូរសួរសំណួរសិស្សអំពីរូបភាពជាភាសាខ្មែរ។ ជួយសិស្សដោយប្រើភាសាកំណើតរបស់សិស្សនៅពេលដែលពួកគេមិនយល់។

| សំណួរគ្រូ | ឧទាហរណ៍នៃចម្លើយ |
|---|---|
| តើប្អូនៗឃើញមានសត្វប៉ុន្មាននៅក្នុងរូបភាពនេះ? | សត្វប្រាំ |
| តើប្អូនៗឃើញមានសត្វអ្វីខ្លះ? | ជ្រូក/គោ/ក្របី/មាន់/ឆ្កែ |
| តើសត្វណាខ្លះមានកន្ទុយវែង/ខ្លី? | សិស្សឆ្លើយ |
| តើសត្វចំនួនប៉ុន្មានដែលមានជើងបួន? | សិស្សឆ្លើយ |
| តើសត្វចំនួនប៉ុន្មានដែលមានពណ៌ខ្មៅ? | សិស្សឆ្លើយ |

៣. ចូរបិទផ្ទាំងក្រដាសធំអំពីបញ្ជីឈ្មោះសត្វ (**បញ្ជីនេះយកមកពីឈុតសកម្មភាពទី១ក្នុងសកម្មភាពទី១ផ្នែក II-ការជជែកអំពីរូបភាព**) នៅលើក្ដារខៀន។ អានពាក្យគំណើតរបស់សិស្សជាមួយសិស្ស។ ចូរបកប្រែពាក្យទាំងនេះជាភាសាខ្មែរឱ្យសិស្ស។ សូមកុំសរសេរការបកប្រែជាខ្មែរ។ ត្រូវធ្វើដោយផ្ទាល់មាត់តែប៉ុណ្ណោះ។ ចូរអានពាក្យគំណើតរបស់សិស្សម្ដងទៀត។ ចូរប្រាប់សិស្សឱ្យព្យាយាមចងចាំនូវការបកប្រែពាក្យទាំងនេះជាភាសាខ្មែរ (ដោយផ្ទាល់ មាត់តែប៉ុណ្ណោះ)។ ចូរជួយសិស្សនៅពេលដែលចាំបាច់។

៤. ចូរបិទផ្ទាំងក្រដាសធំពីបញ្ជីឈ្មោះសត្វ (**បញ្ជីនេះយកមកពីឈុតសកម្មភាពទី១ក្នុងសកម្មភាពទី១ផ្នែកII-ការជជែកអំពីរូបភាព**) នៅលើក្ដារខៀន។ ចូរឱ្យសិស្សអានបញ្ជីពាក្យគំណើតរបស់សិស្សឱ្យលោកគ្រូ/អ្នកគ្រូស្ដាប់ និងឱ្យ ពួកគេព្យាយាមបកប្រែពាក្យទាំងនេះជាភាសាខ្មែរ (ដោយផ្ទាល់មាត់តែប៉ុណ្ណោះ)។ ចូរសរសេរការបកប្រែជាភាសាខ្មែរ។ ចូរអានបញ្ជីពាក្យទាំងពីរឱ្យសិស្សស្ដាប់។ ចូរអានបញ្ជីពាក្យទាំងនោះជាមួយសិស្ស ។

៥. ចូរបង្ហាញរូបភាពសត្វហើយសួរសិស្សជាភាសាខ្មែរ "**តើប្អូនៗមើលឃើញសត្វអ្វីខ្លះ?**" (ជ្រូក, មាន់ . . .)។ "**តើសត្វណាខ្លះដែលមានពណ៌ខ្មៅ?**" (សិស្សឆ្លើយ) "**តើសត្វណាខ្លះដែលមានជើង២?**" (សិស្សឆ្លើយ) "**តើសត្វណាខ្លះដែលមានកន្ទុយវែង?**" (សិស្សឆ្លើយ)។

ចូរចែកក្រដាសខ្លះ និងខ្មៅដៃពណ៌ឱ្យសិស្ស។ ចូរប្រាប់សិស្សថាលោកគ្រូ/អ្នកគ្រូនឹងធ្វើការពណ៌នាអំពីប្រភេទសត្វថ្មី។ សិស្សត្រូវតែស្ដាប់ និងគូរនូវអ្វីដែលលោកគ្រូ/អ្នកគ្រូនិយាយ។ ចូរធ្វើការពណ៌នាឱ្យសិស្សស្ដាប់ពីរឬ បីដង។

សត្វនេះធំណាស់។ វាមានកន្ទុយពណ៌ខ្មៅយ៉ាងវែង។ វាមានជើងខ្លីៗចំនួន៥ដែលមានពណ៌ផ្កាឈូក។ វាមានកូនចំនួន៧ ។

ចូរឱ្យសិស្សប្រៀបធៀបរូបភាពពួកគេជាមួយដៃគូ។ ចូរសួរសិស្ស "**តើសត្វនេះមានជើងប៉ុន្មាន?**" (៥) "**តើជើងទាំងនោះវែង ឬ ខ្លី?**" (ខ្លី) "**តើជើងទាំងនោះមានពណ៌ផ្កាឈូក ឬពណ៌ត្នោត?** " (ផ្កាឈូក)។

ចូរឱ្យសិស្សទាំងអស់បិទរូបភាពពួកគេនៅលើក្ដារខៀន។ ចូរអានការពណ៌នាម្ដងទៀត។ ចូរពិនិត្យមើលថាតើសិស្សគូរបានត្រឹមត្រូវឬទេ។

## ឈុតសកម្មភាពទី៣ ការស្វាគមន៍គ្នា និងការផ្ដែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការស្វាគមន៍គ្នា:

ឧទាហរណ៍ **អរុណសួស្តី ។ តើអ្នកសុខសប្បាយឬទេថ្ងៃនេះ?** (ខ្ញុំសុខសប្បាយជាទេ អរគុណ)

**សាយ័ណសួស្តី ។**

១. ចូរធ្វើការណែនាំការស្វាគមន៍ជាភាសាខ្មែរ ដោយឱ្យសិស្សអានតាម ។

២. និយាយការស្វាគមន៍នោះ ។ សិស្សឆ្លើយចម្លើយដែលសមស្រប ។

៣. សិស្សធ្វើការសម្តែងជាមួយដៃគូដោយគ្រូសម្តែងជាមួយសិស្សឬសិស្សជាមួយសិស្សដូចគ្នា ។

### ការប្រើប្រាស់រូបភាព



៤. ប្រើរូបភាព ហើយសួរសំណួរជាភាសាកំណើតរបស់សិស្ស ។ ឧទ **"តើមនុស្សទាំងអស់នេះជាអ្នកណា?" តើពួកគេនៅឯណា ?" " តើស្រីម្នាក់នោះកំពុងនិយាយអ្វីទៅកាន់សិស្សី?"** ។ល ។

៥. ចូរប្រើរូបភាព និងធ្វើសកម្មភាពដូចពេលមុន ប៉ុន្តែពេលនេះប្រើវាជាភាសាខ្មែរ ។

៦. ប្រើភាសាកំណើតរបស់សិស្ស ។ ចូរប្រាប់សិស្សអំពីភាពខុសគ្នានៅក្នុងរូបភាពថា " **នេះជាក្តារខៀន / ជាទូរ / ជាគ្រូបង្រៀន** " ។ល ។ បន្ទាប់មកសួរសិស្ស " **តើនេះជាអ្វី ?** " (នេះជាក្តារខៀន) ។ល ។

៧. ចូរធ្វើសកម្មភាពដូចពេលមុនប៉ុន្តែពេលនេះប្រើវាជាភាសាខ្មែរបានហើយ ។

៨. ប្រើរូបភាព ហើយអានការសន្ទនា២ទៅ៣ដងឱ្យសិស្សស្តាប់ ។ សិស្សស្តាប់ ។

**គ្រូះ** អរុណសួរស្តី មីរ៉ា ។ តើប្អូនសុខសប្បាយជាទេថ្ងៃនេះ ?

**សិស្សះ** ខ្ញុំសុខសប្បាយជាទេ អរគុណ ។ តើអ្នកគ្រូសុខសប្បាយជាទេថ្ងៃនេះ?

**គ្រូះ** សុខសប្បាយជាទេ អរគុណ ។ តើអ្នកគ្រូអាចជួយមើលលំហាត់ផ្ទះរបស់ប្អូនៗបានទេ ?

**សិស្សះ** ចាស់ អ្នកគ្រូ

៩. ចូរប្រើរូបភាព និងការសន្ទនាម្តងទៀត ។ អានការសន្ទនា ។ សិស្សអានតាម ។

១០. សម្តែងការសន្ទនាជាមួយសិស្សដទៃទៀតនៅក្នុងថ្នាក់រៀន ។ អ្នកត្រូវសម្តែងតួជាគ្រូ ។ សិស្សឆ្លើយ ។

១១. ចូរបែងចែងសិស្សជាពាក់កណ្ដាល ។ ពាក់កណ្ដាលសម្ដែងតួជាគ្រូ ឯពាក់កណ្ដាលទៀតសម្ដែងតួជា សិស្ស ។

## II. ការចជែកពីរូបភាពនិងរឿងនិទាន "មិត្តសំលាញ់សត្វរបស់ខ្ញុំ"

    

១. <u>ការសម្ដែងតួ</u>

សិស្សនឹងសម្ដែងតួជាក្រុមអំពីសត្វនៅក្នុងរូបភាព ។ ចូរចែកថ្នាក់ទាំងមូលទៅជា៥ក្រុម ។ ក្រុមនីមួយៗតំណាងឱ្យសត្វមួយ ( មាន់/ជ្រូក/ក្របី/គោ/ឆ្កែ) ។ ចូរទុកពេល៥នាទីឱ្យសិស្សគិតអំពីសត្វពួកគេ ។

**សំណួរសម្រាប់ក្រុម**

តើសត្វរបស់ប្អូនៗធំឬទេ? តូច? ពណ៌ត្នោត? ពណ៌ខ្មៅ?

*តើវាមានកន្ទុយវែងឬទេ?*

*តើវាមានសម្លេងដូចម្ដេច?*

*តើវាដើរដូចម្ដេច?*

សិស្សនៅក្នុងក្រុមសត្វនីមួយៗនឹងសម្ដែងតួអំពីសត្វរបស់ពួកគេឱ្យសិស្សក្នុងថ្នាក់មើល ។ សិស្សក្នុងថ្នាក់ត្រូវធ្វើការទស្សន៍ទាយអំពីសត្វដែលគេសម្ដែងតួ និងត្រូវនិយាយថាតើពួកគេស្គាល់សត្វនោះយ៉ាងដូចម្ដេច ។

២. ចូរបិទរូបភាពនៅលើក្ដារខៀន ហើយអានរឿងទិនានអំពីរូបភាព ។ សិស្សគ្រាន់តែស្ដាប់ប៉ុណ្ណោះ ។

៣. ចូរអានរឿងនិទានឱ្យសិស្សស្ដាប់ម្ដងទៀត និងចង្អុលទៅកាន់សត្វនៅក្នុងរូបភាពព្រមទាំងប្រាប់សិស្សអំពីសត្វទាំងនេះជាភាសាខ្មែរ ។ ឧទាហរណ៍: " **នេះគឺជាសត្វជ្រូក ។ វាធំ និងមានពណ៌ផ្កាឈូក ។ វាមានកន្ទុយតូចមួយ** "។ល។ ឥឡូវនេះ ចូរចង្អុលទៅសត្វផ្សេងទៀត និងសួរសិស្សជាភាសាខ្មែរ " **តើនេះជាសត្វអ្វី?**" **តើវាមានពណ៌អ្វី?**" ។ ល ។

*អ្នកស្រីមាន់ និងកូនរបស់គាត់ទាំង៩នាក់រស់នៅក្នុងភូមិតូចមួយនៅជាប់នឹងដងអូរ ។ ផ្ទះរបស់អ្នកស្រីមាន់ ស្ថិតនៅខាងមុខអូរ ។ អ្នកស្រីមាន់ និងគ្រួសារគាត់មានមិត្តភ័ក្ដិជាច្រើនដែលរស់នៅក្នុងភូមិនេះ ។ មានអ្នកស្រីជ្រូក ។ គាត់ធាត់ និងមានសំបុរពណ៌ផ្កាឈូក និងមានកន្ទុយតូចមួយ ។ មានអ្នកស្រីក្របី ។ គាត់ធាត់ និងមានសំបុរខ្មៅ ។ គាត់មានកូនម្នាក់ដែលនៅតូច និងសំបុរខ្មៅ ។ មានអ្នកស្រីគោ ។ អ្នកស្រីគោមានសំបុរត្នោតហើយមានកន្ទុយវែង ។ និងមាន លោកឆ្កែ ។ គាត់មិនធំទេ ។ គាត់មិនតូចទេ ប៉ុន្តែគាត់មានសំបុរខ្មៅស្រិល ។ អ្នកស្រីមាន់ និងគ្រួសារគាត់ចូលចិត្តមិត្តភ័ក្ដិសត្វពួកគាត់យ៉ាងខ្លាំង ។*

៤. ចូររំលឹកពាក្យខ្មែរឡើងវិញដើម្បីធ្វើតេស្តការចងចាំរបស់សិស្ស។ ចូរបង្ហាញរូបភាពដល់សិស្សរយៈពេល២ នាទី។ រួចសួរសំណួរខ្លះ " **តើនេះជាសត្វអ្វី? តើវាធំឬតូច?** "។ល។ ចូរគ្របរូបភាព។ ដោយឱ្យសិស្ស ធ្វើការជាគូ ចូរឱ្យពួកគេធ្វើការចងចាំសត្វនៅក្នុងរូបភាពឱ្យបានច្រើនតាមតែពួកគេអាចចាំបាន។ ចូរសួរអំពីគំនិតរបស់គូនីមួយៗ។ ចូរបើករូបភាពវិញ និងធ្វើការផ្ទៀងផ្ទាត់មើលតើមានគំនិតប៉ុន្មានដែលត្រឹមត្រូវ។ **"តើយើងមានភ្លេចអ្វីទេ? គឺអ្វី?"** (សិស្សឆ្លើយ)។

៥. ចូរអានរឿងនិទានឱ្យសិស្សស្តាប់ហើយប្រាប់ថា **"ចូរទះដៃនៅពេលដែលប្អូនៗឮខ្ញុំនិយាយពាក្យអំពីពណ៌ "ពណ៌ខ្មៅ"**។ ចូរអានរឿងនិទានម្តងទៀតហើយប្រាប់សិស្សថា " **ចូររាប់ចំនួនដងដែលប្អូនៗឮពាក្យ "ពណ៌ខ្មៅ" នៅក្នុងរឿងនិទាន** " (បីដង)។

៦. ចូរបិទរូបភាពនៅលើក្តារខៀន។ ហៅសិស្ស២នាក់ឱ្យឡើងមកក្តារខៀន ហើយឱ្យឈរប្រហែល២ម៉ែត្រពីក្តារខៀន។ ចូរប្រាប់ពួកគេថា លោកគ្រូ/អ្នកគ្រូនឹងពណ៌នាសត្វមួយនៅក្នុងរូបភាព។ ពួកគេត្រូវតែស្តាប់ការពណ៌នារបស់លោកគ្រូ/អ្នកគ្រូ បន្ទាប់មកត្រូវទះសត្វនៅក្នុងរូបភាពដែលត្រូវតាមការពណ៌នា។
*ឧទា: **សត្វនេះមានពណ៌ត្នោត និងមានកន្ទុយវែង** ។សិសត្រូវទះរូបភាពរបស់<u>សត្វគោ</u>។ ចូរលេងម្តងទៀត* ជាមួយសិស្ស២នាក់ទៀតដោយពិពណ៌នាពីសត្វផ្សេងទៀត។

៧. ចូរធ្វើការបំពេញប្រយោគដោយផ្ទាល់មាត់។ ចូរអានរឿងនិទានឱ្យសិស្សស្តាប់។ ចូរអានរឿងនិទានម្តងទៀត ។ យូរៗឈប់ម្តង និងទុកឱ្យសិស្សបំពេញពាក្យបន្ទាប់ " **មានអ្នកស្រីជ្រូក។ គាត់ធាត់ និង .........និងមាន ...........តូចមួយ** "

## ឈុតសកម្មភាពទី៤ ការរៀនលេខនិងការប្រកបលេខ និងការបំផែកអំពីរូបភាព

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការរៀនលេខនិងការប្រកបចំនួន:

បណ្ណរូបភាពសម្រាប់រៀនលេខ

១. ចុរបង្រៀនសិស្សពីលេខ១ដល់លេខ៥ ជាភាសាខ្មែរដោយប្រើសម្ភារពិត។ ចូរបង្ហាញខ្មៅដៃដល់សិស្សហើយប្រាប់ថា "នេះគឺជា ខ្មៅដៃ "។ បន្ទាប់មកសួរសិស្សថា "តើមានខ្មៅដៃចំនួនប៉ុន្មាន?"(១) ។គ្រូបន្តលើកខ្មៅដៃឡើង និងប្រាប់ថា"មានខ្មៅដៃពីរ ។ហើយសួរ ថា"តើមានខ្មៅដៃប៉ុន្មាន?"(២)។ គ្រូធ្វើបន្តរហូតដល់អស់លេខពីលេខ១ ដល់លេខ៥។

| | |
|---|---|
| ១<br>មួយ | សាលារៀន |
| ២<br>ពីរ | សិស្សា |
| ៣<br>បី | ដុំដីស |
| ៤<br>បួន | សិស្សី |
| ៥<br>ប្រាំ | ខ្មៅដៃ |

| | |
|---|---|
| ៦<br>ប្រាំមួយ | ក្តារឆ្នួន |
| ៧<br>ប្រាំពីរ | សៀវភៅ |
| ៨<br>ប្រាំបី | គ្រូ |
| ៩<br>ប្រាំបួន | សំពៀត |
| ១០<br>ដប់ | សិស្ស |

២. ចូរធ្វើសកម្មភាពដូចគ្នា ប៉ុន្តែពេលនេះចូរណែនាំសិស្សពីលេខ៦ដល់លេខ១០ដោយប្រើសម្ភារពិត ។

៣. នៅក្នុងក្រុម ចូររំលឹកពីលេខ១ដល់១០ដោយប្រើសម្ភារពិត (ឧទាហរណ៍ : ប៊ិច និងខ្មៅដៃ )។ ចូរចែកសិស្សជាក្រុមតូចៗ។ សិស្សម្នាក់នៅក្នុងក្រុមគួរតែបង្ហាញខ្មៅដៃឬប៊ិចខ្លះ ហើយសួរថា "តើមានខ្មៅដៃឬប៊ិច ប៉ុន្មាន ? " ។ អ្នកផ្សេងទៀតនៅក្នុងក្រុមឆ្លើយ ។ សិស្សម្នាក់នៅក្នុងក្រុមដាក់វេនគ្នាសួរ " តើមាន......?" ។

៤. មានរូបភាព១ ចូរពិភាក្សាគ្នាពីប័ណ្ណរូបភាពពី១ដល់១០ ដោយប្រើភាសាកំណើតរបស់សិស្ស ។ ចូរសួរសំណួរដល់សិស្សជា ភាសារបស់ពួកគេអំពីរូបភាពថា"**តើប្អូនមើលឃើញអ្វីខ្លះ? តើប្អូនមើលឃើញមនុស្សប៉ុន្មាននាក់? តើពួកគេ ជាអ្នកណា?** " (សិស្សឆ្លើយដោយប្រើភាសារបស់ពួកគេ) ។

៥. ចូរប្រើប័ណ្ណរូបភាពដូចគ្នាពីលេខ១ដល់១០តែពេលនេះនិយាយជាមួយសិស្សដោយប្រើភាសាខ្មែរ ។ " **នេះជាសាលារៀន ។ " ហើយឥឡូវនេះចូរប្អូនៗនិយាយជាភាសារបស់ប្អូនៗ ?** " (សិស្សឆ្លើយជាភាសារបស់ពួកគេ ) " **មានសិស្សា ២ នាក់ ។ "ចូរប្អូននិយាយវាជាភាសារបស់ប្អូន ?** " (សិស្សឆ្លើយជាភាសារបស់ពួកគេ) ។

៦. ចូររំលឹកប័ណ្ណពីលេខ១ដល់១០ដោយប្រើភាសាខ្មែរ ។ ចូរប្រាប់សិស្ស " នេះជាសាលារៀន១ ។ ចូរសួរសិស្ស " **តើវាជាអ្វី ?** " (សាលារៀនមួយ) ។ មានសិស្សា២នាក់ ។ "**តើមានសិស្សាចំនួនប៉ុន្មាននាក់ ?** " (២) ។

៧. ចូរលើកប័ណ្ណរូបភាពខុសៗគ្នាទៅតាមលំដាប់លំដោយ រួចសួរសិស្សថា "តើមាន...............ដែលប្អូនអាចមើលឃើញ? ចូរចែកសិស្សជា៥ក្រុមហើយឱ្យរូបភាព២ទៅឱ្យក្រុមនីមួយៗ ។ ឱ្យក្រុមទាំងមូលប្រាប់គ្នាទៅវិញទៅមកពីរូបភាព ។ ចូរធ្វើការផ្លាស់ប្តូរប័ណ្ណរូបភាពជុំវិញក្រុម ។

៨. ចូររំលឹកលេខពី១-១០ម្តងទៀតហើយបិទរូបភាពនៅលើក្តារខៀន ដោយកុំឱ្យត្រូវតាមលំដាប់លំដោយ ។ ឱ្យសិស្សផ្សេងៗគ្នា ឡើងក្តារខៀនដើម្បីជួយគ្នាក្នុងការតំរៀបរូបភាពឱ្យត្រូវទៅតាមលំដាប់លំដោយ ពី១-១០ ។ ប័ណ្ណទី ១ ជា " **សាលារៀន**" ប័ណ្ណទី២ ជា "**សិស្ស ២ នាក់** "។ល ។ ក្រុមទាំងមូលអាចជួយគ្នា ។

៩. ចូរប្រើសម្ភារពិតដើម្បីរំលឹកលេខ និងពាក្យថ្មីជាភាសាខ្មែរ ។ ចូរប្រាប់សិស្សថា "**បង្ហាញខ្មៅដៃ៤ ដល់ខ្ញុំ** "។ សិស្សត្រូវលើកខ្មៅដៃ៤ឡើង ។ គ្រូបន្តប្រាប់ " **បង្ហាញកាតាប៣ដល់ខ្ញុំ** "។ល ។

១០. ចូរណែនាំលេខជាភាសាខ្មែរដល់សិស្ស ។ ចូរគ្របការប្រកបលេខសម្រាប់សកម្មភាពនេះ ។ ចូរចង្អុលលេខនីមួយៗហើយប្រាប់សិស្សថា " **នេះគឺជាលេខ ១** " ។ **តើនេះជាលេខប៉ុន្មាន ?** " (លេខ ១ ) ។ " **នេះជាលេខ២ ។ល ។** "

១១. **មើល គ្រប សរសេរ ផ្ទៀងផ្ទាត់** លេខពី១-១០ ។ ចូរគ្របការប្រកបលេខសម្រាប់មេរៀននេះ ។ ចូរលើកប័ណ្ណឡើងហើយសួរថា "**តើនេះជាលេខប៉ុន្មាន ?** " (លេខ ២) ។ គ្របប័ណ្ណ ។ ឱ្យសិស្សសរសេរលេខដាក់នៅលើក្តារឆ្នួនរបស់ពួកគេ ។ ចូរឱ្យសិស្ស " លើកក្តារឆ្នួនឡើង " ។ បើកប័ណ្ណឡើងវិញដើម្បីពិនិត្យមើល ។

១២. ចែកសិស្សជាក្រុមចំនួន១០នាក់ហើយឱ្យប័ណ្ណលេខទៅក្រុមនីមួយៗ ។ ចូរគ្របការប្រកបលេខសម្រាប់សកម្មភាពនេះ ។ ហៅសិស្សម្នាក់នៅក្នុងក្រុមឱ្យឡើងក្តារខៀនហើយប្រាប់សិស្សថា " **ចូរដាក់ប័ណ្ណលេខឱ្យត្រូវទៅតាមលំដាប់លំដោយពី១-១០**" ។ សិស្សនៅក្នុងថ្នាក់ទាំងមូលអាចជួយបាន ។

១៣. ចូរណែនាំសិស្សនូវការប្រកបពី១-១០ ។ ចូរលើកប័ណ្ណពី១-១០ឡើងហើយចង្អុលទៅលេខនិងសួរថា "**តើនេះជាលេខប៉ុន្មាន?**" (លេខ ១) ។ ចង្អុលទៅពាក្យហើយប្រាប់សិស្សថា "**នេះគឺជាលេខ ១** " ។ ចូរធ្វើសកម្មភាពដូចគ្នាចំពោះប័ណ្ណដែលនៅសល់ ។

១៤. រំលឹកការអានពាក្យថ្មីជាភាសាខ្មែរ។ នៅពេលនេះចូរគ្រូបលេខនៅលើប័ណ្ណ។ លើកប័ណ្ណនីមួយៗឡើងហើយចង្អុលតែពាក្យបានហើយ បន្ទាប់មកសួរសិស្សថា ” **តើនេះជាលេខប៉ុន្មាន ?** ” សិស្សអានពាក្យថា ”**១**”។ ចូរធ្វើលេខដែលនៅសល់ពីលេខ ២-១០។

១៥. ចូរដាក់ប័ណ្ណលេខពី១-១០នៅលើក្ដារខៀនកុំឱ្យត្រូវតាមលំដាប់លំដោយ។ គ្របលេខហើយឱ្យសិស្សតំរៀបប័ណ្ណឱ្យត្រូវទៅតាមលំដាប់លំដោយឡើងវិញពី១-១០។ សិស្សត្រូវអានពាក្យ និងតំរៀបប័ណ្ណទៅតាមលំដាប់លំដោយ។

១៦. ចូរណែនាំរូបភាព និងប័ណ្ណរួមគ្នាតែម្ដងដោយលើករូបភាព និងប័ណ្ណតាមគូដែលត្រឹមត្រូវពី១-១០ (ឧទាហរណ៍ៈ រូបភាពសាលារៀនត្រូវនឹងលេខ ១ ) ហើយសួរសិស្សថា ” **តើនេះជាអ្វី?** ”(សាលារៀន)។ ”**តើមានសាលារៀនប៉ុន្មាន?**” (១)។

១៧. ចូរដាក់រូបភាព និងលេខនៅលើក្ដារខៀន ហើយឱ្យសិស្សភ្ជាប់រូបភាព និងប័ណ្ណលេខឱ្យត្រូវគ្នា។

១៨. ចែកសិស្សនៅក្នុងថ្នាក់ជា២០ក្រុម។ ឱ្យប័ណ្ណ១ទៅក្រុមនីមួយៗហើយប្រាប់ថា ” **ប័ណ្ណរបស់អ្នកត្រូវការស្វែងរកគូត្រឹមត្រូវរបស់វា**។ ចូរស្វែងរកក្រុមដែលមានគូត្រូវគ្នា ។ សិស្សត្រូវដើរជុំវិញថ្នាក់រៀនដើម្បីស្វែងរករូបភាពឬប័ណ្ណលេខដែលត្រូវគ្នានិងរបស់ដែលខ្លួនមាន។

## II. ការផ្ដែកពីរូបភាពនិងរឿងនិទាន ”មិត្តសំលាញ់សត្វរបស់ខ្ញុំ”

    

១. កាសម្ដែងតួ- ការសន្ទនា

ចូរអានការសន្ទនាឱ្យសិស្សស្ដាប់។ ការសន្ទនានេះបានធ្វើឡើងរវាងសត្វចំនួនបី ៈមាន់, ជ្រូក និង គោ។

  

មាន់ : អរុណសួស្ដីអ្នកស្រីជ្រូក និងអ្នកស្រីគោ។ តើអ្នកសុខសប្បាយឬទេថ្ងៃនេះ?

ជ្រូក និងគោៈ អរុណសួស្ដីអ្នកស្រីមាន់។ ពួកយើងសុខសប្បាយទេ សូមអរគុណ។

មាន់ : តើអ្នកស្រីទាំងពីរនាំគ្នាទៅណាដែរ?

គោ : អ្នកស្រីជ្រូក និងខ្ញុំនាំគ្នាទៅផ្សារ។

មាន់ : តើខ្ញុំអាចទៅជាមួយអ្នកស្រីទាំងពីរនាក់ផងបានឬទេ?

គោ និងជ្រូកៈ ចាស៎ បាន។

ចូរប្រាប់សិស្សថាលោកគ្រូ/អ្នកគ្រូនឹងអានការសន្ទនារវាងសត្វចំនួនបី បន្ទាប់មកធ្វើសម្លេងសត្វនីមួយៗ។ ហើយសួរសិស្សថា " **តើខ្ញុំជាសត្វអ្វី? ជាសត្វគោ/ជ្រូក/មាន់?**"។ ឥឡូវនេះចូរសួរសិស្ស " **តើសត្វគោ/ជ្រូក/មាន់ធ្វើសម្លេងដូចម្តេច?**" (សិស្សឆ្លើយ) ។ ចូរអានការសន្ទនាឱ្យសិស្សស្តាប់។ ចូរសម្តែងតួអំពីសត្វ ចំនួនបី។ សិស្សគ្រាន់តែមើល និងស្តាប់ប៉ុណ្ណោះ។

៣. ចូរអានការសន្ទនា (សកម្មភាពទី១) ម្តងទៀត។ ចូរឱ្យសិស្សសម្តែងតួសត្វនៅពេលដែលលោកគ្រូ /អ្នកគ្រូអានការសន្ទនា។ អានការសន្ទនាម្តងទៀត។ នៅលើកនេះ ចូរឈប់ដោយអន្លើ និងឱ្យសិស្សផ្តល់ពាក្យបន្ទាប់ ។

៤. ចូរអានការសន្ទនាម្តងទៀត។ នៅលើកនេះ ចូរបែងចែកថ្នាក់ជាពីរ។ ពាក់កណ្តាលជាអ្នកស្រីមាន់ ហើយពាក់កណ្តាលទៀតជាអ្នកស្រីគោ។ លោកគ្រូ/អ្នកគ្រូគឺជាអ្នកស្រីជ្រូក។ ជួយសិស្សឱ្យចាំជួរបន្ទាត់សន្ទនាពួកគេ ។ ចូរអានការសន្ទនាម្តងទៀត។ នៅលើកនេះ ចូរឱ្យសិស្សនិយាយផ្នែករបស់ពួកគេដោយមិនចាំបាច់ ជួយឡើយ ។

៥. ចូរធ្វើមុខសត្វ (<u>សម្ភារ</u> កន្ត្រៃ, ប៊ិចពណ៌, ខ្មៅដៃពណ៌, ស្លឹកចេក, ស្កុត, ស្បែក) ។

ចូរបែងចែកសិស្សជាបីក្រុម។ ក្រុមនីមួយៗតំណាងឱ្យសត្វមួយនៅក្នុងការសន្ទនា (មាន់/ជ្រូក/គោ)។ ចូរសួរក្រុមនីមួយៗ " **តើប្អូនជាសត្វអ្វី? តើប្អូនធ្វើសម្លេងដូចម្តេច?**" (ក្រុមនីមួយៗឆ្លើយទៅតាមនោះ)

ថ្ងៃនេះក្រុមសត្វនីមួយៗនឹងធ្វើការទាំងអស់គ្នាដើម្បីធ្វើមុខសត្វមួយសម្រាប់ក្រុមរៀងៗខ្លួន។ ចូរបង្ហាញសិស្សអំពីឧទាហរណ៍ដែលលោកគ្រូ/អ្នកគ្រូបានធ្វើរួចហើយ។ ចូរចែកស្លឹកចេកដល់ក្រុមនីមួយៗដើម្បីប្រើធ្វើជា មុខសត្វ។ បន្ទាប់មកសិស្សអាចបិទវត្ថុផ្សេងៗនៅលើស្លឹកនោះដើម្បីធ្វើមុខសត្វពួកគេ។

ចូរដាក់រូបភាពនៅលើក្តារខៀន ដូចនេះក្រុមនីមួយៗអាចមើលឃើញសត្វពួកគេ។

នៅពេលដែលក្រុមទាំងបីបានធ្វើចប់ ប្រាប់ពួកគេឱ្យបង្ហាញមុខនោះដល់សិស្សក្នុងថ្នាក់។ ចូរសួរក្រុមទាំង ឡាយ " **តើប្អូនជាសត្វអ្វី? តើប្អូនធ្វើសម្លេងដូចម្តេច?**"។

៦. សម្តែងតួការសន្ទនា (សកម្មភាពទី១) ម្តងទៀត។ ចូរឱ្យសិស្សម្នាក់ពីក្រុមសត្វនីមួយៗពាក់មុខពួកគេ។ មុខនោះត្រូវតែជាមុខមាន់, គោ និងជ្រូក។ ឥឡូវនេះ ចូរឱ្យសិស្សទាំងបីនាក់សម្តែងតួធ្វើការសន្ទនារួមគ្នា។ ជួយពួកគេនៅពេលដែលចាំបាច់។

ហៅសិស្សបីនាក់ទៀតឱ្យពាក់មុខ និងសម្តែងតួសន្ទនា។

# មេរៀនទី ៥

## តើនរណាស្លៀកខោជើងខ្លីនៅថ្ងៃនេះ?



**- ការនិយាយអំពីសំលៀកបំពាក់**

### គោលបំណងនៃមេរៀន

សិស្សនៅថ្នាក់ទី ១ នឹងរៀនៈ

- ចំរៀង/កំណាព្យ/មេសូត្រជាភាសាខ្មែរ
- បទបញ្ជារបស់ថ្នាក់រៀន
- ភាសានៃការស្វាគមន៍ និងការណែនាំគ្នា
- លេខពី ១-១០
- ដើម្បីចូលរួមជជែកអំពីរូបភាពសំលៀកបំពាក់ និង សំលៀកបំពាក់ដែលមនុស្សកំពុងតែពាក់

### ធនធានសម្ភារសម្រាប់បង្រៀន

សម្ភារមានដូចជាៈ

- ប័ណ្ណរូបភាពសម្រាប់រៀនលេខ និង ឈ្មោះចំនួន
- រូបភាព "គ្រូ និង សិស្ស"
- រូបភាព "សំលៀកបំពាក់របស់ខ្ញុំ"

ចូរបែងចែងពេលវេលារបស់លោកគ្រូ/អ្នកគ្រូដើម្បីធ្វើសកម្មភាពខ្លីៗពីឈុតសកម្មភាពទាំង៥ខាងក្រោម ។ ចូរព្យាយាមធ្វើសកម្មភាពពី៤ទៅ៥ ខុសៗគ្នានៅក្នុងមេរៀនរយៈពេលមួយម៉ោង របស់លោកគ្រូ/អ្នកគ្រូ ។

## ឈុតសកម្មភាពទី១ ចំរៀង តារាងរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ជំហ្វូង)**

I. **ចំរៀង " សត្វសារិកាកែវ "**

### សារិកាកែវពត់ប្រាណ

| | | |
|---|---|---|
| សារិកាកែវអើយ | ស៊ីអីកងកង | សិស្សត្រសងនាំគ្នាពត់ប្រាណ |
| | អើយកែវៗអើយ (២ដង) ។ | |
| យើងខំលើកដៃ | លើកជើងឱ្យបាន | ខំពត់ទាំងប្រាណទើបសុខភាពល្អ |
| | អើយកែវៗអើយ (២ដង) ។ | |

១. ចូរប្រាប់សិស្សថា លោកគ្រូ/អ្នកគ្រូនឹងច្រៀងចំរៀងខ្មែរមួយបទអំពីបក្សីមួយហៅថា "**សត្វសេក**" ឱ្យពួកគេស្តាប់ ។ ចូរបកប្រែពាក្យនេះជាភាសាកំណើតរបស់សិស្ស ដើម្បីជួយសិស្សឱ្យងាយយល់ ។ ចូរសួរ "**តើប្អូនៗស្គាល់បក្សីនេះឬទេ?**" "**តើប្អូនៗអាចរកវាឃើញនៅក្នុងភូមិឬទេ?**" ។ ចូរប្រាប់សិស្សថា សត្វសេកគឺជាបក្សីឆ្លាតណាស់ ។ វាពូកែធ្វើត្រាប់ តាមអ្វីដែលមនុស្សយើងធ្វើ ។

ចូរឈរខាងមុខថ្នាក់ ។ ច្រៀងចំរៀងទៅកាន់សិស្សដោយធ្វើកាយវិការ ។ ត្រូវប្រាកដថាសិស្សអាចមើលឃើញកាយវិការរបស់លោកគ្រូ/អ្នក គ្រូច្បាស់ ។ សិស្សគ្រាន់តែមើល និងស្តាប់តែប៉ុណ្ណោះ ។

២. ចូរឈរ និង ច្រៀងចំរៀងទៅកាន់សិស្សដោយធ្វើកាយវិការ ។ សិស្សមើល និងស្តាប់ ។ ចូរហៅសិស្សឱ្យក្រោកឈរ " **តើសត្វសេកធ្វើកាយវិការយ៉ាងដូចម្តេច?**" (សិស្សបង្ហាញកាយវិការនោះដល់លោកគ្រូ/អ្នកគ្រូ) ។ ចូរចែកក្រដាស និង ខ្មៅដៃពណ៌ដល់សិស្ស ។ ចូរឱ្យពួកគេគូររូបសត្វសេក ។ ចូរដាក់រូបគំនូរទាំងនេះនៅលើក្តារខៀន ។

៣. ចូច្រៀងចំរៀងដោយធ្វើកាយវិការ ។ ឥឡូវនេះ ចូរនិយាយបន្ទាត់នីមួយៗនៅក្នុងបទចំរៀងយឺតៗ ។ សិស្សស្តាប់ និង និយាយ***តាមក្រោយ***លោកគ្រូ/អ្នកគ្រូ ។ ចូរនិយាយបន្ទាត់នីមួយៗនៅក្នុងបទចំរៀងម្តងទៀត ។ សិស្សស្តាប់ និង និយាយវា***ជាមួយ***លោកគ្រូ/អ្នកគ្រូ ។

៤. ចូរធ្វើការបំពេញល្បះដោយផ្ទាល់មាត់ ។ ចូរច្រៀងចំរៀងម្តងទៀត ។ ចូរច្រៀងបន្ទាត់នីមួយៗ ប៉ុន្តែយូរៗម្តងត្រូវរំលង ពាក្យខ្លះ ។ ចូរឱ្យសិស្សព្យាយាមបំពេញពាក្យដែលបាត់ ***(ដោយផ្ទាល់មាត់តែប៉ុណ្ណោះ)*** ។

៥. ចូរច្រៀងចំរៀងជាមួយសិស្ស ។ ចូរបែងចែកថ្នាក់ពាក់កណ្តាល ។ សិស្សមួយក្រុមច្រៀងចំរៀងនៅបន្ទាត់ទីមួយ ។ ក្រុម មួយទៀតច្រៀងចំរៀងនៅបន្ទាត់បន្ទាប់ ។ ចូរជួយសិស្សនៅពេលចាំបាច់ ។

៦. ចូរច្រៀងចំរៀងជាមួយសិស្ស ។ ត្រូវធ្វើកាយវិការនៅក្នុងពេលដំណាលគ្នានឹងការច្រៀង ។ ឥឡូវនេះ ចូរចាប់ផ្តើមច្រៀងម្តងទៀតដោយចាប់ផ្តើមពីដំបូង ។ ចូរច្រៀងបន្ទាត់ទីមួយដោយធ្វើកាយវិការ ។ សិស្សគួរតែចម្លងកាយវិការរបស់លោកគ្រូ/អ្នកគ្រូ ។ ចូរច្រៀងបន្ទាត់ទីពីរដោយធ្វើកាយវិការ និងធ្វើដូចនេះរហូតដល់លោកគ្រូ/អ្នកគ្រូបញ្ចប់ចំរៀង ។

៧. ចូរច្រៀងចំរៀងម្តងទៀត ។ ចូរប្រាប់ឱ្យសិស្សធ្វើតែកាយវិការប៉ុណ្ណោះ នៅពេលដែលលោកគ្រូ/អ្នកគ្រូកំពុងច្រៀង ។ ត្រូវពិនិត្យថា សិស្សចេះធ្វើកាយវិការទាំងអស់គ្នា ។

៨. ចូរបែងចែកសិស្សជាគូៗ ។ ច្រៀងចំរៀងទៅកាន់សិស្ស និងនៅពេលដែលលោកគ្រូ/អ្នកគ្រូច្រៀង សិស្សមួយគូៗគួរតែ ធ្វើកាយវិការរួមគ្នា ។ ចូរច្រៀងចំរៀងម្តងទៀត ។ ចូរឱ្យសិស្សព្យាយាមច្រៀងចំរៀង និងធ្វើកាយវិការនៅក្នុងពេល ដំណាលគ្នា ។

៩. ចូរឱ្យថ្នាក់ទាំងមូលក្រោកឈរ និងច្រៀងចំរៀងជាមួយលោកគ្រូ/អ្នកគ្រូ ដោយមានធ្វើកាយវិការ ។

## II. តារាងរូបភាព និងរឿងនិទាន "សំលៀកបំពាក់របស់ខ្ញុំ"

| **ពាក្យគន្លឹះ** | | **ពាក្យរំលឹកឡើងវិញ** | | |
|---|---|---|---|---|
| អាវ | សារ៉ុង | ពណ៌ក្រហម | ពណ៌លឿង | វែង |
| ខោជើងខ្លី | ខោជើងវែង | ពណ៌ខ្មៅ | ពណ៌ផ្កាឈូក | ខ្លី |
| សំពត់ | អាវយឺត | ពណ៌ស | ពណ៌បៃតង | ធំ |
| ស្បែកជើង | | ពណ៌ខៀវ | | តូច |

១. ចូរប្រាប់សិស្សថាពួកគេនឹងនិយាយអំពីសំលៀកបំពាក់ដែលធ្លាប់ស្គាល់ ។ ដោយប្រើភាសាកំណើតរបស់កុមារ ចូរពណ៌នាប្រាប់ សិស្សក្នុងថ្នាក់នូវសំលៀកបំពាក់ដែលសិស្សខ្លះកំពុងតែស្លៀកពាក់នៅថ្ងៃនេះ ឧទាហរណ៍: នៅថ្ងៃនេះ សូរឿនស្លៀក ខោជើងខ្លី, ម៉ារីស្លៀកសំពត់, សុពេជ្រពាក់អាវយឺត និង ។ល។

ចូរសួរសិស្ស "តើនរណាស្លៀក/ពាក់ (**ខោជើងខ្លី**) នៅថ្ងៃនេះ? (សូរឿន? សុពេជ្រ?)

(**សារ៉ុង**) (ម៉ារី? ល័ក្ខ?)

(**អាវយឺត**) (ម៉ារី? សុពេជ្រ?)

ចូរចែកក្រដាសខ្លះ និង ខ្មៅដៃពណ៌ដល់សិស្ស និងឱ្យពួកគេគូររូបភាពសមាជិកម្នាក់នៅក្នុងថ្នាក់ ។ ចូរដាក់រូបភាពទាំង អស់នៅលើក្តារខៀន ។ ថ្នាក់ទាំងមូលត្រូវទស្សន៍ទាយឈ្មោះសិស្សថ្នាក់ទី ១ នៅក្នុងរូបភាពនីមួយៗ ។

២. ចូរដាក់ផ្ទាំងក្រដាសធំមួយ ។ គូរកូឡោនបី ។ នៅលើកូឡោនទី១ ចូរគូររូបសំលៀកបំពាក់មួយ ឧទាហរណ៍: **ខោជើងខ្លី** ។ ចូរសួរ "**តើនេះហៅថាអ្វី?**" (ខោជើងខ្លី) ។ នៅលើកូឡោនទីពីរ ចូរសរសេរឈ្មោះ "**ខោជើងខ្លី**"

ជាភាសាកំណើតរបស់សិស្ស ។

ចូរបន្តធ្វើសកម្មភាពនេះចំពោះសំលៀកបំពាក់ទាំងអស់ដែលមាននៅក្នុងបញ្ជីពាក្យគន្លឹះ ។ ចូរនិយាយ ពាក្យទាំងនេះ **ទៅកាន់** សិស្ស ។ ចូរនិយាយពាក្យទាំងនេះ**ជាមួយ**សិស្ស ។

៣. ចូរធ្វើសកម្មភាពដូចគ្នានឹងចំណុចទី (១) ។ នៅលើកនេះ ចូរប្រើភាសាខ្មែរដើម្បីពណ៌នាពីសំលៀកបំពាក់ដែលសិស្សថ្នាក់ទី១ ស្លៀកពាក់ ។ ចូរសួរសិស្សក្នុងថ្នាក់ជាភាសាខ្មែរ " **តើនរណាស្លៀក/ពាក់ ខោជើងខ្លី/សារ៉ុង/អាវយឺត"** និង ។ ល ។ ចូរពន្យល់ជាភាសាកំណើតរបស់សិស្សនៅពេលចាំបាច់ ។ ឥឡូវ ចូរចង្អុលសំលៀកបំពាក់ដែលសិស្សម្នាក់កំពុងស្លៀកពាក់ និងសួរជាភាសាខ្មែរ " **តើនេះជាអ្វី?**" (ខោជើងខ្លី/សារ៉ុង/អាវយឺត) ។ ដោយឱ្យសិស្សប្រើក្តារឆ្នួនពួកគេ ចូរប្រាប់ពួកគេជាភាសាខ្មែរ ឱ្យគូរមនុស្ស ម្នាក់ដែលកំពុងតែស្លៀក **<u>ខោជើងខ្លី</u>** និងពាក់ **<u>អាវយឺត</u>** ។ ចូរដើរជុំវិញដើម្បីពិនិត្យមើល តើសិស្សយល់នូវការណែនាំ បានត្រឹមត្រូវឬទេ ។

## ឈុតសកម្មភាពទី២ បទបញ្ជាក្នុងថ្នាក់រៀន តារាងរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. បទបញ្ជាក្នុងថ្នាក់រៀន

<u>សូមក្រោកឈរឡើង</u>



<u>សូមអង្គុយចុះ</u>



<u>សូមលើកដៃប្អូនៗឡើង</u>



<u>សូមឈប់ជជែកគ្នា</u>

<u>សូមស្តាប់</u>

<u>សូមយកក្តារឆ្នួន និងដីសប្អូនៗចេញមក</u>



<u>សូមឡើងក្តារខៀន</u>

<u>សូមថាតាមលោកគ្រូ/អ្នកគ្រូ</u>

១. ចូរណែនាំអំពីបទបញ្ជាក្នុងថ្នាក់រៀនថ្មីពីរជាភាសាកំណើតរបស់កុមារ "**សូមឡើងក្តារខៀន**" និង "**សូមថាតាមលោកគ្រូ/អ្នកគ្រូ**" ។ ចូរធ្វើបង្ហាញសិស្ស ។ សិស្សត្រូវមើលនិងស្តាប់ ។ សិស្សត្រូវធ្វើតាមគំរូរបស់លោកគ្រូ/អ្នកគ្រូ ។

២. ចូរណែនាំអំពីបទបញ្ជាដូចគ្នានេះជាភាសាខ្មែរ នៅលើកនេះ ។ ចូរធ្វើគំរូឱ្យសិស្សមើល ។ ចូរសួរសិស្ស "**តើយើងនិយាយ វាជាភាសាកំណើតរបស់ប្អូនយ៉ាងដូចម្ដេច?**" ។

៣. ចូររំលឹកឡើងវិញនូវរាល់បញ្ជាទាំងអស់ ។ ចូរហៅសិស្ស៤នាក់ឡើងមកខាងមុខថ្នាក់ ។ ចូរផ្ដល់បទបញ្ជាដល់ពួកគេ (ឧ: **សូមលើកដៃប្អូន១ឡើង**) ។ សិស្សត្រូវស្ដាប់ និងធ្វើអ្វីដែលលោកគ្រូ/អ្នកគ្រូឱ្យធ្វើ ។ ឥឡូវ ចូរផ្ដល់បទបញ្ជាពីរ (ឧ: **សូមលើកដៃប្អូន១ឡើង និង ឡើងក្ដារខៀន**) ។ សិស្សត្រូវស្ដាប់ និងធ្វើនូវអ្វីដែលលោកគ្រូ/អ្នកគ្រូឱ្យធ្វើ ។

៤. ចូរបែងចែកថ្នាក់រៀនទៅជាក្រុមដែលមានគ្នា ៤ ឬ៥ នាក់ ។ ចូរចាត់តាំងសិស្សម្នាក់ពីក្រុមនីមួយៗធ្វើជា "គ្រូ" ។ "គ្រូ" ម្នាក់ៗគួរតែផ្ដល់បទបញ្ជាផ្សេងៗគ្នាទៅកាន់ក្រុម ។ ក្រុមត្រូវស្ដាប់ និងធ្វើតាមអ្វីដែល"គ្រូ"ប្រាប់ឱ្យធ្វើ ។

៥. ចូរហាត់ធ្វើបទបញ្ជាថ្មីមួយជារៀងរាល់ថ្ងៃ ។ ជាដំបូងត្រូវណែនាំវាជាភាសាសិស្សសិន ។ ធ្វើគំរូឱ្យសិស្សមើល ។ ចូរណែនាំវាម្ដងទៀតជាភាសាខ្មែរ ។ ចូរធ្វើគំរូឱ្យសិស្សមើល ។

៦. ចូរសម្ដែងតួអំពីការផ្ដល់បទបញ្ជា ។ ឱ្យសិស្សនិយាយបទបញ្ជានោះជាសាភាខ្មែរ ។

៧. សិស្សជ្រើសរើសបទបញ្ជាមួយ និងផ្ដល់វាទៅសិស្សដែលនៅសល់ក្នុងថ្នាក់ ដោយប្រើភាសាខ្មែរ ។ សិស្សក្នុងថ្នាក់ត្រូវធ្វើ តាមឱ្យបានត្រឹមត្រូវ ។

៨. ចូរចែកថ្នាក់រៀនជាក្រុមតូចៗ ។ សិស្សម្នាក់ៗសម្ដែងតួផ្ដល់បទបញ្ជាដល់ក្រុម ។ សមាជិកក្រុមត្រូវទាយបទបញ្ជា និង និយាយតើវាជាអ្វី ។

៩. សិស្សគូររូបភាពឱ្យត្រូវគ្នានឹងបទបញ្ជានីមួយៗ ។ សិស្សបង្ហាញគំនូរពួកគេទៅកាន់ថ្នាក់ ។ ធ្វើការទស្សន៍ទាយបទបញ្ជា ដែលត្រូវគ្នានឹងរូបភាព ។

## II. តារាងរូបភាព និងរឿងនិទាន "សំលៀកបំពាក់របស់ខ្ញុំ"

១. ចូរបិទផ្ទាំងក្រដាសធំពីសកម្មភាពទី (២) **ចំនុចទី II តារាង និង រឿងនិទាននៃឈុតសកម្មភាពទី១**នៅលើក្ដារខៀន ។ គូសកូឡោនទីពីរដែលមានពាក្យជាភាសាកំណើតរបស់កុមារ ។ ចង្អុលរូបភាពនីមួយៗនៅក្នុងកូឡោនទីមួយ និងសួរថា "**តើនេះគេហៅថាអ្វីជាភាសាកំណើតរបស់សិស្ស?**" (សិស្សឆ្លើយ) ។ "**ចុះជាភាសាខ្មែរវិញ?**" (សិស្សឆ្លើយ) ។ ចូរសរសេរពាក្យខ្មែរនៅជាប់នឹងពាក្យបកប្រែជាភាសាកំណើតរបស់កុមារ ។

២. ចូរលេងល្បែងជាមួយសិស្សជាភាសាខ្មែរ ។ ចូរប្រាប់សិស្សឱ្យក្រោកឈរ និងស្ដាប់បញ្ជារបស់លោកគ្រូ/អ្នកគ្រូ ។ "**សូមអង្គុយចុះប្រសិនបើប្អូនស្លៀក/ពាក់ .... (ខោជើងខ្លី), (សារ៉ុង), (អាវយឺត)**" ។ បន្តផ្ដល់បទបញ្ជារហូតដល់សិស្សទាំងអស់ក្នុងថ្នាក់អង្គុយចុះគ្រប់គ្នា ។ ចូរហៅសិស្សខុសៗគ្នាឱ្យសាកល្បងផ្ដល់បទបញ្ជាពួកគេផ្ទាល់ ដោយប្រើភាសាខ្មែរ ។ ចូរជួយពួកគេនៅពេលចាំបាច់ ។

៣. ចូរលេងល្បែងដូចគ្នាពីសកម្មភាពទី (២) ដោយនិយាយជាភាសាខ្មែរ ។ នៅលើកនេះ ចូររំលឹកឡើងវិញនូវវាក្យស័ព្ទអំពីពណ៌ផងដែរ ។ " **សូមអង្គុយចុះប្រសិនបើប្អូនស្លៀក/ពាក់ ....** (**អាវយឺតក្រហម**)

(**សារ៉ុងបៃតង**)

(**ខោជើងខ្លីពណ៌ខៀវ**) និង ។ល ។

## ឈុតសកម្មភាពទី៣ ការស្វាគមន៍គ្នា តារាងរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការស្វាគមន៍គ្នា

ឧទាហរណ៍: អរុណសួស្តី ។ តើសុំឡាញ់សុខសប្បាយឬទេ ថ្ងៃនេះ? (ខ្ញុំសុខសប្បាយជាទេ សូមអរគុណ)

សាយ័ណ្ហសួស្តី ។





១. ចូរណែនាំឱ្យស្គាល់អំពីការស្វាគមន៍គ្នាជាភាសាខ្មែរ ។ សិស្សត្រូវនិយាយវាតាមពីក្រោយលោកគ្រូ/អ្នកគ្រូ ។

២. ចូរនិយាយពាក្យស្វាគមន៍ ។ សិស្សត្រូវឆ្លើយតបឱ្យបានសមរម្យ ។

៣. សិស្សសម្តែងតួជាគូ ធ្វើជាគ្រូ និង សិស្ស/សិស្ស និង សិស្ស ។



៤. ប្រើរូបភាព ។ ចូរសួរសិស្សនូវសំណួរអំពីរូបភាពជាភាសាកំណើតរបស់កុមារ ។ "**តើមនុស្សទាំងនេះជានរណា?**" "**តើពួកគេនៅ ឯណា?**" "**តើស្ត្រីម្នាក់ នោះកំពុងនិយាយអ្វីខ្លះទៅកាន់សិស្ស?**" និង ។ល។

៥. ប្រើរូបភាព ។ ចូរធ្វើសកម្មភាពដូចគ្នានឹងលើកមុន ប៉ុន្តែត្រូវប្រើភាសាខ្មែរតែប៉ុណ្ណោះ ។

៦. ចូរប្រើភាសាកំណើតរបស់កុមារ ។ ចូរប្រាប់សិស្សអំពីវត្ថុផ្សេងៗនៅក្នុងរូបភាព ។ "**នេះគឺជាក្តារខៀន/ទូ/គ្រូបង្រៀន**" និង ។ល។ ចូរសួរសិស្ស "**តើនេះជាអ្វី?**" (វាគឺជាក្តារខៀន) និង ។ល។

៧. ចូរធ្វើសកម្មភាពដូចលើកមុន ។ នៅលើកនេះត្រូវប្រើតែភាសាខ្មែរប៉ុណ្ណោះ ។

៨. ចូរប្រើរូបភាព ។ ចូរអានការសន្ទនាឱ្យសិស្សស្តាប់ ២ ឬ ៣ ដង ។ សិស្សស្តាប់តាម ។

<u>គ្រូ</u> អរុណសួស្តីមីរ៉ា ។ តើប្អូនសុខសប្បាយឬទេ ថ្ងៃនេះ?

<u>សិស្ស</u> សុខសប្បាយណាស់ សូមអរគុណអ្នកគ្រូ ។ តើអ្នកគ្រូសុខសប្បាយឬទេ ថ្ងៃនេះ?

<u>គ្រូ</u> សុខសប្បាយណាស់ សូមអរគុណប្អូន ។ តើអ្នកគ្រូអាចជួយកិច្ចការធ្វើនៅផ្ទះរបស់ប្អូនបានឬទេ?

<u>សិស្ស</u> ចាស់ អ្នកគ្រូ ។

៩. ចូរប្រើរូបភាព និង ការសន្ទនាម្តងទៀត ។ ចូរនិយាយការសន្ទនា ។ សិស្សនិយាយតាមក្រោយលោកគ្រូ/អ្នកគ្រូ ។

១០. សម្តែងតួធ្វើការសន្ទនាជាមួយសិស្សក្នុងថ្នាក់ ។ លោកគ្រូ/អ្នកគ្រូសម្តែងតួជាគ្រូ ។ សិស្សឆ្លើយតប ។

១១. ចូរបែងចែកថ្នាក់ជាពាក់កណ្តាល ។ សិស្សពាក់កណ្តាលសម្តែងតួធ្វើជាគ្រូ និងពាក់កណ្តាលទៀតសម្តែងតួធ្វើជាសិស្ស ។

## II. តារាងរូបភាព និងរឿងនិទាន "សំលៀកបំពាក់របស់ខ្ញុំ"



១. ចូរណែនាំឱ្យស្គាល់នូវរូបភាព "**សំលៀកបំពាក់របស់ខ្ញុំ**" ចូរប្រាប់សិស្សអំពីរូបភាព ជាភាសាកំណើតរបស់សិស្ស ។ **សំលៀកបំពាក់ទាំងនេះនៅលើស្នួល ។ គេបានបោកវា ហើយឥឡូវនេះកំពុងហាល ។ នេះគឺជាខោជើង វែង ។ វាវែង និងមានពណ៌ខ្មៅ ។ នេះគឺជាសារ៉ុង ។ វាមានពណ៌ក្រហម, ខៀវ និងលឿង** និង ។ល ។ ឥឡូវនេះ ចូរចង្អុលសំលៀកបំពាក់ផ្សេងៗនៅក្នុង រូបភាព, "**តើនេះគឺជាអ្វី?**" (សិស្សឆ្លើយជាភាសាកំណើតរបស់សិស្ស) ។

២. ចូរធ្វើសកម្មភាពទី (១) ឡើងវិញ ។ នៅលើកនេះ ចូរប្រាប់សិស្សអំពីរូបភាព ដោយនិយាយជាភាសាខ្មែរ ។ ចូរចង្អុល សំលៀកបំពាក់ផ្សេងៗគ្នា នៅក្នុងរូបភាព និងសួរ "**តើនេះជាអ្វី?**" (សិស្សឆ្លើយជាភាសាខ្មែរ) ។ ចូរពណ៌នាសំលៀក បំពាក់មួយ ពីក្នុងរូបភាពឱ្យសិស្សស្តាប់ ។ ឧ: **សំលៀកបំពាក់នេះមានពណ៌ខៀវ** ។ សិស្សគួរតែទាយនូវអ្វីដែល លោកគ្រូ/អ្នកគ្រូកំពុងពណ៌នា (**ខោជើងខ្លី?**) ។ **សំលៀកបំពាក់នេះវែង និងមានពណ៌ខ្មៅ** (**ខោជើងវែង?**) និង ។ល ។ ចូរហៅសិស្សខ្លះឱ្យពណ៌នាអំពីសំលៀកបំពាក់ ឱ្យលោកគ្រូ/អ្នកគ្រូស្តាប់ ប៉ុន្តែពួកគេមិនត្រូវនិយាយថាតើវាជាអ្វីឡើយ ។ លោកគ្រូ/អ្នកគ្រូត្រូវទាយសំលៀកបំពាក់ដែលសិស្សកំពុងពណ៌នា ។

៣. ចូរសួរសិស្សនូវសំណួរ ត្រូវ និង ខុស អំពីអ្វីៗដែលមាននៅក្នុងរូបភាព ។ ចូរប្រើភាសាខ្មែរ ប៉ុន្តែត្រូវជួយពួកគេជាភាសា កំណើតរបស់សិស្ស នៅពេលចាំបាច់ ។

**អាវយឺតមានពណ៌ស** (ត្រូវ ឬ ខុស?)

**សារ៉ុងមានពណ៌ស** (ត្រូវ ឬ ខុស?)

**ខោជើងវែងមានពណ៌លឿង** (ត្រូវ ឬ ខុស?)

**មានសំលៀកបំពាក់ប្រាំនៅលើស្នួល** (ត្រូវ ឬ ខុស?)

## ឈុតសកម្មភាពទី៤ ការរៀនលេខ ការប្រកបចំនួន តារាងរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

## I. ការរៀនលេខ និងការប្រកបចំនួន

១. ចូរបង្រៀនសិស្សនូវចំនួនពី ១ ដល់ ៥ ជាភាសាខ្មែរ ។ ចូរប្រើសម្ភារពិត ។ ចូរបង្ហាញខ្មៅដៃមួយដល់សិស្ស ។ ចូរប្រាប់សិស្សថា " **នេះគឺជាខ្មៅដៃមួយដើម**" ។ សួរសិស្ស " **តើមានខ្មៅដៃប៉ុន្មាន?**" (១) ។ ចូរលើកខ្មៅដៃពីរឡើង ។ "**ទាំងនេះជាខ្មៅដៃពីរដើម**" ។ " **តើមានខ្មៅដៃប៉ុន្មានដើម?**" (២) និង-ល-សម្រាប់ចំនួនទាំងអស់ពី ១ ដល់ ៥ ។

២. ចូរធ្វើសកម្មភាពដូចគ្នា ។ នៅលើកនេះ ត្រូវណែនាំបង្ហាញចំនួនពី ៦ ដល់ ១០ ។ ចូរប្រើសម្ភារពិត ។

៣. ដោយធ្វើកិច្ចការជាក្រុមចូររំលឹកចំនួនពី ១ ដល់ ១០ ដោយប្រើសម្ភារពិត (ឧ: **ខ្មៅដៃ ឬ បំពង់បឺត**) ។ ចូរបែងចែកថ្នាក់ទៅជាក្រុមតូចៗ ។ សិស្សម្នាក់ក្នុងក្រុមនីមួយៗត្រូវធ្វើជាអ្នកបង្ហាញខ្មៅដៃ ឬ បំពង់បឺតខ្លះដល់ក្រុម និងសួរ "**តើមានខ្មៅដៃ/បំពង់បឺតប៉ុន្មាន?**" ។ សិស្សនៅសល់ក្នុងក្រុមត្រូវឆ្លើយតប ។ សិស្សម្នាក់ៗនៅក្នុងក្រុមត្រូវប្តូរវេនគ្នា សួរ " **តើមាន ....... ប៉ុន្មាន?**" ។

៤. ត្រូវមានតារាងរូបភាពដែលនិយាយអំពីប័ណ្ណរូបភាពពី ១ ដល់ ១០ ជាភាសាកំណើតរបស់សិស្ស។ ចូរសួរសិស្សនូវសំណួរជាភាសាពួកគេអំពីរូបភាព ។ " **តើប្អូនៗអាចមើលឃើញអ្វីខ្លះ?**" "**តើប្អូនៗអាចមើលឃើញមនុស្សប៉ុន្មាននាក់?**" "**តើពួកគេជានរណា?**" (សិស្សឆ្លើយដោយប្រើភាសាពួកគេ) ។

៥. ចូរប្រើប័ណ្ណរូបភាពដូចគ្នាពី ១ ដល់ ១០ ។ នៅលើកនេះ ត្រូវនិយាយវាជាភាសាខ្មែរ ។ "**នេះគឺជាសាលារៀនមួយ**" ។ " **ចុះតើយើងនិយាយវាដូចម្តេចជាភាសាយើង?**" (សិស្សឆ្លើយជាភាសាពួកគេ) ។ "**ទាំងនេះគឺជាសិស្សាពីរនាក់**" **តើយើងនិយាយវាដូចម្តេចជាភាសាយើង?**" (សិស្សឆ្លើយជាភាសាពួកគេ) ។

៦. ចូររំលឹកប័ណ្ណឡើងវិញពី ១ ដល់ ១០ ដោយប្រើភាសាខ្មែរ ។ ចូរប្រាប់សិស្ស "**នេះគឺជាសាលារៀនមួយ**" ។ ចូរសួរសិស្ស "**តើនេះគឺជាអ្វី?**" (សាលារៀន) ។ "**ទាំងនេះជាសិស្សាពីរនាក់**" **តើមានសិស្សាប៉ុន្មាននាក់?**" (២) ។

៧. ចូរលើកប័ណ្ណរូបភាពខុសៗគ្នាឡើង ដោយដាក់តាមលំដាប់ ។ ចូរសួរសិស្ស " **តើមាន .........ប៉ុន្មានដែលប្អូនៗអាចមើល ឃើញ?**" ។ ចូរចែកថ្នាក់ជា ៥ក្រុម ។ ចូរចែកប័ណ្ណពាក្យពីរ ដល់ក្រុមនីមួយៗ ។ ចូរឱ្យក្រុមទាំងឡាយប្រាប់គ្នាទៅវិញ ទៅមកអំពីរូបភាពនៅលើប័ណ្ណ ។ ចូរប្តូរប័ណ្ណនៅតាមក្រុមទាំងឡាយ ។

៨. រំលឹកចំនួនពី ១ ដល់ ១០ ឡើងវិញម្តងទៀត ។ ចូរបិទប័ណ្ណរូបភាពនៅលើក្តារខៀនទៅតាមលំដាប់មិនត្រឹមត្រូវ ។ ចូរ ហៅសិស្សផ្សេងៗគ្នាឱ្យឡើងក្តារខៀន និងជួយដាក់ប័ណ្ណរូបភាពឱ្យត្រូវតាមលំដាប់ពី ១ ដល់ ១០ ។ ប័ណ្ណដំបូងគួរតែ ជារូប "**សាលារៀន**" ប័ណ្ណបន្ទាប់គឺជា "**សិស្សាពីរនាក់**" និង ។ល ។ សិស្សទាំងអស់អាចជួយបាន ។

៩. ចូរប្រើសម្ភារពិតដើម្បីរំលឹកចំនួន និងវាក្យស័ព្ទថ្មីៗ ឡើងវិញ ជាភាសាខ្មែរ។ ចូរសួរសិស្ស " **ចូរបង្ហាញអ្នកគ្រូនូវខ្មៅដៃ ៤ ដើម**" ។ សិស្សគួរតែលើកខ្មៅដៃ ៤ ដើម ឡើង ។ " **ចូរបង្ហាញអ្នកគ្រូនូវសំពាតសៀវភៅបី**" និង ។ល ។

១០. ណែនាំអំពីលេខខ្មែរឱ្យសិស្សស្គាល់ ។ ចូរគ្របអក្ខរាវិរុទ្ធរបស់លេខ សម្រាប់មេរៀននេះ ។ ចូរចង្អុលលេខនីមួយៗ និងប្រាប់ សិស្សថា " **នេះគឺជាលេខ ១**" ។ " **តើនេះជាអ្វី?** " (លេខ ១) ។ "**នេះគឺជាលេខ ២**" និង ។ល។

១១.**មើល គ្រប សរសេរ ផ្ទៀងផ្ទាត់** លេខពី ១ ដល់ ១០ ។ គ្របអក្ខរាវិរុទ្ធលេខ សម្រាប់មេរៀននេះ ។ ចូរលើកប័ណ្ណមួយ ឡើង និងសួរ "**តើនេះជាចំនួនប៉ុន្មាន?**" (ចំនួន ២) ។ ចូរគ្របប័ណ្ណនោះ ។ សិស្សសរសេរលេខនៅលើក្ដារឆ្នួនពួកគេ ។ ចូរប្រាប់សិស្ស " **ចូរលើកក្ដារឆ្នួនប្អូនៗឡើង**" ។ បើកប័ណ្ណនោះវិញ និងផ្ទៀងផ្ទាត់ ។

១២.ចូរចែកសិស្សក្នុងថ្នាក់ទៅជាក្រុមដែលមានគ្នា ១០ នាក់ ។ ចូរចែកប័ណ្ណមួយដល់ក្រុមនីមួយៗ ។ គ្របអក្ខរាវិរុទ្ធលេខ សម្រាប់មេរៀននេះ ។ ចូរហៅសិស្សម្នាក់ពីក្នុងក្រុមនីមួយៗឱ្យឡើងមកខាងមុខ ។ ចូរប្រាប់សិស្ស " **ចូរលើកប័ណ្ណរបស់ ប្អូនៗឡើងឱ្យត្រូវតាមលំដាប់ពី ១ ដល់ ១០**" ។ ថ្នាក់ទាំងមូលអាចជួយបាន ។

១៣. ចូរណែនាំសិស្សឱ្យស្គាល់ពីអក្ខរាវិរុទ្ធចំនួនពី ១ ដល់ ១០ ។ លើកប័ណ្ណពី ១ ដល់ ១០ ឡើង ។ ចូរចង្អុលលេខ " **តើនេះជាចំនួនអ្វី?**" (ចំនួន ១) ។ ចង្អុលទៅពាក្យ និងនិយាយប្រាប់សិស្ស "**នេះគឺជាចំនួន មួយ**" ។ ចូរធ្វើសកម្មភាព នេះដោយប្រើប័ណ្ណដែលនៅសល់ ។

១៤.រំលឹកការអានពាក្យថ្មីឡើងវិញ ជាភាសាខ្មែរ ។ នៅលើកនេះ ចូរគ្របលេខនៅលើប័ណ្ណ ។ លើកប័ណ្ណនីមួយៗឡើង និងចង្អុលពាក្យតែប៉ុណ្ណោះ ។ ចូរសួរសិស្ស "**តើនេះជាចំនួនប៉ុន្មាន?**" ។ សិស្សអានពាក្យសម្រាប់លេខ "១" ។ ចូរធ្វើ ដូចគ្នាចំពោះចំនួនពី ២ ដល់ ១០ ។

១៥.ចូរដាក់ប័ណ្ណទាំងអស់ពី ១ ដល់ ១០ នៅលើក្ដារខៀនទៅតាមលំដាប់មិនត្រឹមត្រូវ ។ ចូរគ្របលេខទាំងនោះ ។ ចូរឱ្យសិស្សរៀបប័ណ្ណឱ្យត្រូវតាមលំដាប់ពី ១ ដល់ ១០ ... ។ សិស្សគួរតែអានពាក្យ និងរៀបប័ណ្ណឱ្យត្រូវតាមលំដាប់ ។

១៦.ចូរណែនាំឱ្យសិស្សស្គាល់រូបភាព និងប័ណ្ណចំនួនដែលនៅជាមួយគ្នា ។ ចូរលើកគូរូបភាព និងចំនួន ពី ១ ដល់ ១០ ឡើង (ឧទាហរណ៍: ប័ណ្ណរូបភាព**សាលារៀន** និងប័ណ្ណចំនួន ១) ។ ចូរសួរសិស្ស "**តើនេះគឺជាអ្វី?**" (វាគឺជាសាលារៀន) ។ "**តើមានសាលារៀនប៉ុន្មាន?**" (១) ។

១៧.ចូរដាក់រូបភាព និងប័ណ្ណចំនួននៅលើក្ដារខៀន ។ ចូរឱ្យសិស្សផ្គូរផ្គងរូបភាព និងប័ណ្ណចំនួនឱ្យបានត្រឹមត្រូវ ។

១៨. ចូរចែកសិស្សក្នុងថ្នាក់ជា ២០ ក្រុម ។ ចូរចែកប័ណ្ណមួយដល់ក្រុមនីមួយៗ ។ ចូរប្រាប់ក្រុមនីមួយៗថា "**ប័ណ្ណរបស់ប្អូនៗត្រូវតែមានគូត្រូវគ្នា ។ ចូររកក្រុមដែលមានគូប័ណ្ណរបស់ប្អូនៗ**" ។ សិស្សត្រូវតែដើរជុំវិញថ្នាក់ដើម្បីរកក្រុមដែលមានរូបភាព ឬ ប័ណ្ណចំនួនដែលត្រូវគ្នាជាមួយប័ណ្ណពួកគេ ។

## II. តារាងរូបភាព និងរឿងនិទាន "សំលៀកបំពាក់របស់ខ្ញុំ"

១. ចូរធ្វើការពណ៌នាខ្លីៗជាភាសាខ្មែរ ឱ្យសិស្សស្ដាប់អំពីសំលៀកបំពាក់ដែលនរណាម្នាក់កំពុងស្លៀកពាក់ ។ សិស្សគួរតែគូររូបភាពអ្វីដែលពួកគេ ឮ លោកគ្រូ/អ្នកគ្រូពណ៌នា ។ ពួកគេនឹងត្រូវការក្រដាស និង ខ្មៅដៃពណ៌ ។ ចូរអានការពណ៌នាឱ្យសិស្សស្ដាប់ ៣ ឬ ៤ ដង ។

**សុពៅជ្រពាក់អាវយឺតពណ៌ក្រហម និងខៀវ ជាមួយនឹងខោជើងវែងពណ៌បៃតង ។**

ចូរឱ្យសិស្សបង្ហាញរូបភាពពួកគេទៅកាន់ដៃគូគេ ។ ចូរឱ្យសិស្សលើករូបភាពពួកគេឡើង ។ ចូរផ្ទៀងផ្ទាត់រូបភាពទៅនឹង ការពណ៌នារបស់លោកគ្រូ/អ្នកគ្រូ ។

២. ចូរប្រាប់សិស្សថា ពួកគេនឹងធ្វើខ្សែស្ទួលហាលសំលៀកបំពាក់មួយ នៅក្នុងមេរៀននេះ ។ ចូរបង្ហាញពួកគេនូវឧទាហរណ៍ ដែលលោកគ្រូ/អ្នកគ្រូបានធ្វើរួច ។

ចូរសួរសិស្ស " **តើយើងដាក់អ្វីនៅលើខ្សែស្ទួល?**" (សំលៀកបំពាក់) ។ "**ហេតុអ្វីក៏យើងដាក់វានៅទីនេះ?**" (ដើម្បីហាលសំងួតបន្ទាប់ពីយើងបោកវារួច) ។



ចូរចែកសិស្សជា ៥ ក្រុម ។ ចូរចែក **ក្រដាសពណ៌, ក្រដាសសធម្មតាមួយសន្លឹក, កន្ត្រៃ, ជ័រកាវ និង ខ្មៅដៃ** ដល់ក្រុមនីមួយៗ ។ ចូរឱ្យសិស្សគូររូបភាពខ្សែស្ទួលសំលៀកបំពាក់ នៅលើក្រដាសពណ៌ស ដោយប្រើប៊ិចហ្វឺត ។ បន្ទាប់ មក ត្រូវឱ្យសិស្សប្រើខ្មៅដៃគូរទ្រង់ទ្រាយសំលៀកបំពាក់ផ្សេងៗ ដោយប្រើក្រដាសពណ៌ ។ ពួកគេគួរតែបន្ទាប់មក កាត់ទ្រង់ទ្រាយទាំងនោះចេញ និងយកជ័រកាវបិទវាទៅលើខ្សែស្ទួលតាមក្រុម ។ ក្រុមនីមួយៗ គួរតែបង្ហាញខ្សែស្ទួល សំលៀកបំពាក់ឱ្យសិស្សក្នុងថ្នាក់មើល ។ ចូរសួរសំណួរអំពីកិច្ចការរបស់ក្រុមនីមួយៗ " **តើមានខោជើងវែង/ខោជើងខ្លី/ អាវយឺត ប៉ុន្មាននៅលើខ្សែស្ទួលសំលៀកបំពាក់របស់ប្អូនៗ?**" "**តើវាមានពណ៌អ្វីខ្លះ?**" ។

# មេរៀនទី៦

## មិត្តសំលាញ់របស់ខ្ញុំ





### គោលបំណងមេរៀន

សិស្សថ្នាក់ទី១ នឹងរៀនៈ

- ចំរៀង/ ពាក្យចុងចួន / មេសូត្រជាភាសាខ្មែរ
- បទបញ្ជារបស់ថ្នាក់រៀន
- ភាសានៃការស្វាគមន៍ និងការណែនាំគ្នា
- លេខពី ១-១០
- ចូលរួមជជែករូបភាពអំពីមិត្តសំលាញ់និងអ្វីដែលពួកគេធ្វើជាមួយគ្នា

### ធនធានសម្រាប់បង្រៀន

សម្ភារមានដូចជាៈ

- ប័ណ្ណរូបភាពសម្រាប់រៀនលេខ និង ឈ្មោះរបស់ លេខ
- រូបភាព "មិត្តសំលាញ់របស់ខ្ញុំ"

ចូរបែងចែងពេលវេលារបស់លោកគ្រូ/អ្នកគ្រូដើម្បីធ្វើសកម្មភាពខ្លី១ពីឈុតសកម្មភាពទាំង៥ខាងក្រោម ។ ចូរព្យាយាមធ្វើសកម្មភាពពី៤ទៅ៥ ខុស១គ្នានៅក្នុងមេរៀនរយៈពេលមួយម៉ោង របស់លោកគ្រូ/អ្នកគ្រូ ។

## ឈុតសកម្មភាពទី១ ចំរៀង ការផ្តែកអំពីរូបភាព និង រឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ចំរៀង " សារិកាកែវ "

សារិកាកែវពត់ប្រាណ

សារិកាកែវអើយ ស៊ីអីកងកង សិស្សត្រសងនាំគ្នាពត់ប្រាណ

អើយកែវៗអើយ (២ដង) ។

យើងខំលើកដៃ លើកជើងឱ្យបាន ខំពត់ទាំងប្រាណទើបសុខភាពល្អ

អើយកែវៗអើយ (២ដង) ។

១. ចូរប្រាប់សិស្សថាអ្នកនឹងច្រៀងចំរៀងខ្មែរមួយបទឱ្យពួកគេស្តាប់ ដែលចំរៀងនេះមានចំណងជើងថា "**សារិកា-កែវ**"។ ចូរបកប្រែពាក្យនេះជាភាសាកំណើតរបស់សិស្ស ដើម្បីជួយឱ្យពួកគេងាយយល់។ ចូរសួរសិស្សថា "**តើប្អូនៗស្គាល់សត្វនេះឬទេ?**" "**តើប្អូនៗអាចរកសត្វនេះឃើញនៅក្នុងភូមិឬទេ?**"។ ចូរប្រាប់សិស្សថាសត្វសារិកាកែវ គឺជាបក្សីវៃឆ្លាត។ ពួកបក្សីទាំងនេះចូលចិត្តធ្វើតាមសកម្មភាពរបស់មនុស្ស។

ចូរឈរនៅខាងមុខសិស្ស ហើយច្រៀងចំរៀងឱ្យសិស្សស្តាប់ដោយប្រើសកម្មភាព។ គ្រូបង្រៀនត្រូវប្រាកដក្នុងចិត្តថាសកម្មភាពរបស់ខ្លួនច្បាស់លាស់។ សិស្សអង្គុយស្តាប់ និងមើលតែសកម្មភាពរបស់គ្រូប៉ុណ្ណោះ។

២. ចូរក្រោកឈរហើយច្រៀងចំរៀងទៅកាន់សិស្សដោយប្រើសកម្មភាព។ សិស្សមើល និងស្តាប់គ្រូ។ ចូរហៅឱ្យសិស្សក្រោកឈរ ហើយសួរសិស្សថា "**តើសត្វសារិកាកែវធ្វើសកម្មភាពអ្វីខ្លះ?**" (សិស្សបង្ហាញសកម្មភាពដល់គ្រូបង្រៀន)។ ចូរផ្តល់ក្រដាស និងខ្មៅដៃពណ៌ឱ្យសិស្ស ហើយឱ្យពួកគេគូររូបសត្វសារិកាកែវនោះ។ បន្ទាប់មកយកគំនូរនេះ ដាក់បង្ហាញលើក្តារខៀន។

៣. ចូរច្រៀងចំរៀងដោយប្រើសកម្មភាព។ ឥឡូវនេះ ចូរអានចំរៀងតាមជួរបន្ទាត់នីមួយៗឱ្យបានយឺតៗ។ សិស្សស្តាប់និងថាតាមគ្រូ។ ចូរអានចំរៀងតាមជួរនីមួយៗម្តងទៀត។ សិស្សស្តាប់ និងនិយាយតាមគ្រូ។

៤. ការអនុវត្តបំពេញចន្លោះដោយផ្ទាល់មាត់។ ចូរច្រៀងចំរៀងម្តងទៀត។ បន្ទាប់មកអានជួរបន្ទាត់នីមួយៗ ប៉ុន្តែយូៗម្តង គ្រូត្រូវរំលងពាក្យខ្លះ ហើយឱ្យសិស្សព្យាយាមរកពាក្យដែលបាត់នោះមកបំពេញ (ដោយផ្ទាល់មាត់ប៉ុណ្ណោះ)។

៥. ចូរអានចំរៀងជាមួយសិស្ស បន្ទាប់មកចែកសិស្សក្នុងថ្នាក់ជាពីរក្រុម។ ក្រុមម្ខាងអានជួរបន្ទាត់ចំរៀងដំបូង និងក្រុមម្ខាងទៀតអានចំរៀងជួរបន្ទាប់។ ចូរជួយសិស្សបើសិនជាចាំបាច់។

៦. ចូរច្រៀងចំរៀងជាមួយសិស្ស ដោយធ្វើសកម្មភាពក្នុងពេលដំណាលគ្នា។ ឥឡូវនេះ ចូរចាប់ផ្តើមច្រៀងចំរៀងពីដើមដំបូងឡើងវិញ។ ចូរច្រៀងចំរៀងក្នុងជួរបន្ទាត់ដំបូងដោយប្រើសកម្មភាព ហើយឱ្យសិស្សធ្វើតាម។ ចូរច្រៀងចំរៀងជួរបន្ទាត់ទីពីរដោយធ្វើសកម្មភាព ហើយឱ្យសិស្សធ្វើតាម។ គ្រូអនុវត្តតាមវិធីនេះរហូត ចប់ចំរៀង។

៧. ចូរច្រៀងចំរៀងម្តងទៀត ហើយឱ្យសិស្សធ្វើតែសកម្មភាពក្នុងខណៈពេល ដែលអ្នកកំពុងច្រៀង។ ចូរត្រួតពិនិត្យថាតើពួកគេអាចធ្វើសកម្មភាពត្រឹមត្រូវឬទេ។

៨. ចូរបែងចែកសិស្សជាដៃគូ។ ចូរច្រៀងចំរៀងទៅកាន់សិស្ស ហើយក្នុងពេលដែលអ្នកកំពុងច្រៀង ដៃគូនីមួយៗគួរតែធ្វើសកម្មភាពរួមគ្នា។ ចូរច្រៀងចំរៀងម្តងទៀត។ ចូរប្រាប់ឱ្យសិស្សព្យាយាមច្រៀងនិងធ្វើសកម្មភាពក្នុងពេលដំណាលគ្នា។

៩. ចូរប្រាប់ឱ្យសិស្សទាំងអស់ក្រោកឈរ ហើយច្រៀងចំរៀងជាមួយអ្នក ដោយប្រើសកម្មភាព។

## II. ការជជែកអំពីរូបភាព និងរឿងនិទាន " មិត្តសំលាញ់របស់ខ្ញុំ "

**បញ្ជីពាក្យ**

| | |
|---|---|
| លេង | ចិត្តល្អ |
| ជជែកគ្នា | កំប្លែង |
| សើច | រាក់ទាក់ |
| បរិភោគ | អត់ធន់ |
| ចូលចិត្ត | សប្បាយ |
| ស្តាប់ | ឆ្លាត |
| ចេះ | |
| ដើរ | |
| រៀន | |

១. ចូរប្រាប់សិស្សថា នៅក្នុងមេរៀននេះពួកគេនឹងជជែកគ្នាអំពីមិត្តសំលាញ់។ ដោយប្រើប្រាស់ភាសាកំណើត ចូរឱ្យសិស្សគិតពីមិត្តសំលាញ់របស់ពួកគេ។ **"តើពួកគេឈ្មោះអ្វីខ្លះ?" "តើពួកគេជាមនុស្សបែបណា? ចិត្តល្អ? រាក់ទាក់? អត់ធន់?"** ។ ចូរស្តាប់គំនិតរបស់សិស្ស ហើយសរសេរគំនិតទាំងនោះនៅលើក្រដាសរ៉ាមធំជាភាសាកំណើតរបស់គេ ( ពាក្យគុណនាម) ដែលអាចប្រើសម្រាប់ពណ៌នាពីមិត្តសំលាញ់របស់ពួកគេ។

ចូរអានបញ្ជីពាក្យនេះជាមួយសិស្ស ។ ចូរអានគុណនាមទាំងនេះជាគំរូ បើសិនជាអ្នកចេះ ឧ. រីករាយ រាក់ទាក់ ចិត្តល្អ បន្ទាប់មកឱ្យសិស្សគូរគំនូរដែលពណ៌នាពីគុណនាមទាំងនេះ ឧ. គំនូរបង្ហាញពី "ការសប្បាយរីករាយ" ឬ "រាក់ទាក់" ។ ចូរបិទរូបគំនូរទាំងនេះនៅក្បែរគុណនាម ។ សូមរក្សាទុកបញ្ជីសម្រាប់ប្រើប្រាស់នៅក្នុងសកម្មភាពក្រោយ ។

២. ចូរប្រើប្រាស់ក្រដាសផ្ទាំងធំដែលបានពីសកម្មភាពទី១ ហើយចង្អុលទៅកាន់គំនូរនីមួយៗរួចសួរថា "**តើរូបគំនូរនេះពណ៌នាពីអ្វី?**" (រីករាយ រាក់ទាក់ ចិត្តល្អ ។ល។) ។ ចូរចង្អុលពាក្យនីមួយៗម្តងទៀត ហើយស្តាប់សិស្សអាន ។ នៅពេលនេះ ចូរប្រាប់សិស្សជាភាសាខ្មែរចំពោះគុណនាមទាំងនោះ ។ សូមកុំសរសេរពាក្យខ្មែរនៅលើក្រដាសផ្ទាំង គឺគ្រាន់តែធ្វើឱ្យសិស្សយល់តែប៉ុណ្ណោះ ។

ចូរចង្អុលទៅកាន់ពាក្យកំណើតរបស់សិស្ស ហើយសួរថា "តើភាសាខ្មែរគេថាដូចម្តេច?" ។ ចូរត្រួតពិនិត្យថាតើសិស្សចាំឬទេ ។ ចូរនិយាយពាក្យជាភាសាខ្មែរ ហើយឱ្យសិស្សប្រាប់ជាភាសាកំណើតរបស់ពួកគេ ។

៣. ចូរឱ្យសិស្សធ្វើការជាគូដើម្បីប្រាប់គ្នាទៅវិញទៅមកអំពីមិត្តសំលាញ់ ដោយប្រើភាសាកំណើតរបស់ពួកគេ ។ ចូរឱ្យក្រដាស និងខ្មៅដៃទៅសិស្សដើម្បីឱ្យពួកគេគូរគំនូរពីមិត្តសំលាញ់របស់ខ្លួន ។ គ្រូត្រូវជួយសរសេរឈ្មោះមិត្តសំលាញ់របស់សិស្សនៅខាងក្រោមគំនូរទាំងនោះ ។ បន្ទាប់មកសិស្សបង្ហាញគំនូរទៅកាន់សិស្សក្នុងថ្នាក់ ព្រមទាំងប្រាប់ព័ត៌មានមិត្តសំលាញ់របស់ខ្លួនផងដែរ ។ចូរសួរ "**តើមិត្តសំលាញ់របស់ប្អូនឈ្មោះអ្វី?**" "**តើប្អូនជួបមិត្តសំលាញ់របស់ប្អូននៅទីណា?**" "**តើមិត្តសំលាញ់របស់ប្អូនជាមនុស្សប្រភេទណា? សូមពណ៌នា**" ។ ចូររក្សាទុកគំនូរនេះសម្រាប់ប្រើនៅក្នុងសកម្មភាពក្រោយទៀត ។

## ឈុតសកម្មភាពទី២ បទបញ្ជាក្នុងថ្នាក់រៀន ការចែករំលែកអំពីរូបភាព និង រឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. បទបញ្ជាក្នុងថ្នាក់រៀន



សូមក្រោកឈរឡើង



សូមអង្គុយចុះ



សូមលើកដៃរបស់ប្អូន

សូមឈប់ជជែកគ្នា

សូមស្តាប់



សូមយកក្តារឆ្នួន និងដីសរបស់ប្អូនចេញមក

សូមឡើងក្តារខៀន

សូមថាតាមខ្ញុំ

១. ការណែនាំបង្ហាញបទបញ្ជាក្នុងថ្នាក់រៀនថ្មីពីរដោយប្រើប្រាស់ភាសាកំណើតរបស់សិស្ស **"សូមឡើងក្តារខៀន"** និង **"សូមថាតាមខ្ញុំ"** ។ ចូរធ្វើបង្ហាញបទបញ្ជាដល់សិស្ស ។ សិស្សមើលនិងស្តាប់ បន្ទាប់មកឱ្យអនុវត្តតាមគំរូរបស់ អ្នក ។

២. នៅពេលនេះចូរបង្ហាញបទបញ្ជាដោយប្រើភាសាខ្មែរម្តង ។ ចូរធ្វើជាគំរូ បន្ទាប់មកសួរសិស្សថា **"តើនៅក្នុងភាសារបស់ប្អូនគេនិយាយដូចម្តេច?"** ។

៣. ចូររំលឹកបទបញ្ជាទាំងអស់ឡើងវិញ ។ ហៅសិស្សប្អូនទាក់មកកាន់ខាងមុខថ្នាក់ ហើយផ្តល់បទបញ្ជាមួយ (ឧ: **សូមលើកដៃរបស់ប្អូនៗឡើង**) ។ សិស្សត្រូវស្តាប់ហើយធ្វើតាមអ្វីដែលអ្នកប្រាប់ ។ ឥឡូវនេះ ចូរផ្តល់បទបញ្ជាពីរ (ឧ: **សូមលើកដៃរបស់ប្អូនឡើងហើយដើរសំដៅទៅក្តារខៀន**) ។ សិស្សត្រូវស្តាប់ហើយធ្វើតាមអ្វីដែលអ្នកប្រាប់ ។

៤. ចូរបែងចែកសិស្សក្នុងថ្នាក់ជាបួន ឬ ប្រាំក្រុម ។ ចូរឱ្យសិស្សម្នាក់នៅក្នុងក្រុមនីមួយៗធ្វើជា "គ្រូ" ។ គ្រូនីមួយៗត្រូវផ្តល់បទបញ្ជាផ្សេងទៅកាន់ក្រុមរបស់ខ្លួន ។ ក្រុមនីមួយៗត្រូវស្តាប់ ហើយធ្វើតាមអ្វីដែលគ្រូរបស់ខ្លួនសួរ ។

៥. ចូរអនុវត្តបទបញ្ជាថ្មីមួយជារៀងរាល់ថ្ងៃ ។ ចូរណែនាំបង្ហាញដោយប្រើប្រាស់ភាសារបស់សិស្សជាដំបូងសិន ។ ចូរធ្វើជាគំរូ ។ ចូរណែនាំបង្ហាញម្តងទៀតជាភាសាខ្មែរ ។ ចូរធ្វើជាគំរូ ។

៦. ចូរសម្តែងតួប្រើប្រាស់បទបញ្ជាមួយ ដោយឱ្យសិស្សនិយាយបទបញ្ជានោះផ្ទាល់មាត់ជាភាសាខ្មែរ ។

៧. សិស្សជ្រើសរើសបទបញ្ជាមួយហើយផ្តល់ទៅឱ្យសិស្សផ្សេងៗទៀតនៅក្នុងថ្នាក់ដោយប្រើភាសាខ្មែរ ។ សិស្សទាំងឡាយឆ្លើយតបឱ្យបានសមស្រប ។

៨. ចូរបែងចែកសិស្សជាក្រុមតូចៗ ហើយឱ្យសិស្សម្នាក់នៅក្នុងក្រុមសម្តែងតួផ្តល់បទបញ្ជាទៅកាន់ក្រុមខ្លួន ។ សមាជិកក្រុមទស្សន៍ទាយបទបញ្ជានោះ ហើយប្រាប់ថាវាជាអ្វី ។

៩. ចូរឱ្យសិស្សគូររូបភាពឱ្យត្រូវនឹងបទបញ្ជានីមួយៗ បន្ទាប់មកបង្ហាញគំនូររបស់ពួកគេទៅសិស្សទាំងឡាយ ។ សិស្សទាំងឡាយត្រូវទស្សន៍ទាយបទបញ្ជានោះឱ្យត្រូវនឹងគំនូរ ។

## II. ការចែករំលែកអំពីរូបភាព និងរឿងនិទាន " មិត្តសំលាញ់របស់ខ្ញុំ "

១. ចូរលើកបង្ហាញគំនូរនៅក្នុង**សកម្មភាពទីបី ចំនុចទី II ឈុតសកម្មភាពទី១**ខាងលើ ។ ចូរចង្អុលទៅកាន់គំនូរនោះ និងសួរថា **"តើមិត្តម្នាក់នេះឈ្មោះ អ្វី?"** សិស្សគួរអានឈ្មោះដែលសរសេរនៅលើគំនូរនោះ ។ ចូរសួរ "តើនេះជាមិត្តរបស់នរណា?" (សិស្សដែលគូរ គំនូរនោះត្រូវឆ្លើយតប) ។ ចូរសួរសិស្សនេះអំពីមិត្តរបស់ពួកគេ ។ **"តើមនុស្សនេះមានរូបរាងដូចនរណាគេ?"** ។ សិស្សគួរព្យាយាមពណ៌នាជាភាសាខ្មែរ ដោយប្រើប្រាស់គុណនាមផ្សេងៗ ។ ចូរជួយពួកគេបើសិនជាចាំបាច់ ដោយ ប្រើប្រាស់ភាសាកំណើតរបស់សិស្ស ។

២. សិស្សលេងល្បែងស្ទង់មតិអំពីមិត្តរបស់ពួកគេក្នុងថ្នាក់ ។ សិស្សនីមួយៗត្រូវនិយាយទៅកាន់សិស្សពីរនាក់ផ្សេងទៀតនៅក្នុងថ្នាក់ និងស្វែងរកឈ្មោះមិត្តល្អម្នាក់នៅក្នុងចំណោមមិត្តទាំងនោះ ។ ពួកគេត្រូវព្យាយាមសរសេរឈ្មោះនោះផងដែរ ។ នៅលើក្រដាសផ្ទាំងធំ ចូរកត់ត្រាពត៌មានដែលសិស្សគិតឃើញ ។

| ឈ្មោះរបស់សិស្ស | ឈ្មោះរបស់មិត្ត |
|---|---|
| ភឿង | ណាង |
| វ៉ៃ | ប៊ុន |

ចូរនិយាយពត៌មាននេះទៅកាន់សិស្ស ។ ចូរសួរ ភឿង **"តើមិត្តល្អរបស់ប្អូនឈ្មោះអ្វី?"** (ណាង) **"តើហេតុអ្វីបានជាណាង ជាមិត្តល្អរបស់ប្អូន?"** (ដោយសារមិត្តរបស់ខ្ញុំ ចិត្តល្អ ព្យាយាម...) ។ ចូរសួរសិស្សផ្សេងទៀតនៅក្នុងថ្នាក់ឱ្យពណ៌នាពីមិត្តរបស់ពួកគេ ។ ចូរលើកទឹកចិត្តពួកគេឱ្យប្រើភាសាខ្មែរនៅក្នុងការពណ៌នា ។ ចូរប្រើផ្ទាំងក្រដាសផ្ទាំងធំនេះសម្រាប់សកម្មភាពលើកក្រោយ ។

## ឈុតសកម្មភាពទី៧ ការស្វាគមន៍គ្នា ការថ្លែងអំពីរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសពីមានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការស្វាគមន៍គ្នា

ឧទាហរណ៍: អរុណសួស្តី ។ តើសំឡាញ់សុខសប្បាយឬទេ ថ្ងៃនេះ? (ខ្ញុំសុខសប្បាយជាទេ សូមអរគុណ)
សាយ័ណ្ហសួស្តី ។

១. ចូរណែនាំការស្វាគមន៍គ្នាជាភាសាខ្មែរ ហើយឱ្យសិស្សថាតាមអ្នក ។

២. ចូរនិយាយពាក្យស្វាគមន៍គ្នា ។ សិស្សឆ្លើយតបឱ្យបានសមរម្យ ។

៣. សិស្សសម្តែងតួជាគូៗ ធ្វើជាគ្រូ និងសិស្ស/សិស្ស និងសិស្ស ។



៤. ចូរប្រើរូបភាព ហើយសួរសំណួរដោយប្រើភាសាកំណើតរបស់សិស្ស ។ **"តើមនុស្សទាំងនេះជានរណា"** **"តើពួកគេនៅឯណា"** **"តើស្ត្រីម្នាក់នោះកំពុងនិយាយអ្វីខ្លះទៅកាន់សិស្ស?"** ។ល ។

៥. ចូរប្រើរូបភាពហើយធ្វើសកម្មភាពដូចមុន ប៉ុន្តែប្រើតែភាសា ខ្មែរតែប៉ុណ្ណោះ ។

៦. ចូរប្រើភាសាកំណើតរបស់សិស្ស ដើម្បីប្រាប់ពីវត្ថុផ្សេងនៅក្នុងរូបភាព ។ "**នេះគឺជាក្តារខៀន/ទូ/គ្រូបង្រៀន**" ។ល ។ ចូរសួរសិស្ស "**តើនេះជាអ្វី?**" (ក្តារខៀន) ។ល ។

៧. ចូរធ្វើសកម្មភាពដូចលើកមុន ប៉ុន្តែលើកនេះត្រូវប្រើភាសាខ្មែរម្តង ។

៨. ចូរប្រើរូបភាព ហើយអានការសន្ទនាខាងក្រោមទៅកាន់សិស្សលេខពីរ ឬបីដង ។ សិស្សស្តាប់ ។

<u>គ្រូ</u> អរុណសួស្តីមីរ៉ា ។ តើប្អូនសុខសប្បាយឬទេ ថ្ងៃនេះ?

<u>សិស្ស</u> សុខសប្បាយណាស់ សូមអរគុណអ្នកគ្រូ ។ តើអ្នកគ្រូសុខសប្បាយឬទេ ថ្ងៃនេះ?

<u>គ្រូ</u> សុខសប្បាយណាស់ សូមអរគុណប្អូន ។ តើអ្នកគ្រូអាចជួយកិច្ចការធ្វើនៅផ្ទះរបស់ប្អូនបានឬទេ?

<u>សិស្ស</u> ចាស៎ អ្នកគ្រូ ។

៩. ចូរប្រើរូបភាព និងការសន្ទនាម្តងទៀត ។ ចូរនិយាយការសន្ទនា ហើយសិស្សថាតាមអ្នក ។

១០. ចូរសម្តែងការសន្ទនាជាមួយសិស្សក្នុងថ្នាក់ ។ អ្នកត្រូវសម្តែងតួធ្វើជាគ្រូ ហើយឱ្យសិស្សឆ្លើយតប ។

១១. ចូរបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ ក្រុមទីមួយសម្តែងតួជាគ្រូបង្រៀន និងក្រុមមួយទៀតសម្តែងតួជាសិស្ស ។

## II. ការចែករំលែកអំពីរូបភាព និងរឿងនិទាន " មិត្តសំលាញ់របស់ខ្ញុំ "

១. ចូរបិទក្រដាសវ៉ាមធំនៅក្នុងសកម្មភាពទីប្រាំខាងលើ នៅលើក្តារខៀន ។ ចូរគ្របកូឡោនទីពីរ ។ ចូរសួរថា "**តើមិត្តរបស់ ភឿងឈ្មោះអ្វី?**" ។ សិស្សគួរព្យាយាមចងចាំឈ្មោះមិត្តរួមថ្នាក់របស់ពួកគេ ។ ចូរហៅសិស្សឱ្យឡើងក្តារខៀន ដើម្បីសរសេរឈ្មោះ ។ បន្ទាប់មក បើកគ្របនៅក្នុងកូឡោនទីពីរ ដើម្បីត្រួតពិនិត្យ ថាតើការសរសេរនោះ ខុសឬត្រូវ ។ ចូរត្រួតពិនិត្យលើអក្ខរាវិរុទ្ធផងដែរ ។

២. ចូរបង្ហាញរូបភាពអំពី "**មិត្តសំលាញ់របស់ខ្ញុំ**"

ចូរប្រាប់សិស្សអំពីរូបភាពនោះដោយប្រើភាសាកំណើតរបស់សិស្ស ។ **សិស្សទាំងអស់នេះជាមិត្តសំលាញ់នឹងគ្នា** ។ **ពួកគេរស់នៅក្នុងភូមិជាមួយគ្នា** ។ **ពួកគេទៅសាលារៀនជាមួយគ្នា** ។ **ពួកគេចូលចិត្តធ្វើអ្វីជាច្រើនជាមួយគ្នា ឧ. រៀន លេង ជជែកគ្នា បរិភោគ** ។ ឥឡូវនេះ ចូរចង្អុលទៅកាន់ផ្នែកផ្សេងៗក្នុងរូបភាព "**តើនេះជាអ្វី?**" "**តើពួកគេនៅឯណា?**" "**តើពួកគេកំពុងធ្វើអ្វី?**" "**តើពួកគេកំពុងនិយាយអ្វីខ្លះទៅកាន់គ្នា?**" (សិស្សឆ្លើយដោយប្រើភាសាកំណើតរបស់ពួកគេ) ។

៣. ចូរអនុវត្តសកម្មភាពទី២ឡើងវិញ ។ នៅលើកនេះ ចូរប្រាប់សិស្សអំពីរូបភាពដោយប្រើភាសាខ្មែរ ។ ចូរចង្អុលទៅកាន់ផ្នែកផ្សេងៗនៃរូបភាព ហើយសួរថា "តើនេះជាអ្វី?" (សិស្សឆ្លើយជាភាសាខ្មែរ) ។ ចូរពណ៌នាអ្វីមួយនៅក្នុងរូបភាពទៅកាន់សិស្ស ឧ. **សិស្សទាំងអស់នេះចូលចិត្តលេងនៅក្នុងទីធ្លាសាលារៀនជាមួយគ្នា** ។ សិស្សត្រូវទស្សន៍ទាយរូបភាពដែលគ្រូកំពុងពណ៌នា... ។ បន្ទាប់មក សិស្សគួរព្យាយាមពណ៌នាអ្វីមួយនៅក្នុងរូបភាពទៅកាន់គ្រូបង្រៀនវិញជាភាសាខ្មែរ ។ គ្រូគួរទស្សន៍ទាយអ្វីដែលពួកគេកំពុងពណ៌នា ។

## ឈុតសកម្មភាពទី៤ ការរៀនលេខ ការប្រកបលេខ ការជជែកអំពីរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល ១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការរៀនលេខ និងការប្រកបលេខ

១. ចូរបង្រៀនលេខដល់សិស្សពីលេខ១ដល់៥ ជាភាសាខ្មែរ ដោយប្រើសម្ភារជាក់ស្តែង។ ចូរបង្ហាញខ្មៅដៃមួយដល់សិស្ស ហើយប្រាប់សិស្សថា "**នេះជាខ្មៅដៃមួយ**"។ ចូរសួរសិស្ស "**តើមានខ្មៅដៃប៉ុន្មាន?**" (១)។ លើកខ្មៅដៃពីរឡើង "**នេះជាខ្មៅដៃលេខពីរ**"។ "**តើមានខ្មៅដៃលេខប៉ុន្មាន?**" (២)។ ចូរធ្វើតាមរបៀបនេះពីលេខមួយដល់លេខប្រាំ។

២. ចូរធ្វើសកម្មភាពដូចមុន។ នៅលើកនេះ ចូរណែនាំបង្ហាញលេខពី៦ដល់១០ ដោយប្រើប្រាស់សម្ភារជាក់ស្តែង។

៣. បង្កើតសិស្សជាក្រុមៗ ដើម្បីរំលឹកលេខពី១ដល់១០ដោយប្រើសម្ភារជាក់ស្តែង (ឧ: ខ្មៅដៃ ឬ បំពង់បឹត)។ សិស្សម្នាក់នៅក្នុងក្រុមនីមួយៗត្រូវបង្ហាញខ្មៅដៃ ឬបំពង់បឹត បន្ទាប់មកសួរថា "**តើមានខ្មៅដៃ/បំពង់បឹតលេខប៉ុន្មាន?**"។ សិស្សផ្សេងទៀតនៅក្នុងក្រុមត្រូវឆ្លើយ។ សិស្សម្នាក់ៗនៅក្នុងក្រុមត្រូវដាក់វេនគ្នាដើម្បីសួរ "**តើមាន..........លេខប៉ុន្មាន?**"។

៤. ការជជែកគ្នាអំពីប័ណ្ណរូបភាពពីលេខ១ដល់១០ដោយប្រើភាសាកំណើតរបស់សិស្ស។ ចូរសួរសំណួរដល់សិស្សអំពីរូបភាពដោយប្រើភាសាកំណើតរបស់សិស្ស "**តើប្អូនមើលឃើញអ្វីខ្លះ?**" "**តើប្អូនមើលឃើញមនុស្សប៉ុន្មាននាក់?**" "**តើពួកគេជានរណា?**" (សិស្សឆ្លើយដោយប្រើភាសាកំណើតរបស់ពួកគេ)។

៥. ចូរប្រើប័ណ្ណរូបភាពដដែលពី១ដល់១០។ នៅពេលនេះ និយាយពីរូបភាពនោះដោយប្រើភាសាខ្មែរម្តង។ "**នេះជាសាលារៀន**"។ "**តើគេនិយាយថាដូចម្តេចនៅក្នុងភាសារបស់ប្អូន?**" (សិស្សឆ្លើយដោយប្រើភាសារបស់ពួកគេ)។ "**នេះជាសិស្សពីរនាក់**" "**តើគេនិយាយថាដូចម្តេចនៅក្នុងភាសារបស់ប្អូន?**" (សិស្សឆ្លើយដោយប្រើភាសារបស់ពួកគេ)។

៦. ចូររំលឹកប័ណ្ណពី១ដល់១០ឡើងវិញដោយប្រើភាសាខ្មែរ។ ចូរប្រាប់សិស្សថា "**នេះជាសាលារៀនមួយ**"។ បន្ទាប់មកសួរសិស្សថា "**តើវាជាអ្វី?**" (សាលារៀនមួយ)។ "**នេះជាសិស្សពីរនាក់**" "**តើមានសិស្សប៉ុន្មាននាក់?**" (២)។

៧. ចូរលើកប័ណ្ណរូបភាពផ្សេងៗឡើង ដោយមិនចាំបាច់តាមលំដាប់លំដោយទេ ហើយសួរសិស្សថា "**តើមាន.......ដែលប្អូនៗមើលឃើញ?**"។ បែងចែកសិស្សជាប្រាំក្រុម។ ចូរផ្តល់ឱ្យក្រុមនីមួយៗនូវប័ណ្ណរូបភាពពីរ ហើយឱ្យក្រុមទាំងនោះប្រាប់គ្នាទៅវិញទៅមកអំពីរូបភាពនៅលើប័ណ្ណ បន្ទាប់មកគ្រូត្រូវប្តូរប័ណ្ណរូបភាពពីក្រុមមួយទៅកាន់ក្រុមផ្សេងទៀត។

៨. ចូររំលឹកលេខពី១ដល់១០ម្តងទៀត។ ចូរបិទរូបភាពរបស់អ្នកនៅលើក្តារខៀនមិនឱ្យត្រូវតាមលំដាប់លំដោយ។ ចូរឱ្យសិស្សឡើងមកក្តារខៀនដើម្បីរៀបប័ណ្ណទាំងនោះឱ្យត្រូវតាមលំដាប់លំដោយពី១ដល់១០។ ប័ណ្ណទី១ គួរតែជា **"សាលារៀន"** ប័ណ្ណទី២ជា **"សិស្សាពីរនាក់"** ។ល។ សិស្សទាំងឡាយនៅក្នុងថ្នាក់ក៏អាចជួយបានដែរ។

៩. ចូរប្រើសម្ភារជាក់ស្តែងដើម្បីរំលឹកលេខនិងវាក្យស័ព្ទថ្មីជាភាសាខ្មែរឡើងវិញ។ ចូរសួរសិស្សថា **"សូមបង្ហាញខ្មៅដៃ៤ដល់ខ្ញុំ"**។ សិស្សត្រូវលើកខ្មៅដៃ៤ឡើង។ **"សូមបង្ហាញកាតាប៣ដល់ខ្ញុំ"** ។ល។

១០. ចូរណែនាំលេខខ្មែរដល់សិស្ស។ ចូរគ្រូបការប្រកបរបស់លេខ បន្ទាប់មកចង្អុលទៅលេខនីមួយៗហើយប្រាប់ថា **"នេះជាលេខមួយ"**។ **"តើនេះជាអ្វី?"** (លេខមួយ)។ **"នេះជាលេខពីរ"** ។ល។

១១. **មើល គ្រូប សរសេរ ផ្ទៀងផ្ទាត់** លេខពី ១ ដល់ ១០ ។ ចូរគ្រូបការប្រកបលេខសម្រាប់សកម្មភាពនេះ ។ ចូរលើកប័ណ្ណមួយឡើងហើយសួរថា **"តើនេះជាលេខប៉ុន្មាន?"** (លេខ២) ។ ចូរគ្រូបប័ណ្ណនោះ ហើយឱ្យសិស្សសរសេរលេខនៅលើក្តារឆ្នួនរបស់ពួកគេ ។ ចូរប្រាប់សិស្ស **"ចូរលើកក្តារឆ្នួនប្អូនៗឡើង"** ។ បន្ទាប់មកបើកប័ណ្ណនោះវិញដើម្បីផ្ទៀងផ្ទាត់ ។

១២. ចូរចែកសិស្សក្នុងថ្នាក់ទៅជាក្រុមដែលមានគ្នា ១០ នាក់ ។ ចូរចែកប័ណ្ណមួយដល់ក្រុមនីមួយៗ ។ គ្រូបការប្រកបរបស់លេខសម្រាប់សកម្មភាពនេះ ។ ចូរហៅសិស្សម្នាក់ពីក្នុងក្រុមនីមួយៗឱ្យឡើងមកខាងមុខហើយប្រាប់សិស្ស **"ចូររៀប ប័ណ្ណរបស់ប្អូនៗឱ្យត្រូវតាមលំដាប់ពី ១ ដល់ ១០"** ។ ថ្នាក់ទាំងមូលអាចជួយបាន ។

១៣. ចូរណែនាំសិស្សឱ្យស្គាល់ពីការប្រកបរបស់លេខពី ១ ដល់ ១០ ។ លើកប័ណ្ណពី ១ ដល់ ១០ ឡើង ។ ចូរចង្អុលលេខ **"តើនេះជាលេខប៉ុន្មាន?"** (លេខ១) ។ ចង្អុលទៅពាក្យ និងនិយាយប្រាប់សិស្ស **"នេះគឺជាលេខមួយ"** ។ ចូរធ្វើសកម្មភាពនេះដោយប្រើប័ណ្ណដែលនៅសល់ ។

១៤. រំលឹកការអានពាក្យថ្មីឡើងវិញជាភាសាខ្មែរ ។ នៅលើកនេះ ចូរគ្រូបលេខនៅលើប័ណ្ណ ។ លើកប័ណ្ណនីមួយៗ ឡើង និងចង្អុលពាក្យតែប៉ុណ្ណោះ។ ចូរសួរសិស្ស **"តើនេះជាលេខប៉ុន្មាន?"** ។ សិស្សអានពាក្យសម្រាប់លេខ "១" ។ ចូរធ្វើ ដូចគ្នាចំពោះលេខពី ២ ដល់ ១០ ។

១៥. ចូរដាក់ប័ណ្ណទាំងអស់ពី ១ ដល់ ១០ នៅលើក្តារខៀនទៅតាមលំដាប់មិនត្រឹមត្រូវ ។ ចូរគ្រូបលេខទាំងនោះ ។ ចូរឱ្យសិស្សរៀបប័ណ្ណឱ្យត្រូវតាមលំដាប់ពី១ដល់១០។ សិស្សគួរតែអានពាក្យ និងរៀបប័ណ្ណឱ្យត្រូវតាមលំដាប់ ។

១៦. ចូរណែនាំឱ្យសិស្សស្គាល់រូបភាព និងប័ណ្ណលេខដែលនៅជាមួយគ្នា ។ ចូរលើកគូរូបភាពនិងលេខពី ១ ដល់ ១០ ឡើង (ឧទាហរណ៍: ប័ណ្ណរូបភាព**សាលារៀន** និងប័ណ្ណលេខ១) ។ ចូរសួរសិស្ស **"តើនេះគឺជាអ្វី?"** (វាគឺជាសាលារៀន) ។ **"តើមានសាលារៀនប៉ុន្មាន?"** (១) ។

១៧. ចូរដាក់រូបភាព និងប័ណ្ណលេខនៅលើក្តារខៀន ។ ចូរឱ្យសិស្សផ្គូរផ្គងរូបភាព និងប័ណ្ណលេខឱ្យបានត្រឹមត្រូវ ។

១៨. ចូរចែកសិស្សក្នុងថ្នាក់ជា ២០ក្រុម ។ ចូរចែកប័ណ្ណមួយដល់ក្រុមនីមួយៗ ។ ចូរប្រាប់ក្រុមនីមួយៗថា **"ប័ណ្ណរបស់ប្អូនៗត្រូវតែមានគូត្រូវគ្នា ។ ចូររកក្រុមដែលមានគូប័ណ្ណរបស់ប្អូនៗ"** ។ សិស្សត្រូវតែដើរជុំវិញថ្នាក់ដើម្បីរកក្រុមដែលមានរូបភាព ឬ ប័ណ្ណលេខដែលត្រូវគ្នាជាមួយប័ណ្ណពួកគេ ។

## II. ការផ្ទៃងផ្ទាត់អំពីរូបភាព និងរឿងនិទាន " មិត្តសំលាញ់របស់ខ្ញុំ "

១. ចូរសួរសំណួរសិស្សដោយប្រើប្រភេទសំណួរខុស និង ត្រូវ អំពីខ្លឹមសាររូបភាព។ ចូរប្រើភាសាខ្មែរ ប៉ុន្តែត្រូវជួយពួកគេដោយប្រើភាសាកំណើតរបស់សិស្ស បើសិនជាចាំបាច់។

**សិស្សកំពុង មើល គ្រប សរសេរ ត្រួតពិនិត្យ ជាមួយគ្នា** (ខុស ឬ ត្រូវ?)

**មានតែសិស្សាទេ ដែលកំពុងបរិភោគជាមួយគ្នា** (ខុស ឬ ត្រូវ?)

**សិស្សកំពុងជជែកគ្នាយ៉ាងសប្បាយរីករាយ** (ខុស ឬ ត្រូវ?)

**សិស្សទាំងអស់មិនចូលចិត្តលេងនៅក្នុងទីធ្លាសាលារៀនទេ** (ខុស ឬ ត្រូវ?)

**២.** ចូរពណ៌នាខ្លីៗពីមិត្តរបស់អ្នក (គ្រូ) ទៅកាន់សិស្សជាភាសាខ្មែរ។ សិស្សគួរតែគូរនូវអ្វីដែលពួកគេបានឮពីការពណ៌នា។ ពួកគេនឹងត្រូវការក្រដាស និងខ្មៅដៃពណ៌។ ចូរអានការពណ៌នាចំនួនបីឬបួនដងទៅកាន់សិស្ស។

**មិត្តរបស់ខ្ញុំឈ្មោះ ណាង ។ នាងមានកំពស់ល្មម ហើយមានសក់ពណ៌ខ្មៅវែង។ នាងជាមនុស្សចិត្តល្អ និងរីករាយ។ នាងចូលចិត្តស្លៀកពាក់ពណ៌ក្រហម។**

ចូរឱ្យសិស្សបង្ហាញរូបភាពទៅកាន់ដៃគូរបស់ពួកគេ។ ចូរឱ្យសិស្សលើកបង្ហាញរូបភាពនោះឡើង។ ចូរត្រួតពិនិត្យថាតើរូបភាពនោះត្រូវនឹងការពណ៌នារបស់អ្នកដែរឬទេ។

ចូរឱ្យសិស្សធ្វើការជាដៃគូនិងពណ៌នាពីមិត្តរបស់ពួកគេដោយប្រើភាសាខ្មែរ។ សមាជិកម្នាក់ក្នុងដៃគូនីមួយៗត្រូវព្យាយាមគូររូបមិត្តនៅក្នុងការពណ៌នានោះឱ្យបានត្រឹមត្រូវតាមដែលអាចធ្វើបាន។

# មេរៀនទី៧ រាងកាយរបស់យើង



**គោលបំណងមេរៀន**

សិស្សថ្នាក់ទី១ នឹងរៀន:

- ចំរៀង/ ពាក្យចុងចួន / មេសូត្រជាភាសាខ្មែរ
- បទបញ្ជារបស់ថ្នាក់រៀន
- ភាសានៃការស្វាគមន៍ និងការណែនាំគ្នា
- លេខពី ១-១០
- ចូលរួមជជែករូបភាពអំពីផ្នែកផ្សេងៗនៃរាងកាយ

**ធនធានសម្រាប់បង្រៀន**

សម្ភារមានដូចជា:

- ប័ណ្ណរូបភាពសម្រាប់រៀនលេខ និង ឈ្មោះរបស់លេខ
- រូបភាព "រាងកាយរបស់ខ្ញុំ"

ចូរបែងចែងពេលវេលារបស់លោកគ្រូ/អ្នកគ្រូដើម្បីធ្វើសកម្មភាពខ្លីៗពីឈុតសកម្មភាពទាំង៥ខាងក្រោម ។ ចូរព្យាយាមធ្វើសកម្មភាពពី៤ទៅ៥ ខុសៗគ្នានៅក្នុងមេរៀនរយៈពេលមួយម៉ោង របស់លោកគ្រូ/អ្នកគ្រូ ។

## ឈុតសកម្មភាពទី១ ចំរៀង ការជជែកអំពីរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល១ម៉ោង របស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

**I. ចំរៀង "សត្វសារិកាកែវ"**

សារិកាកែវពត់ប្រាណ

| | | |
|---|---|---|
| សារិកាកែវអើយ | ស៊ីអីកងកង<br>អើយកែវៗអើយ (២ដង) ។ | សិស្សត្រសងនាំគ្នាពត់ប្រាណ |
| យើងខំលើកដៃ | លើកជើងឱ្យបាន ខំពត់ទាំងប្រាណទើបសុខភាពល្អ<br>អើយកែវៗអើយ (២ដង) ។ | |

១. ចូរប្រាប់សិស្សថាអ្នកនឹងច្រៀងចំរៀងខ្មែរមួយបទឱ្យពួកគេស្តាប់ ដែលចំរៀងនេះមានចំណងជើងថា **"សារិកាកែវ"**។ ចូរបកប្រែពាក្យនេះជាភាសាកំណើតរបស់សិស្ស ដើម្បីជួយឱ្យពួកគេងាយយល់។ ចូរសួរសិស្សថា **"តើប្អូនៗស្គាល់សត្វនេះឬទេ?"** **"តើប្អូនៗអាចរកសត្វនេះឃើញនៅក្នុងភូមិឬទេ?"**។ ចូរប្រាប់សិស្សថាសត្វសារិកាកែវគឺជាបក្សីវ័យឆ្លាត។ ពួកបក្សីទាំងនេះចូលចិត្តធ្វើតាមសកម្មភាពរបស់មនុស្ស។

ចូរឈរនៅខាងមុខសិស្ស ហើយច្រៀងចំរៀងឱ្យសិស្សស្តាប់ដោយប្រើសកម្មភាព។ គ្រូបង្រៀនត្រូវប្រាកដក្នុងចិត្តថាសកម្មភាពរបស់ខ្លួនច្បាស់លាស់។ សិស្សអង្គុយស្តាប់ និងមើលតែសកម្មភាពរបស់គ្រូប៉ុណ្ណោះ។

២. ចូរក្រោកឈរហើយច្រៀងចំរៀងទៅកាន់សិស្សដោយប្រើសកម្មភាព។ សិស្សមើល និងស្តាប់គ្រូ។ ចូរហៅឱ្យសិស្សក្រោកឈរ ហើយសួរសិស្សថា **"តើសត្វសារិកាកែវធ្វើសកម្មភាពអ្វីខ្លះ?"** (សិស្សបង្ហាញសកម្មភាពដល់គ្រូបង្រៀន)។ ចូរផ្តល់ក្រដាស និងខ្មៅដៃពណ៌ឱ្យសិស្ស ហើយឱ្យពួកគេគូររូបសត្វសារិកាកែវនោះ។ បន្ទាប់មកយកគំនូរនេះ ដាក់បង្ហាញលើក្តារខៀន។

៣. ចូរច្រៀងចំរៀងដោយប្រើសកម្មភាព។ ឥឡូវនេះ ចូរអានចំរៀងតាមជួរបន្ទាត់នីមួយៗឱ្យបានយឺតៗ។ សិស្សស្តាប់និងថាតាមគ្រូ។ ចូរអានចំរៀងតាមជួរនីមួយៗម្តងទៀត។ សិស្សស្តាប់ និងនិយាយតាមគ្រូ។

៤. ការអនុវត្តបំពេញចន្លោះដោយផ្ទាល់មាត់។ ចូរច្រៀងចំរៀងម្តងទៀត។ បន្ទាប់មកអានជួរបន្ទាត់នីមួយៗ ប៉ុន្តែយូៗម្តងគ្រូត្រូវរំលងពាក្យខ្លះ ហើយឱ្យសិស្សព្យាយាមរកពាក្យដែលបាត់នោះមកបំពេញ (ដោយផ្ទាល់មាត់ប៉ុណ្ណោះ)។

៥. ចូរអានចំរៀងជាមួយសិស្ស បន្ទាប់មកចែកសិស្សក្នុងថ្នាក់ជាពីរក្រុម។ ក្រុមម្ខាងអានជួរបន្ទាត់ចំរៀងដំបូង និងក្រុមម្ខាងទៀតអានចំរៀងជួរបន្ទាប់។ ចូរជួយសិស្សបើសិនជាចាំបាច់។

៦. ចូរច្រៀងចំរៀងជាមួយសិស្ស ដោយធ្វើសកម្មភាពក្នុងពេលដំណាលគ្នា។ ឥឡូវនេះ ចូរចាប់ផ្តើមច្រៀងចំរៀងពីដើមដំបូងឡើងវិញ។ ចូរច្រៀងចំរៀងក្នុងជួរបន្ទាត់ដំបូងដោយប្រើសកម្មភាព ហើយឱ្យសិស្សធ្វើតាម។ ចូរច្រៀងចំរៀងជួរបន្ទាត់ទីពីរដោយធ្វើសកម្មភាព ហើយឱ្យសិស្សធ្វើតាម។ គ្រូអនុវត្តតាមវិធីនេះរហូត ចប់ចំរៀង។

៧. ចូរច្រៀងចំរៀងម្តងទៀត ហើយឱ្យសិស្សធ្វើតែសកម្មភាពក្នុងខណៈពេល ដែលអ្នកកំពុងច្រៀង។ ចូរត្រួតពិនិត្យថាតើពួកគេអាចធ្វើសកម្មភាពត្រឹមត្រូវឬទេ។

៨. ចូរបែងចែកសិស្សជាដៃគូ។ ចូរច្រៀងចំរៀងទៅកាន់សិស្ស ហើយក្នុងពេលដែលអ្នកកំពុងច្រៀង ដៃគូនីមួយៗគួរតែធ្វើសកម្មភាពរួមគ្នា។ ចូរច្រៀងចំរៀងម្តងទៀត។ ចូរប្រាប់ឱ្យសិស្សព្យាយាមច្រៀងនិងធ្វើសកម្មភាពក្នុងពេលដំណាលគ្នា។

៩. ចូរប្រាប់ឱ្យសិស្សទាំងអស់ក្រោកឈរ ហើយច្រៀងចំរៀងជាមួយអ្នក ដោយប្រើសកម្មភាព។

## II. ការចំរែកអំពីរូបភាព និងរឿងនិទាន " រាងកាយរបស់យើង "

**បញ្ជីពាក្យ**

ក្បាល ក ដៃ ម្រាមជើង

| | | |
|---|---|---|
| ភ្នែក | ស្មា | ម្រាមដៃ |
| ច្រមុះ | ទ្រូង | ជើង |
| ត្រចៀក | ក្រពះ | ជង្គង់ |
| មាត់ | | ប្រអប់ជើង |

**ពាក្យរំលឹក**

| | | | |
|---|---|---|---|
| ក្រហម | វែង | អាវយឺត | ទីមួយ |
| ខៀវ | ខ្លី | សារ៉ុង | ទីពីរ |
| លឿង | ខ្ពស់ | ខោវែង | ទីបី |
| ស | ធំ | អាវ | |
| ខ្មៅ | តូច | មួក | |

១. ការផ្តល់សេចក្តីណែនាំដោយប្រើភាសាកំណើតរបស់សិស្ស

ចូប្រាប់សិស្សថា ពួកគេនឹងជជែកគ្នាអំពីរាងកាយរបស់ពួកគេ និងរៀនពីផ្នែកផ្សេងៗរបស់រាងកាយ ។ ចូរលេងល្បែងនេះជាមួយសិស្សនៅលើកតំបូង ដោយប្រើភាសាកំណើតរបស់គេ ។ ចូផ្តល់សេចក្តីណែនាំមួយចំនួនទៅកាន់សិស្ស ឧ. "ចូរស្ទាបច្រមុះរបស់ប្អូន" ។ ចូរធ្វើសកម្មភាពជាគំរូផងដែរក្នុងពេលផ្តល់សេចក្តីណែនាំ ។ ចូរផ្តល់សេចក្តីណែនាំ ដោយប្រើប្រាស់ផ្នែកផ្សេងៗនៃរាងកាយ ។ ចូរធ្វើសកម្មភាពជាគំរូក្នុងពេលតែមួយ ។

ចូរផ្តល់សេចក្តីណែនាំម្តងទៀត ។ នៅលើកនេះ ចូរកុំធ្វើសកម្មភាពជាគំរូ ។ ចូរត្រួតពិនិត្យថាតើ សិស្សចង្អុលត្រូវផ្នែកផ្សេងៗនៃរាងកាយឬយ៉ាងណា ។

ចូរផ្តល់សេចក្តីណែនាំផ្សេងៗទៀត ដោយបង្ហាញឈ្មោះផ្នែកនៃរាងកាយច្រើនជាងមួយ ឧ. "ចូរស្ទាបក្បាលរបស់ប្អូន ភ្នែករបស់ប្អូន បន្ទាប់មកច្រមុះរបស់ប្អូន" ។ ចូរត្រួតពិនិត្យថាតើសិស្សអាចអនុវត្តតាមសេចក្តីណែនាំឬយ៉ាងណា ។

ចូរសួរសិស្សដទៃទៀតឱ្យផ្តល់សេចក្តីណែនាំទៅកាន់អ្នក ( គ្រូ) ។ ចូរស្តាប់សេចក្តីណែនាំរបស់ពួកគេ ហើយធ្វើតាម ។

ចូរបែងចែកសិស្សក្នុងថ្នាក់ជាក្រុមដោយមានគ្នា៥ឬ៦នាក់ ។ សិស្សម្នាក់នៅក្នុងក្រុមនីមួយៗផ្តល់សេចក្តីណែនាំទៅកាន់ក្រុម ។ សមាជិកផ្សេងៗត្រូវធ្វើតាមសេចក្តីណែនាំរបស់ពួកគេ ។ សិស្សម្នាក់ៗនៅក្នុងក្រុមមានឱកាសផ្តល់បទបញ្ជាដូចៗគ្នា ។

២. ការរំលឹកផ្នែកផ្សេងៗនៃរាងកាយដោយប្រើភាសាកំណើតរបស់សិស្ស ។ ការបង្កើតបញ្ជីពាក្យ ។

ចូរប្រាប់ឱ្យសិស្សរំលឹកពាក្យដែលប្រើប្រាស់សម្រាប់ពណ៌នាពីផ្នែកផ្សេងនៃរាងកាយ ។ ចូរសួរសិស្សឱ្យប្រាប់ពីអ្វីដែលពួកគេបានរៀន ។ ចូរស្តាប់គំនិតរបស់ពួកគេ ។ ចូរបង្កើតបញ្ជីពាក្យទាំងនេះនៅលើក្រដាសវ៉ាមធំ ជាភាសាកំណើតរបស់សិស្ស ។

ចូរអានបញ្ជីនេះឱ្យសិស្សស្តាប់ និងក្រោយមកអានជាមួយសិស្សរួមគ្នា ។ ចូរចង្អុលទៅកាន់ពាក្យនីមួយៗនៃផ្នែករបស់រាងកាយដែលពាក់ព័ន្ធគ្នានៅលើបញ្ជីពាក្យ ឧ. ច្រមុះ ក្បាល ភ្នែក ។

ចូរផ្តល់ក្រដាស និងខ្មៅដៃឱ្យសិស្ស ។ ចូរឱ្យពួកគេគូរគំនូមិត្តរបស់ពួកគេនៅក្នុងថ្នាក់ ។ ពួកគេត្រូវដាក់ស្លាកសម្គាល់ផ្នែកផ្សេងៗនៃរាងកាយមិត្តរបស់ពួកគេជាភាសាកំណើត ។ ពួកគេអាចចម្លងពាក្យពីបញ្ជីពាក្យដើម្បីត្រួតពិនិត្យការសរសេរអក្ខរាវិរុទ្ធ... ។

ចូរឱ្យសិស្សបង្ហាញ និងពណ៌នាគំនូររបស់ពួកគេ ។ សិស្សក្នុងថ្នាក់ត្រូវទស្សន៍ទាយថា តើនរណាគេនៅក្នុងគំនូរនោះ ។

៣. ចូរធ្វើតាមសកម្មភាពទី១ឡើងវិញដោយប្រើភាសាខ្មែរ ។ នៅលើកនេះ ចូរផ្តល់សេចក្តីណែនាំដោយប្រើភាសាខ្មែរ ។
ចូរធ្វើសកម្មភាពជាគំរូក្នុងពេលផ្តល់សេចក្តីណែនាំ ។ "ចូរស្ទាបក្បាលរបស់ប្អូន" ។
ចូរធ្វើគំរូដោយយកដៃស្ទាបក្បាលរបស់អ្នក ( គ្រូ) ។ ចូរផ្តល់សេចក្តីណែនាំជាភាសាខ្មែរ
ដោយនិយាយពីផ្នែកផ្សេងៗនៃរាងកាយ ព្រមទាំងធ្វើសកម្មភាពជាគំរូក្នុងពេលតំណាលគ្នា

## ឈុតសកម្មភាពទី២ បទបញ្ជាក្នុងថ្នាក់រៀន ការជជែកអំពីរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល១ម៉ោង របស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. បទបញ្ជាក្នុងថ្នាក់រៀន

សូមក្រោកឈរឡើង



សូមអង្គុយចុះ





សូមលើកដៃរបស់ប្អូន

សូមឈប់ជជែកគ្នា

សូមស្តាប់

សូមយកក្តារឆ្នួន និងដីសរបស់ប្អូនចេញមក



សូមឡើងក្តារខៀន

សូមថាតាមខ្ញុំ

១. ការណែនាំបង្ហាញបទបញ្ជាក្នុងថ្នាក់រៀនថ្មីពីរដោយប្រើប្រាស់ភាសាកំណើតរបស់សិស្ស "**សូមឡើងក្តារខៀន**" និង "**សូមថាតាមខ្ញុំ**"។ ចូរធ្វើបង្ហាញបទបញ្ជាដល់សិស្ស។ សិស្សមើលនិងស្តាប់ បន្ទាប់មកឱ្យអនុវត្តតាមគំរូរបស់ អ្នក។

២. នៅពេលនេះចូរបង្ហាញបទបញ្ជាដោយប្រើភាសាខ្មែរម្តង។ ចូរធ្វើជាគំរូ បន្ទាប់មកសួរសិស្សថា "**តើនៅក្នុងភាសារបស់ប្អូនគេនិយាយដូចម្តេច?**"។

៣. ចូររំលឹកបទបញ្ជាទាំងអស់ឡើងវិញ។ ហៅសិស្សប្អូននាក់មកកាន់ខាងមុខថ្នាក់ ហើយផ្តល់បទបញ្ជាមួយ (ឧៈ **សូមលើកដៃរបស់ប្អូន១ឡើង**)។ សិស្សត្រូវស្តាប់ហើយធ្វើតាមអ្វីដែលអ្នកប្រាប់។ ឥឡូវនេះ ចូរផ្តល់បទបញ្ជាពីរ (ឧៈ **សូមលើកដៃរបស់ប្អូនឡើងហើយដើរសំដៅទៅក្តារខៀន**)។ សិស្សត្រូវស្តាប់ហើយធ្វើតាមអ្វីដែលអ្នកប្រាប់។

៤. ចូរបែងចែកសិស្សក្នុងថ្នាក់ជាបួន ឬ ប្រាំក្រុម។ ចូរឱ្យសិស្សម្នាក់នៅក្នុងក្រុមនីមួយៗធ្វើជា "គ្រូ"។ គ្រូនីមួយៗត្រូវផ្តល់បទបញ្ជាផ្សេងទៅកាន់ក្រុមរបស់ខ្លួន។ ក្រុមនីមួយៗត្រូវស្តាប់ ហើយធ្វើតាមអ្វីដែលគ្រូរបស់ខ្លួនសួរ។

៥. ចូរអនុវត្តបទបញ្ជាថ្មីមួយជារៀងរាល់ថ្ងៃ។ ចូរណែនាំបង្ហាញដោយប្រើប្រាស់ភាសារបស់សិស្សជាដំបូងសិន។ ចូរធ្វើជាគំរូ។ ចូរណែនាំបង្ហាញម្តងទៀតជាភាសាខ្មែរ។ ចូរធ្វើជាគំរូ។

៦. ចូរសម្តែងតួប្រើប្រាស់បទបញ្ជាមួយ ដោយឱ្យសិស្សនិយាយបទបញ្ជានោះផ្ទាល់មាត់ជាភាសាខ្មែរ។

៧. សិស្សជ្រើសរើសបទបញ្ជាមួយហើយផ្តល់ទៅឱ្យសិស្សផ្សេងៗទៀតនៅក្នុងថ្នាក់ដោយប្រើភាសាខ្មែរ។ សិស្សទាំងឡាយឆ្លើយតបឱ្យបានសមស្រប។

៨. ចូរបែងចែកសិស្សជាក្រុមតូចៗ ហើយឱ្យសិស្សម្នាក់នៅក្នុងក្រុមសម្តែងតួផ្តល់បទបញ្ជាទៅកាន់ក្រុមខ្លួន។ សមាជិកក្រុមទស្សន៍ទាយបទបញ្ជានោះ ហើយប្រាប់ថាវាជាអ្វី។

៩. ចូរឱ្យសិស្សគូររូបភាពឱ្យត្រូវនឹងបទបញ្ជានីមួយៗ បន្ទាប់មកបង្ហាញគំនូររបស់ពួកគេទៅសិស្សទាំងឡាយ។ សិស្សទាំងឡាយត្រូវទស្សន៍ទាយបទបញ្ជានោះឱ្យត្រូវនឹងគំនូរ។

## II. ការចែករំលែកអំពីរូបភាព និងរឿងនិទាន " រាងកាយរបស់យើង "

៤. ការរំលឹកពីផ្នែកផ្សេងៗនៃរាងកាយជាភាសាខ្មែរ។ ការបង្កើតបញ្ជីពាក្យដោយផ្ទាល់មាត់។

ចូរឱ្យសិស្សប្រាប់អ្នកពីផ្នែកផ្សេងៗនៃរាងកាយដែលពួកគេបានរៀនជាភាសាខ្មែរ ។ ចូរស្តាប់គំនិតរបស់ពួកគេ ។ ចូរបិទបញ្ជីពាក្យក្នុងសកម្មភាពទី២នៅលើក្តារខៀន ។ ចូរចង្អុលទៅកាន់ពាក្យនីមួយៗដោយប្រើភាសាកំណើតរបស់សិស្ស ហើយស្តាប់នៅពេលសិស្សអានពាក្យទាំងនោះ ។ ចូរសួរសិស្សឱ្យបកប្រែជាភាសាខ្មែរ ។ ចូរកុំសរសេរពាក្យទាំងនេះ ។ ចូរឱ្យពួកគេចង្អុលទៅកាន់ផ្នែកផ្សេងៗនៅលើរាងកាយរបស់ពួកគេទៅតាមពាក្យពណ៌នា ។

ឥឡូវនេះ ចូរចង្អុលទៅកាន់ផ្នែកផ្សេងៗនៃរាងកាយរបស់អ្នក និងសួរជាភាសាខ្មែរ "តើនេះជាអ្វី?" ។ សិស្សប្រាប់អ្នកពីឈ្មោះផ្នែកនៃរាងកាយទាំងនោះជាភាសាខ្មែរ ។

៥. វិធី ធ្វើ ពិភាក្សា កត់ត្រា ជាភាសាខ្មែរ

ចូរនាំសិស្សដើរនៅក្នុងភូមិ ហើយឱ្យសិស្សមើលសត្វផ្សេងនៅក្នុងភូមិនោះ ។ ចូរសួរសិស្ស "តើសត្វនេះឈ្មោះអ្វី?" (ឆ្កែ) "តើវាមានពណ៌អ្វី?" (ខ្មៅ) "តើឆ្កែមានជើង/ក្បាល/ភ្នែក ។ល។ ឬទេ?" (សិស្សឆ្លើយ) ។ "តើឆ្កែមានជើងប៉ុន្មាន?" (៤) ។ ចូរនិយាយអំពីសត្វផ្សេងៗទៀតដែលពួកគេឃើញ និងផ្នែកផ្សេងនៃរាងកាយសត្វនោះ ។

ចូរត្រឡប់ទៅកាន់ថ្នាក់រៀនវិញ ។ សិស្សត្រូវគូររូបសត្វដែលពួកគេបានឃើញ ។ ពួកគេត្រូវបង្ហាញគំនូរ និងនិយាយពីផ្នែកផ្សេងៗនៃរាងកាយសត្វនោះ ជាភាសាខ្មែរ ។ ចូរជួយសិស្សនៅពេលចាំបាច់ជាភាសាកំណើតរបស់សិស្ស ។

## ឈុតសកម្មភាពទី៣ ការស្វាគមន៍គ្នា ការចែករំលែកអំពីរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល១ម៉ោងរបស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

### I. ការស្វាគមន៍គ្នា

ឧទាហរណ៍: អរុណសួស្តី ។ តើសំឡាញ់សុខសប្បាយឬទេ ថ្ងៃនេះ? (ខ្ញុំសុខសប្បាយជាទេ សូមអរគុណ)
សាយ័ណសួស្តី ។

១. ចូរណែនាំការស្វាគមន៍គ្នាជាភាសាខ្មែរ ហើយឱ្យសិស្សថាតាមអ្នក ។
២. ចូរនិយាយពាក្យស្វាគមន៍គ្នា ។ សិស្សឆ្លើយតបឱ្យបានសមរម្យ ។
៣. សិស្សសម្តែងតួជាគូៗ ធ្វើជាគ្រូ និងសិស្ស/សិស្ស និងសិស្ស ។



៤. ចូរប្រើរូបភាព
ហើយសួរសំណួរដោយប្រើភាសាកំណើតរបស់សិស្ស ។ "**តើមនុស្សទាំងនេះជានរណា**"
"**តើពួកគេនៅឯណា**"
"**តើស្ត្រីម្នាក់នោះកំពុងនិយាយអ្វីខ្លះទៅកាន់សិស្សី?**"
។ល។

៥. ចូរប្រើរូបភាពហើយធ្វើសកម្មភាពដូចមុន ប៉ុន្តែប្រើតែភាសា ខ្មែរតែប៉ុណ្ណោះ ។

៦. ចូរប្រើភាសាកំណើតរបស់សិស្ស ដើម្បីប្រាប់ពីវត្ថុផ្សេងនៅក្នុងរូបភាព ។ "**នេះគឺជាក្តារខៀន/ទូ/គ្រូបង្រៀន**" ។ល។ ចូរសួរសិស្ស "**តើនេះជាអ្វី?**" (ក្តារខៀន) ។ល។

៧. ចូរធ្វើសកម្មភាពដូចលើកមុន ប៉ុន្តែលើកនេះត្រូវប្រើភាសាខ្មែរម្តង ។

៨. ចូរប្រើរូបភាព ហើយអានការសន្ទនាខាងក្រោមទៅកាន់សិស្សលេខពីរ ឬបីដង ។ សិស្សស្តាប់ ។

<u>គ្រូ</u> អរុណសួស្តីមីរ៉ា ។ តើប្អូនសុខសប្បាយឬទេ ថ្ងៃនេះ?

<u>សិស្ស</u> សុខសប្បាយណាស់ សូមអរគុណអ្នកគ្រូ ។ តើអ្នកគ្រូសុខសប្បាយឬទេ ថ្ងៃនេះ?

<u>គ្រូ</u> សុខសប្បាយណាស់ សូមអរគុណប្អូន ។ តើអ្នកគ្រូអាចជួយកិច្ចការធ្វើនៅផ្ទះរបស់ប្អូនបានឬទេ?

<u>សិស្ស</u> ចាស៎ អ្នកគ្រូ ។

៩. ចូរប្រើរូបភាព និងការសន្ទនាម្តងទៀត ។ ចូរនិយាយការសន្ទនា ហើយសិស្សថាតាមអ្នក ។

១០. ចូរសម្តែងការសន្ទនាជាមួយសិស្សក្នុងថ្នាក់ ។ អ្នកត្រូវសម្តែងតួធ្វើជាគ្រូ ហើយឱ្យសិស្សឆ្លើយតប ។

១១. ចូរបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ ក្រុមទីមួយសម្តែងតួជាគ្រូបង្រៀន និងក្រុមមួយទៀតសម្តែងតួជាសិស្ស ។

## II. ការផ្ដែកអំពីរូបភាព និងរឿងនិទាន " រាងកាយរបស់យើង "

៦. ការស្ទង់មតិសិស្សថ្នាក់ទី១

ចូរធ្វើការស្ទង់មតិតូចមួយដែលមានសិស្សចំនួន១០នាក់ដើម្បីរំលឹកពីផ្នែកផ្សេងៗនៃរាងកាយ និងដើម្បីរំលឹកពីចំនួន ។ នៅលើក្រដាសវ៉ាមធំ ចូរសរសេរពាក្យសម្រាប់ផ្នែកខុសៗគ្នាចំនួន៣នៃរាងកាយជាភាសាកំណើតរបស់សិស្ស ឧ. ក្បាល ភ្នែក ជើង ។ ចូរនិយាយពីបញ្ជីនោះជាភាសាខ្មែរ ។ ចូរចង្អុលទៅកាន់ផ្នែកផ្សេងៗនៃរាងកាយ "តើនេះជាអ្វី?" (សិស្សឆ្លើយដោយប្រើពាក្យខ្មែរឱ្យបានត្រឹមត្រូវ) ។

ចូរជ្រើសរើសសិស្ស១០នាក់ ។ ចូរឱ្យសិស្សទាំងនេះឈរនៅខាងមុខថ្នាក់ ហើយសិស្សក្នុងថ្នាក់នឹងរាប់ចំនួន ក្បាល ភ្នែក មាត់ ដែលពួកគេមើលឃើញនៅក្នុងក្រុម ។ សិស្សទាំងអស់រាប់រួមគ្នា ។ ចូរកត់ត្រាចំនួននោះនៅលើក្រដាសវ៉ាមធំ ។

| ផ្នែកនៃរាងកាយ | ចំនួន |
|---|---|
| ក្បាល | ១០ |
| ភ្នែក | ២០ |
| ច្រមុះ | ១០ |

ចូរនិយាយប្រាប់ពតិមាននេះទៅកាន់សិស្សទាំងអស់។ "តើមានច្រមុះប៉ុន្មាន?" (១០) "តើយើងអាចរាប់ថាមានច្រមុះច្រើនឬក្បាលច្រើនបានឬទេ?" (ច្រមុះច្រើន)។

ចូរបែងចែកសិស្សក្នុងថ្នាក់ជាក្រុម១ដែលមានចំនួន៥ឬ៦នាក់។ ក្រុមនីមួយ១អាចធ្វើការស្ទង់មតិដូចគ្នារួមគ្នា។ ចូរជ្រើសរើសផ្នែកផ្សេង១នៃរាងកាយដើម្បីធ្វើការស្ទង់មតិ ឧ. ជើង ម្រាមដៃ ត្រចៀក។ ចូរសរសេរពាក្យទាំងនេះនៅលើក្រដាសវ៉ាមធំ។ ចូរជួយក្រុមនីមួយ១នៅពេលពួកគេរាប់ បើសិនជាចាំបាច់។

ចូរឱ្យក្រុមទាំងឡាយរាយការណ៍ត្រឡប់ទៅកាន់សិស្សក្នុងថ្នាក់នូវចំនួននោះ។ ចូរកត់ត្រាចំនួននៅលើក្រដាសវ៉ាមធំ។ ចូរសួរសំណួរ "តើមាន................ប៉ុន្មាននៅក្នុងក្រុមរបស់អ្នក?" (ជើង១០/ត្រចៀក១០) ។ល។

៧. ការបង្ហាញពីរូបភាព "រាងកាយរបស់ពួកយើង"

ចូរប្រាប់សិស្សអំពីរូបភាពជាភាសាកំណើតរបស់ពួកគេ។

សិស្សទាំងអស់នេះជាមិត្តសំលាញ់នឹងគ្នា ហើយពួកគេចូលចិត្តលេងជាមួយគ្នាណាស់។ សិស្សខ្លះមានអាយុច្រើនជាងសិស្សផ្សេងទៀត។ សិស្សខ្លះមានកំពស់ខ្ពស់ជាងសិស្សផ្សេងទៀត។ ពួកគេទាំងអស់មានជើង។ ជើងរបស់ពួកគេរត់បានលឿនណាស់។ ពួកគេទាំងអស់មានដៃ។ ពួកគេប្រើដៃសម្រាប់កាន់បាល់ និងធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។ ពួកគេទាំងអស់មានមាត់។ ពួកគេប្រើមាត់សម្រាប់និយាយគ្នា។ ពួកគេទាំងអស់មានភ្នែក។ ពួកគេប្រើភ្នែកសម្រាប់មើល។ ពួកគេទាំងអស់មានត្រចៀក។ ពួកគេប្រើត្រចៀកសម្រាប់ស្តាប់។

ឥឡូវនេះ ចូរចង្អុលទៅកាន់សិស្សទាំងឡាយនៅក្នុងរូបភាព ហើយសួរសំណួរ។ ចូរចង្អុលទៅកាន់ផ្នែកផ្សេង១នៃរាងកាយ ឧ. ជើង។ ចូរសួរ "តើយើងប្រើជើងសម្រាប់ធ្វើអ្វី?" (រត់ ដើរ លោត)។ ចូរឱ្យសិស្សធ្វើសកម្មភាពបង្ហាញអ្នក "រត់" "ដើ" "លោត" ដោយប្រើជើងរបស់ពួកគេ។ ចូរសួរសំណួរដូចគ្នា សម្រាប់ផ្នែកផ្សេង១ទៀតនៃរាងកាយ។

៨. ចូរធ្វើសកម្មភាពទី៧ឡើងវិញដោយប្រើភាសាខ្មែរ

នៅលើកនេះ ចូរប្រាប់សិស្សអំពីរូបភាពជាភាសាខ្មែរ។ ចូរសួរសំណួរដូចគ្នា ដោយប្រើភាសាខ្មែរ។ ចូរជួយសិស្សដោយប្រើភាសាកំណើតរបស់គេ បើសិនជាចាំបាច់។

## ឈុតសកម្មភាពទី៤ ការរៀនលេខ ការប្រកបលេខ ការចចែកអំពីរូបភាព និងរឿងនិទាន

**ចូរជ្រើសរើសជំហានសកម្មភាពបង្រៀនខាងក្រោម ឱ្យបានសមស្របសម្រាប់ប្រើនៅក្នុងមេរៀនរយៈពេល១ម៉ោង របស់លោកគ្រូ/អ្នកគ្រូ ( ឧទាហរណ៍: សកម្មភាព៤ឬ៥ដំបូង)**

## I. ការរៀនលេខ និង ការប្រកបលេខ

១. ចូរបង្រៀនលេខដល់សិស្សពីលេខ១ដល់៥ ជាភាសាខ្មែរ ដោយប្រើសម្ភារជាក់ស្តែង។ ចូរបង្ហាញខ្មៅដៃមួយដល់សិស្ស ហើយប្រាប់សិស្សថា "**នេះជាខ្មៅដៃមួយ**"។ ចូរសួរសិស្ស "**តើមានខ្មៅដៃប៉ុន្មាន?**" (១)។ លើកខ្មៅដៃពីរឡើង "**នេះជាខ្មៅដៃលេខពីរ**"។ "**តើមានខ្មៅដៃលេខប៉ុន្មាន?**" (២)។ ចូរធ្វើតាមរបៀបនេះពីលេខមួយដល់លេខប្រាំ។

២. ចូរធ្វើសកម្មភាពដូចមុន។ នៅលើកនេះ ចូរណែនាំបង្ហាញលេខពី៦ដល់១០ ដោយប្រើប្រាស់សម្ភារជាក់ស្តែង។

៣. បង្កើតសិស្សជាក្រុម២ ដើម្បីរំលឹកលេខពី១ដល់១០ដោយប្រើសម្ភារជាក់ស្តែង (ឧ: ខ្មៅដៃ ឬ បំពង់បឺត)។ សិស្សម្នាក់នៅក្នុងក្រុមនីមួយៗត្រូវបង្ហាញខ្មៅដៃ ឬបំពង់បឺត បន្ទាប់មកសួរថា "**តើមានខ្មៅដៃ/បំពង់បឺតលេខប៉ុន្មាន?**"។ សិស្សផ្សេងទៀតនៅក្នុងក្រុមត្រូវឆ្លើយ។ សិស្សម្នាក់ៗនៅក្នុងក្រុមត្រូវដាក់វេនគ្នាដើម្បីសួរ "**តើមាន...........លេខប៉ុន្មាន?**"។

៤. ការជជែកគ្នាអំពីប័ណ្ណរូបភាពពីលេខ១ដល់១០ដោយប្រើភាសាកំណើតរបស់សិស្ស។ ចូរសួរសំណួរដល់សិស្សអំពីរូបភាពដោយប្រើភាសាកំណើតរបស់សិស្ស "**តើប្អូនមើលឃើញអ្វីខ្លះ?**" "**តើប្អូនមើលឃើញមនុស្សប៉ុន្មាននាក់?**" "**តើពួកគេជានរណា?**" (សិស្សឆ្លើយដោយប្រើភាសាកំណើតរបស់ពួកគេ)។

៥. ចូរប្រើប័ណ្ណរូបភាពដដែលពី១ដល់១០។ នៅពេលនេះ និយាយពីរូបភាពនោះដោយប្រើភាសាខ្មែរម្តង។ "**នេះជាសាលារៀន**"។ "**តើគេនិយាយថាដូចម្តេចនៅក្នុងភាសារបស់ប្អូន?**" (សិស្សឆ្លើយដោយប្រើភាសារបស់ពួកគេ)។ "**នេះជាសិស្សពីរនាក់**" "**តើគេនិយាយថាដូចម្តេចនៅក្នុងភាសារបស់ប្អូន?**" (សិស្សឆ្លើយដោយប្រើភាសារបស់ពួកគេ)។

៦. ចូររំលឹកប័ណ្ណពី១ដល់១០ឡើងវិញដោយប្រើភាសាខ្មែរ។ ចូរប្រាប់សិស្សថា "**នេះជាសាលារៀនមួយ**"។ បន្ទាប់មកសួរសិស្សថា "**តើវាជាអ្វី?**" (សាលារៀនមួយ)។ "**នេះជាសិស្សពីរនាក់**" "**តើមានសិស្សប៉ុន្មាននាក់?**" (២)។

៧. ចូរលើកប័ណ្ណរូបភាពផ្សេងៗឡើង ដោយមិនចាំបាច់តាមលំដាប់លំដោយទេ ហើយសួរសិស្សថា "**តើមាន.......ដែលប្អូនៗមើលឃើញ?**"។ បែងចែកសិស្សជាប្រាំក្រុម។ ចូរផ្តល់ឱ្យក្រុមនីមួយៗនូវប័ណ្ណរូបភាពពីរ ហើយឱ្យក្រុមទាំងនោះប្រាប់គ្នាទៅវិញទៅមកអំពីរូបភាពនៅលើប័ណ្ណ បន្ទាប់មកគ្រូត្រូវប្តូរប័ណ្ណរូបភាពពីក្រុមមួយទៅកាន់ក្រុមផ្សេងទៀត។

៨. ចូររំលឹកលេខពី១ដល់១០ម្តងទៀត។ ចូរបិទរូបភាពរបស់អ្នកនៅលើក្តារខៀនមិនឱ្យត្រូវតាមលំដាប់លំដោយ។ ចូរឱ្យសិស្សឡើងមកក្តារខៀនដើម្បីរៀបប័ណ្ណទាំងនោះឱ្យត្រូវតាមលំដាប់លំដោយពី១ដល់១០។ ប័ណ្ណទី១ គួរតែជា "**សាលារៀន**" ប័ណ្ណទី២ជា "**សិស្សពីរនាក់**" ។ល។ សិស្សទាំងឡាយនៅក្នុងថ្នាក់ក៏អាចជួយបានដែរ។

៩. ចូរប្រើសម្ភារជាក់ស្តែងដើម្បីរំលឹកលេខនិងវាក្យស័ព្ទថ្មីជាភាសាខ្មែរឡើងវិញ។ ចូរសួរសិស្សថា "**សូមបង្ហាញខ្មៅដៃ៤ដល់ខ្ញុំ**"។ សិស្សត្រូវលើកខ្មៅដៃ៤ឡើង។ "**សូមបង្ហាញកាតាបពាដល់ខ្ញុំ**" ។ល។

១០.ចូរណែនាំលេខខ្មែរដល់សិស្ស។ ចូរគ្រូបការប្រកបរបស់លេខ បន្ទាប់មកចង្អុលទៅលេខទីមួយៗហើយប្រាប់ថា **"នេះជាលេខមួយ"**។ **"តើនេះជាអ្វី?"** (លេខមួយ)។ **"នេះជាលេខពីរ"**។ល។

១១.**មើល គ្រូប សរសេរ ផ្ទៀងផ្ទាត់** លេខពី ១ ដល់ ១០ ។ ចូរគ្រូបការប្រកបលេខសម្រាប់សកម្មភាពនេះ ។ ចូរលើកប័ណ្ណមួយឡើងហើយសួរថា **"តើនេះជាលេខប៉ុន្មាន?"** (លេខ២) ។ ចូរគ្រូបប័ណ្ណនោះ ហើយឱ្យសិស្សសរសេរលេខនៅលើក្ដារឆ្នួនរបស់ពួកគេ ។ ចូរប្រាប់សិស្ស **" ចូរលើកក្ដារឆ្នួនប្អូនៗឡើង"** ។ បន្ទាប់មកបើកប័ណ្ណនោះវិញដើម្បីផ្ទៀងផ្ទាត់ ។

១២.ចូរចែកសិស្សក្នុងថ្នាក់ទៅជាក្រុមដែលមានគ្នា ១០ នាក់ ។ ចូរចែកប័ណ្ណមួយដល់ក្រុមនីមួយៗ ។ គ្រូបការប្រកបរបស់លេខសម្រាប់សកម្មភាពនេះ ។ ចូរហៅសិស្សម្នាក់ពីក្នុងក្រុមនីមួយៗឱ្យឡើងមកខាងមុខហើយប្រាប់សិស្ស **"ចូររៀប ប័ណ្ណរបស់ប្អូនៗឱ្យត្រូវតាមលំដាប់ពី ១ ដល់ ១០"** ។ ថ្នាក់ទាំងមូលអាចជួយបាន ។

១៣. ចូរណែនាំសិស្សឱ្យស្គាល់ពីការប្រកបរបស់លេខពី ១ ដល់ ១០ ។ លើកប័ណ្ណពី ១ ដល់ ១០ ឡើង ។ ចូរចង្អុលលេខ **"តើនេះជាលេខប៉ុន្មាន?"** (លេខ១) ។ ចង្អុលទៅពាក្យ និងនិយាយប្រាប់សិស្ស **"នេះគឺជាលេខមួយ"** ។ ចូរធ្វើសកម្មភាពនេះដោយប្រើប័ណ្ណដែលនៅសល់ ។

១៤.រំលឹកការអានពាក្យថ្មីឡើងវិញជាភាសាខ្មែរ ។ នៅលើកនេះ ចូរគ្រូបលេខនៅលើប័ណ្ណ ។ លើកប័ណ្ណនីមួយៗឡើងនិងចង្អុលពាក្យតែប៉ុណ្ណោះ។ ចូរសួរសិស្ស **"តើនេះជាលេខប៉ុន្មាន?"**។ សិស្សអានពាក្យសម្រាប់លេខ "១"។ ចូរធ្វើ ដូចគ្នាចំពោះលេខពី ២ ដល់ ១០ ។

១៥.ចូរដាក់ប័ណ្ណទាំងអស់ពី ១ ដល់ ១០ នៅលើក្ដារខៀនទៅតាមលំដាប់មិនត្រឹមត្រូវ ។ ចូរគ្រូបលេខទាំងនោះ ។ ចូរឱ្យសិស្សរៀបប័ណ្ណឱ្យត្រូវតាមលំដាប់ពី១ដល់១០។ សិស្សគួរតែអានពាក្យ និងរៀបប័ណ្ណឱ្យត្រូវតាមលំដាប់ ។

១៦.ចូរណែនាំឱ្យសិស្សស្គាល់រូបភាព និងប័ណ្ណលេខដែលនៅជាមួយគ្នា ។ ចូរលើកគូរូបភាពនិងលេខពី ១ ដល់ ១០ ឡើង (ឧទាហរណ៍: ប័ណ្ណរូបភាព**សាលារៀន** និងប័ណ្ណលេខ១) ។ ចូរសួរសិស្ស **"តើនេះគឺជាអ្វី?"** (វាគឺជាសាលារៀន) ។ **"តើមានសាលារៀនប៉ុន្មាន?"** (១) ។

១៧.ចូរដាក់រូបភាព និងប័ណ្ណលេខនៅលើក្ដារខៀន ។ ចូរឱ្យសិស្សផ្គូរផ្គងរូបភាព និងប័ណ្ណលេខឱ្យបានត្រឹមត្រូវ ។

១៨.ចូរចែកសិស្សក្នុងថ្នាក់ជា ២០ក្រុម ។ ចូរចែកប័ណ្ណមួយដល់ក្រុមនីមួយៗ ។ ចូរប្រាប់ក្រុមនីមួយៗថា **"ប័ណ្ណរបស់ប្អូនៗត្រូវតែមានគូត្រូវគ្នា ។ ចូររកក្រុមដែលមានគូប័ណ្ណរបស់ប្អូនៗ"** ។ សិស្សត្រូវតែដើរជុំវិញថ្នាក់ដើម្បីរកក្រុមដែលមានរូបភាព ឬ ប័ណ្ណលេខដែលត្រូវគ្នាជាមួយប័ណ្ណពួកគេ ។

## II. ការថតែកអំពីរូបភាព និងរឿងនិទាន " រាងកាយរបស់យើង "

១. ចូរសួរសំណួរដល់សិស្ស ដោយប្រើសំណួរប្រភេទ ខុស និង ត្រូវអំពីរូបភាពជាភាសាខ្មែរ។ ចូររំលឹកពាក្យដែលទាក់ ទង ពណ៌ និង សំលៀកបំពាក់ឡើងវិញ។

**ចូរជួយសិស្សដោយប្រើភាសាកំណើតរបស់គេ បើសិនជាចាំបាច់។**

សិស្សានេះពាក់មួកពណ៌ខ្មៅ (**ខុស ឬ ត្រូវ?**)

សិស្សីនេះខ្ពស់ជាងសិស្សានេះ (**ខុស ឬ ត្រូវ?**)

មានសិស្សាចំនួន៤នាក់នៅក្នុងរូបភាព (**ខុស ឬ ត្រូវ?**)

សារ៉ុងរបស់សិស្សីខ្លី (**ខុស ឬ ត្រូវ?**)

**២. ចូរពណ៌នាខ្លីមួយទៅកាន់សិស្សអំពីមិត្តរបស់អ្នកជាភាសាខ្មែរ ។ សិស្សត្រូវគូរទៅតាមអ្វីដែលពួកគេឮតាមរយៈការពណ៌នា ។ ពួកគេនឹងត្រូវការក្រដាស និងខ្មៅដៃពណ៌ ។ ចូរអានការពណ៌នានោះចំនួន៣ឬ៤ដងឱ្យសិស្សស្តាប់ ។**

មិត្តរបស់ខ្ញុំឈ្មោះ ណាង ។ នាងមានកំពស់ខ្ពស់ និងមានសក់ខ្លីពណ៌ខ្មៅ ។ នាងមានភ្នែកធំពណ៌ត្នោត និងច្រមុះតូច ។ នាងស្លៀកពាក់អាវយឺតពណ៌ក្រហម និងសារ៉ុងពណ៌បៃតង ។

**ចូរឱ្យសិស្សបង្ហាញរូបភាពទៅកាន់ដៃគូរបស់ពួកគេ ។ ចូរឱ្យសិស្សលើករូបភាពនោះឡើង ។ ចូរត្រួតពិនិត្យ ថាតើរូបនោះត្រូវជាមួយការពណ៌នាឬទេ ។**

**ដោយធ្វើជាដៃគូ ចូរឱ្យសិស្សព្យាយាមពណ៌នាមិត្តរបស់ពួកគេដោយប្រើភាសាខ្មែរ ។ ដៃគូម្ខាងទៀតត្រូវស្តាប់ការពណ៌នានោះ ហើយព្យាយាមគូររូបភាពមិត្តឱ្យបានត្រឹមត្រូវតាមដែលអាចធ្វើបាន ។**

# មេរៀនទី ៨

## តើប្អូនៗកំពុងធ្វើអ្វី?





**- កំពុងតែរៀបចំផ្លែឈើសម្រាប់លក់**

## គោលបំណងនៃមេរៀន

### នៅក្នុងមេរៀននេះ សិស្សនឹងរៀនៈ

- បទបញ្ជារបស់ថ្នាក់រៀន
- ភាសានៃការស្វាគមន៍ និងការណែនាំគ្នា
- ចំនួនពី ១-២០
- ច្រៀងចំរៀងខ្មែរ
- ដើម្បីចូលរួមជជែកអំពីរូបភាពអំពីការរៀបចំផ្លែឈើសម្រាប់លក់

## ធនធានសម្ភារសម្រាប់បង្រៀន

### សម្ភារមានដូចជាៈ

- រូបភាព "ការរៀបចំផ្លែឈើ"
- រឿងនិទាន "ពេរៀបចំផ្លែឈើសម្រាប់លក់"
- ការសន្ទនាគ្នា
- ចំរៀង

ចូរបែងចែងពេលវេលារបស់លោកគ្រូ/អ្នកគ្រូដើម្បីធ្វើសកម្មភាពខ្លីៗពីឈុតសកម្មភាពទាំង៥ខាងក្រោម ។
ចូរព្យាយាមធ្វើសកម្មភាពពី៤ទៅ៥ ខុសៗគ្នានៅក្នុងមេរៀនរយៈពេលមួយម៉ោង របស់លោកគ្រូ/អ្នកគ្រូ ។

## បញ្ជីពាក្យ

| | | |
|---|---|---|
| មួយ | ទីមួយ/ដំបូង | ទទេ |
| បី | ទីពីរ | ពេញ |
| ប្រាំបី | ចុងក្រោយ | |
| ប្រាំបួន | ឥឡូវនេះ | |
| ខ្លះ | ថ្ងៃច័ន្ទ | |

## ឈុតសកម្មភាពទី១ ការនិយាយអំពីប្រធានបទជាភាសាកំណើតរបស់កុមារ

***គោលបំណង*** សិស្សពណ៌នាអំពីផ្លែឈើ និងបន្លែដែលស្គាល់ដោយប្រើភាសាកំណើតពួកគេ ។

***សម្ភារ*** ឧទាហរណ៍នៃផ្លែឈើ/បន្លែនៅមូលដ្ឋាន, ក្រដាស, ខ្មៅដៃពណ៌

១. ចូរយកផ្លែឈើ និងបន្លែនៅមូលដ្ឋានខ្លះមកថ្នាក់រៀន (ចេក, ស្វាយ, ទំពាំងបាយជូរ, ត្រកួន) ។ បង្ហាញវាដល់សិស្ស ។ ចូរសួរ សំណួរខ្លះដល់សិស្ស ។

| សំណួរគ្រូ | ចម្លើយសិស្ស |
|---|---|
| *តើនេះជាបន្លែ/ផ្លែឈើអ្វី?* | *សិស្សឆ្លើយ* |
| *តើប្អូនៗធ្លាប់បរិភោគវាពីមុនមកឬទេ?* | *បាទ/ចាស់* |
| *តើប្អូនៗចូលចិត្តបរិភោគវាឬទេ?* | *បាទ/ចាស់/វាមានរសជាតិផ្អែម* |

ចូរហុចបន្លែ និងផ្លែឈើពីសិស្សម្នាក់ទៅម្នាក់ទៀត ដើម្បីឱ្យពួកគេអាចឃើញវា និងពណ៌នាអំពីវា ។ "**តើវាធ្ងន់/ស្រាល/ធំ/តូច ឬទេ?**" ចូរស្តាប់ការពណ៌នារបស់សិស្ស ។

២. ចូរសួរសិស្ស តើពួកគេស្គាល់ឈ្មោះផ្លែឈើ ឬបន្លែផ្សេងទៀតឬទេ ។ ចូររាយបញ្ជីផ្លែឈើ និងបន្លែទាំងនេះនៅលើក្តារខៀន ។ ចូរឱ្យសិស្សពណ៌នាវា ។ " **តើវាធំ/តូច/ធ្ងន់/ស្រាលឬទេ?**" និង ។ល ។

៣. ចូរចែកក្រដាសខ្លះដល់សិស្ស ។ ចូរឱ្យពួកគេគូររូបភាពផ្លែឈើ ឬបន្លែដែលពួកគេចូលចិត្តបរិភោគជាងគេ ។ ចូរឱ្យសិស្សពណ៌នារូបភាពពួកគេ ។ ដាក់តាំងរូបភាពទាំងនោះនៅក្នុងថ្នាក់រៀន ។

## ឈុតសកម្មភាពទី២ ការនិយាយអំពីរូបភាពជាភាសាកំណើតរបស់កុមារ

***គោលបំណង*** សិស្សបានស្គាល់រូបភាព និងខ្លឹមសាររឿងរបស់វាជាភាសាពួកគេជាលើកដំបូង ។ សិស្សហាត់ធ្វើការទស្សន៍ទាយ ។

***សម្ភារ*** រូបភាព, ផ្ទាំងក្រដាសធំ, ប៊ិចហ្វឺត

១. បង្ហាញរូបភាពដល់សិស្ស ។ ចូរឱ្យសិស្សធ្វើការទស្សន៍ទាយអំពីរូបភាព ។

| សំណួរគ្រូ | ចម្លើយទស្សន៍ទាយរបស់សិស្ស |
|---|---|
| *តើសិស្សានេះឈ្មោះអ្វី?* | *សិស្សឆ្លើយ* |
| *តើវាកំពុងតែធ្វើអ្វី?* | *កំពុងលាងផ្លែឈើ? សំអាតផ្លែឈើ? ដាក់ផ្លែឈើចូលក្នុងកាផា?* |
| *តើប្អូនៗអាចមើលឃើញប្រភេទផ្លែឈើអ្វីខ្លះ?* | *ចេក? ឪឡឹក?* |
| *តើហេតុអ្វីបានជាវាលាងផ្លែឈើ?* | *វាចង់ស៊ីផ្លែឈើនោះ? វាចង់លក់ផ្លែឈើនោះ?* |
| *តើវាដាក់ផ្លែឈើចូលទៅក្នុងអ្វី?* | *កាផា?* |
| *តើវាយកផ្លែឈើទៅណា?* | *ផ្សារ?* |

២. ចូរចង្អុលវត្ថុផ្សេងៗនៅក្នុងរូបភាព ។ ចូរសួរ "**តើនេះគឺជាអ្វី?**" (កាផា/ចេក/សិស្សា/ឪឡឹក) ។ ចូរស្តាប់គំនិតសិស្ស ។ ចូរប្រាប់ពាក្យនោះដល់ពួកគេប្រសិនបើពួកគេមិនដឹង ។

៣. ចូរវាយបញ្ជីពាក្យទាំងនេះជាភាសាកំណើតរបស់កុមារ នៅលើផ្ទាំងក្រដាសធំ ។ អានពាក្យទាំងនេះឱ្យសិស្សស្តាប់ ។ ចូរអាន ពាក្យទាំងនេះជាមួយសិស្ស ។

៤. ចូរចង្អុលពាក្យមួយនៅលើបញ្ជី ។ ឧ: "ចេក" ។ ចូរឱ្យសិស្សចង្អុល "ចេក" នៅក្នុងរូបភាព ។

## ឈុតសកម្មភាពទី៣ ការនិយាយអំពីរូបភាពជាភាសាខ្មែរ ( ដោយផ្ទាល់មាត់តែប៉ុណ្ណោះ)

***គោលបំណង*** សិស្សបានស្គាល់រូបភាព និងខ្លឹមសាររឿងរបស់វាជាភាសាខ្មែរ ។

***សម្ភារ*** រូបភាព (មេរៀនទី ២)

១. ចូរប្រាប់សិស្សថា ពួកគេបាននិយាយអំពីរូបភាពមួយនៅក្នុងមេរៀនកាលពីម្សិលម៉ិញ ។ ចូរសួរ "**តើប្អូនៗបានមើលឃើញអ្វីខ្លះនៅក្នុងរូបភាព?**" ។ សិស្សចាប់គូ និយាយអំពីរូបភាព ។ ចូរសួរអំពីគំនិតសិស្ស ។ សរសេរវាដាក់លើក្តារខៀនជាភាសាកំណើតរបស់កុមារ ។

២. ចូរលើករូបភាពឡើងលើ ។ ចង្អុលទៅកាន់វត្ថុផ្សេងៗ និងសួរ "**តើនេះជាអ្វី?**" ។ សិស្សគួរឆ្លើយជាភាសាកំណើត ពួកគេ។ ចូរសរសេរបន្ថែមទៅក្នុងបញ្ជីនៅលើក្តារខៀន ប្រសិនបើចាំបាច់ ។

៣. ឥឡូវនេះ ចូរប្រាប់សិស្សអំពីរូបភាពដោយប្រើភាសាខ្មែរ ។

**នេះគឺជា ............... ។ សិស្សា/ចេក/កាផា/ឪឡឹក/ផ្លែឈើ**

៤. ចូរពិនិត្យមើលថា សិស្សយល់ភាសាខ្មែរថ្មី ។ ចូរចង្អុលវត្ថុផ្សេងៗ និងសួរថា " **តើនេះជាអ្វី?**" សិស្សគួរឆ្លើយជាភាសាខ្មែរ

៥. ចូរចង្អុលពាក្យជាភាសាកំណើតរបស់កុមារ នៅលើក្តារខៀន ។ ចូរអានពាក្យទាំងឡាយជាមួយសិស្ស ។ ចូរចង្អុលពាក្យ "ចេក" ដោយប្រើភាសាកំណើតពួកគេ ។ ចូរសួរ "**តើយើងនិយាយពាក្យនេះយ៉ាងដូចម្តេចជាភាសាខ្មែរ?**" ។ ចូរមើលតើសិស្សអាចបកប្រែពាក្យផ្សេងទៀតពីបញ្ជីទៅជាភាសាខ្មែរបានឬទេ ។ ឱ្យសិស្សធ្វើដោយផ្ទាល់មាត់តែប៉ុណ្ណោះ ។

៦. ចូរផ្តល់បទបញ្ជាខ្លះៗដល់សិស្សដោយប្រើភាសាខ្មែរ ។ **"ចូរគូរចេកមួយផ្លែ"** ។ ចូរពិនិត្យមើលតើសិស្សបានយល់ឬទេ ។ ឥឡូវនេះ ចូរប្រាប់សិស្ស **"ចូរគូររូបចេក ៥ ផ្លែ នៅក្នុងកាផា"** ។ ចូរពិនិត្យមើលថា រូបភាពរបស់ពួកគេពិតជាត្រឹមត្រូវ ។

## ឈុតសកម្មភាពទី៤ ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ

***គោលបំណង*** ដើម្បីណែនាំសិស្សឱ្យស្គាល់អំពីភាសាខ្មែរ ដែលពួកគេត្រូវប្រើសម្រាប់និយាយអំពីរូបភាព ដោយប្រើវិធីសាស្ត្រភាសាទាំងមូល (whole language approach)

***សម្ភារ*** រូបភាព (មេរៀនទី ២)

១. ចូរអានរឿងនិទានឱ្យសិស្សស្តាប់ ។ សិស្សគ្រាន់តែក្រឡេកមើលរូបភាព និងស្តាប់រឿងនិទានប៉ុណ្ណោះ ។ នេះគឺជាព្រឹកថ្ងៃសៅរ៍ ហើយពេបានរៀបចំផ្លែឈើខ្លះរួចជាស្រេចដើម្បីយកទៅលក់នៅទីផ្សារ ។ លើកទីមួយ វាបានលាងផ្លែល្ហុងបី ។ លើកទីពីរ វាបានលាងផ្លែឪឡឹកមួយ ។ និងនៅចុងក្រោយ វាបានលាងចេកពីរស្និត ។ ស្និតទីមួយមានប្រាំបីផ្លែ ។ ស្និតទីពីរមានប្រាំបួនផ្លែ ។ នៅពេលវាលាងផ្លែឈើរួចហើយ វាក៏បានខ្ចប់ផ្លែឈើទាំងនោះហើយដាក់ចូលទៅក្នុងកាផាទទេមួយ ។ ដំបូងវាដាក់ឪឡឹកចូលទៅក្នុងកាផា ។ ទីពីរវាបានដាក់ចេកចូលទៅក្នុងកាផា ។ វាដាក់ល្ហុងចូលទៅក្នុងកាផានៅចុងក្រោយគេ ។ ឥឡូវនេះកាផារបស់វាពេញហើយ ។ គោរបស់ពេកំពុងមើលវា ។ ឥឡូវនេះ វាត្រៀមខ្លួនរួចជាស្រេចដើម្បីយកផ្លែឈើទៅលក់នៅទីផ្សារ ។ តើពេមានជួបបញ្ហាដោយសារតែវាដាក់ផ្លែឪឡឹកមុនគេចូលទៅក្នុងកាផាឬទេ?

២. អានរឿងនិទានម្តងទៀតឱ្យសិស្សស្តាប់ ។ សិស្សគ្រាន់តែមើលរូបភាព និងស្តាប់តែប៉ុណ្ណោះ ។

៣. ចូរចង្អុលវត្ថុផ្សេងៗនៅក្នុងរូបភាព ។ ចូរសួរ **"តើនេះជាអ្វី?"** (ល្ហុងមួយផ្លែ/ចេក/គោ/កាផា) ។ ជួយសិស្សនៅពេលចាំបាច់ ។

៤. ប្រាប់សិស្សថា លោកគ្រូ/អ្នកគ្រូនឹងអានរឿងនិទានម្តងទៀត ។ ប្រាប់ពួកគេឱ្យទះដៃម្តង នៅពេលពួកគេឮលោកគ្រូ/អ្នកគ្រូអានពាក្យ "ចេក" ។ បន្ទាប់ពីលោកគ្រូ/អ្នកគ្រូអានរួច ចូរសួរ **"តើអ្នកគ្រូ (លោកគ្រូ) បានអានពាក្យ "ចេក" ប៉ុន្មានដង?"** (៤ ដង) ។

៥. ចូរឱ្យសិស្សគូររូបភាពអ្វីមួយពីក្នុងរូបភាព ។ ឧទាហរណ៍: ឪឡឹក ។

៦. សិស្សគូររូបភាពនៅលើក្តារឆ្នួនពួកគេ ។ ចូរដើរជុំវិញថ្នាក់រៀន និងសួរសិស្សតើពួកគេគូររូបភាពអ្វី ។

៧. ឱ្យសិស្សបង្ហាញរូបភាពពួកគេ និងពន្យល់ តើរូបភាពនោះនិយាយអំពីអ្វី ។ ឧទាហរណ៍: **នេះគឺជាកាផាមួយ** ។

## ឈុតសកម្មភាពទី៥ ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ ។ ការទស្សន៍ទាយពាក្យ

***គោលបំណង*** សិស្សនឹងបំពេញប្រយោគដែលស្គាល់ពីរឿងនិទាន ដោយធ្វើសកម្មភាពបំពេញផ្ទាល់មាត់

***សម្ភារ*** រូបភាព (មេរៀនទី ២), ក្រដាស, ខ្មៅដៃពណ៌

១. ប្រាប់សិស្សថា លោកគ្រូ/អ្នកគ្រូបានអានរឿងនិទានឱ្យពួកគេស្តាប់នៅក្នុងមេរៀនម្សិលមិញ ។ សួរសំណួរខ្លះជាភាសាខ្មែរ ។ ចូរលើកទឹកចិត្តសិស្សឱ្យឆ្លើយជាភាសាខ្មែរ ។

| សំណួរគ្រូ | ចម្លើយទស្សន៍ទាយរបស់សិស្ស |
|---|---|
| *តើសិស្សានៅក្នុងរឿងនេះឈ្មោះអ្វី?* | *សិស្សឆ្លើយ* |
| *តើផ្លែឈើអ្វីខ្លះដែលវាខ្ចប់នៅលើកទី១, ២ និងទី ៣?* | *ចេក? ឪឡឹក? ល្ហុង?* |
| *តើនៅក្នុងរឿងនិទានមានសត្វគោឬទេ?* | *មាន? គ្មាន?* |
| *តើនៅក្នុងរឿងនិទានគោកំពុងតែធ្វើអ្វី?* | *កំពុងតែស៊ី? កំពុងតែមើល ពេ? កំពុងតែដេក?* |

១. អានរឿងនិទាន (ពីមេរៀនទី ៤) ឱ្យសិស្សស្តាប់ ។ ចូរពិនិត្យមើល ដើម្បីឱ្យសិស្សឆ្លើយសំណួរបានត្រឹមត្រូវ ។

២. អានរឿងនិទានម្តងទៀតឱ្យសិស្សស្តាប់ ។ លើកនេះ ចូរឈប់ដោយអន្លើនៅពេលដែលលោកគ្រូ/អ្នកគ្រូអាន ។ សិស្សត្រូវតែនិយាយពាក្យបន្ទាប់ ។ ឧទាហរណ៍ៈ ដំបូងវាលាង ................បី (ល្ហុង?) និង ។ល។

## ឈុតសកម្មភាពទី៦ ការនិទានរឿងនៅក្នុងរូបភាពដោយប្រើភាសាខ្មែរ ។ សម្តែងតួរអំពីរឿងនិទាន

***គោលបំណង*** សិស្សនឹងហាត់និទានរឿងជាមួយគ្រូ

***សម្ភារ*** រូបភាព (មេរៀនទី ២)

១. អានរឿងនិទាន (ពីមេរៀនទី ៤) ឱ្យសិស្សស្តាប់ ។ សិស្សគ្រាន់តែមើលរូបភាព និងស្តាប់រឿងនិទានតែប៉ុណ្ណោះ ។

២. អានរឿងនិទានម្តងទៀត ហើយនៅលើកនេះ ត្រូវឈប់ជារឿយៗ និងឱ្យសិស្សនិយាយពាក្យបន្ទាប់ ។

៣. អានរឿងនិទានម្តងទៀត ហើយនៅលើកនេះ សិស្សត្រូវនិទានរឿងជាមួយលោកគ្រូ/អ្នកគ្រូ ។

៤. សម្តែងតួរឿងនិទានឱ្យសិស្សមើល ។ សម្តែងតួធ្វើជា ពេកំពុងលាងផ្លែឈើ និងដាក់វាចូលទៅក្នុងកាផា ។ ចូរសួរសំណួរខ្លះ នៅពេលលោកគ្រូ/អ្នកគ្រូធ្វើចប់ ។

| សំណួរគ្រូ | ចម្លើយទស្សន៍ទាយរបស់សិស្ស |
|---|---|
| *តើអ្នកគ្រូ (លោកគ្រូ) កំពុងតែធ្វើអ្វី?* | *កំពុងលាងផ្លែឈើ? កំពុងតែដាក់វាចូលក្នុងកាផា?* |
| *តើអ្នកគ្រូ (លោកគ្រូ) កំពុងតែលាងផ្លែឈើអ្វី?* | *ចេក? ល្ហុង?* |
| *តើផ្លែឈើនេះធំ/តូច/ធ្ងន់/ស្រាលឬទេ?* | *សិស្សឆ្លើយ* |
| *តើអ្នកគ្រូ(លោកគ្រូ)ដាក់ផ្លែឈើអ្វីចូលក្នុងកាផាមុនគេ?* | *ឪឡឹក? ចេក?* |

៥. សិស្សត្រូវចាប់គូ និងសម្តែងតួអំពីរឿងនិទានឱ្យគ្នាមើលទៅវិញទៅមក ។ ត្រូវដើរនៅជុំវិញថ្នាក់ និងសួរសំណួរដល់សិស្សអំពីអ្វីដែលពួកគេកំពុងតែធ្វើ ។

៦. ឱ្យសិស្សពីរគូផ្សេងគ្នា សម្តែងតួ ឱ្យថ្នាក់ទាំងមូលមើល ។

**ឈុតសកម្មភាពទី៧ ការប្រើភាសាខ្មែរធ្លាប់ស្គាល់ជាទំរង់នៃការសន្ទនា**

***គោលបំណង*** សិស្សហាត់ប្រើភាសាខ្មែរធ្លាប់ស្គាល់ជាទំរង់នៃការសន្ទនា

***សម្ភារ*** រូបភាព (មេរៀនទី ២)

១. ប្រាប់សិស្សថា ពួកគេបានរៀនយ៉ាងច្រើនរួចហើយអំពីសិស្សា ពេ ។ នៅថ្ងៃនេះពួកគេនឹងស្តាប់លោកគ្រូ/អ្នកគ្រូអានការសន្ទនារវាងពេ និងម្តាយវា ។ ចូរសួរសិស្ស **"តើពេ និងម្តាយវានឹងនិយាយគ្នាអំពីអ្វី?"** (ផ្លែឈើ? ពេយកផ្លែឈើទៅផ្សារ?) ។ ចូរស្តាប់គំនិតទស្សន៍ទាយរបស់សិស្ស ។

២. អានការសន្ទនា ។ ប្រាប់សិស្សឱ្យត្រឹមតែស្តាប់ប៉ុណ្ណោះ ។ ប្រសិនបើមានគ្រូ ២ នាក់, គ្រូម្នាក់ៗត្រូវអានផ្នែកសន្ទនាផ្សេងៗគ្នា ។

**ម្តាយ:** សួស្តីពេ ។ តើកូនកំពុងតែធ្វើអ្វី?

**ពេ:** សួស្តីម៉ែ ។ កូនកំពុងតែលាងផ្លែឈើខ្លះ?

**ម្តាយ:** តើកូនលាងវាធ្វើអ្វី?

**ពេ:** លាងវាដើម្បីយកទៅលក់នៅផ្សារ ។

**ម្តាយ:** តើកូននឹងយកផ្លែឈើទាំងនេះទៅផ្សារយ៉ាងដូចម្តេច?

**ពេ:** កូននឹងខ្ចប់វាដាក់ចូលកាផាររបស់ខ្ញុំ ។

**ម្តាយ:** ពិតជាល្អណាស់ពេ ។ អរគុណកូន ។

ចូរពិនិត្យមើលថា តើការទស្សន៍ទាយរបស់សិស្សត្រឹមត្រូវ ឬមិនត្រូវត្រូវ ។

៣. អានការសន្ទនាម្តងទៀត ។ សិស្សមើល និងស្តាប់ ។

៤. អានការសន្ទនាម្តងទៀត ។ សិស្សព្យាយាមនិយាយវាជាមួយលោកគ្រូ/អ្នកគ្រូ ។

៥. ចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ មួយក្រុមធ្វើជា ពេ និងមួយក្រុមទៀតធ្វើជាម្តាយ ។ ចូរហាត់ធ្វើការសន្ទនារួមគ្នាជាមួយសិស្ស ។

## នេះគឺជាព្រឹកថ្ងៃសៅរ៍ ហើយពេបានរៀបចំផ្លែឈើខ្លះរួចជាស្រេចដើម្បីយកទៅលក់នៅទីផ្សារ ។ លើកទីមួយវា បានលាងផ្លែល្ហុងបី ។ លើកទីពីរវាបានលាងផ្លែត្រសក់ស្រូវមួយ និងនៅចុងក្រោយ វាបានលាងចេកពីរស្និត ។ ស្និតទីមួយមានប្រាំបីផ្លែ ។ ស្និតទីពីរមានប្រាំបួនផ្លែ ។ នៅពេលវាលាង

ផ្លែឈើរួចហើយ វាក៏ដាក់ចូលទៅក្នុងកាផា ទទេមួយ ។ ដំបូងវាដាក់ត្រសក់ស្រូវចូលទៅក្នុងកាផា ។ ទីពីរវាបានដាក់ចេក ចូលទៅក្នុងកាផា ។ វាដាក់ល្ពៅចូលទៅក្នុងកាផានៅចុងក្រោយគេ ។ ឥឡូវ នេះកាផារបស់វាពេញហើយ ។ គោរបស់ពេកំពុងមើលវា ។ ឥឡូវនេះ វាត្រៀមខ្លួនរួចជាស្រេចដើម្បីយកផ្លែឈើទៅលក់នៅទីផ្សារ ។ តើពេមាន ជួបបញ្ហាដោយសារតែវាដាក់ផ្លែត្រសក់ស្រូវមុនគេចូលទៅក្នុងកាផាឬទេ?

**ម្ដាយ:** សួស្ដីពេ ។ តើកូនកំពុងតែធ្វើអ្វី?

**ពេ :** សួស្ដីម៉ែ ។ កូនកំពុងតែលាងផ្លែឈើខ្លះ?

**ម្ដាយ:** តើកូនលាងវាធ្វើអ្វី?

**ពេ :** លាងវាដើម្បីយកទៅលក់នៅផ្សារ ។

**ម្ដាយ:** តើកូននឹងយកផ្លែឈើទាំងនេះទៅផ្សារយ៉ាងដូចម្ដេច?

**ពេ :** កូនដាក់វាចូលក្នុងកាផារបស់កូន ។

**ម្ដាយ:** ពិតជាល្អណាស់ពេ ។ អរគុណហើយកូន ។